# ក្រុមជំនុំ និងស្ថានភាពរបស់ក្រុមជំនុំ

វាពិតជាកម្រពីជំងឺនៃក្មេងម្នាក់នេះត្រូវបានចងចាំនៅក្នុងការអធិស្ឋានពេលនេះ ដូចគ្នាដែរយើងឲ្យទាំងអស់គ្នាធ្វើបែបនោះ។ ដុកទ័រមិនទាំងបានដឹងផង។ គេបានហៅ ឈ្មោះជំងឺនោះថាជាអ្វីមួយខ្ញុំគិតថាវាគ្រាន់តែហៅ បានម្យ៉ាងប៉ុណ្ណោះពួកគេ—ពួក គេមិនដឹងថាវាជាអ្វី។ ហើយ ប៉ុន្តែព្រះគ្រីស្ទដឹងថាវាជាអ្វី។ ខ្ញុំអាចប្រាប់វាថាជាអ្វី វាជាអារក្ស ត្រូវហើយ ជាអារក្ខ។ តើឈ្មោះអីដែលគេចង់ដាក់ឲ្យ ហេតុអ្វី នោះស្រេចតែគេ។ ប៉ុន្តែនោះគឺវាហើយ មើល ជាវិញ្ញាណអារក្ស។ ឥឡូវ ចូរ ទាំងអស់គ្នាជាមួយគ្នាម្តង *គ្រាន់តែជឿតាម* គ្រប់គ្នាចេញមក ឥឡូវ។

គ្រាន់តែជឿតាម គ្រាន់តែជឿតាម
គ្រប់យ៉ាងសម្រេចបាន គ្រាន់តែជឿតាម
គ្រាន់តែជឿតាម គ្រាន់តែជឿតាម
គ្រាប់យ៉ាងសម្រេចបាន គ្រាន់តែ...

2 ព្រះអម្ចាស់នឹងប្រោស អ្នកឲ្យបានជាប្អូនស្រី។ ចូរអធិស្ឋានសម្រាប់ក្មេងស្រីកាលបើយើងឱនក្បាល។

3 ព្រះវរបិតានៅស្ថានសួគ៌របស់យើង ខ្ញុំហាក់ដូចជា មិនអាចដកវាចេញពីគំនិតរបស់ខ្ញុំឡើយ។ ក្មេងស្រីតូចនៅទីនោះ កំពុងស្លាប់ នាងជាអ្នកជាទីស្រឡាញ់របស់នរណាម្នាក់។ នាងជាស្នាព្រះហស្តទ្រង់ ហើយសាតាំងកំពុងប្លន់យក ជីវិតវ័យក្មេងរបស់នាង។ ខ្ញុំអធិស្ឋាន ក្នុងព្រះនាមព្រះគ្រីស្ទនោះទ្រង់នឹងទប់ដៃនៃសេចក្តីស្លាប់ដេញពួកខ្មាំងសត្រូវទៅវិញ។ ទ្រង់ជា ព្រះអម្ចាស់ អាចញែកសមុទ្រក្រហម និងសង់ជញ្ជាំងទាំងសងខាង និងប្រទានដល់កូនចៅអ៊ីស្រាអ៊ែល មរតករបស់ទ្រង់ជាការធ្វើដំណើរសុវត្ថិភាព ឆ្លងកាត់សមុទ្រក្រហមនិងចូលទៅកាន់ទឹកដីសន្យា។ ព្រះអើយ ទូលបង្គំយើងខ្ញុំអធិស្ឋាន ថ្ងៃនេះទ្រង់នឹងដកគ្រប់ទាំងរនាំងទៅវិញនិងប្រោសឲ្យក្មេងបានរស់។ វាជាការដែលប្រាប់ឲ្យទូលបង្គំយើងខ្ញុំទូលសុំ។ និងមានក្រុមមនុស្សដែលបានជឿដល់ទ្រង់ យើងខ្ញុំអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវសម្រាប់ការប្រោសឲ្យជាដល់កូនក្មេង។ អាម៉ែន។

4 ថ្ងៃនេះវាជាអំណរព្រះគុណដែល—ខ្ញុំបានមកកាន់អ្នកម្តងទៀត ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវ។ ខ្ញុំមកផ្ទះលឿនបន្តិចពីឡូវីសស៊ីណា។ ដោយគិតថាខ្ញុំប្រហែលជាទៅដល់ទីនោះមុនថ្ងៃអាទិត្យ ដើម្បីឲ្យខ្ញុំអាចមានថ្នាក់ថ្ងៃអាទិត្យបាន។ ហើយដូច្នេះ អាកាសធាតុគឺក្តៅណាស់នៅទីនោះ ដែលយើង...នេះអាចរលាយត្រជាក់ល្អនៅព្រឹកនេះខុសពីឡូវីសស៊ីណា។ អ្នកមិនអាចអង្គុយក្នុងអាគារបែបនេះដោយមិនមានកង្ហាឡើយ ក្នុងឡូវីសស៊ីណា បើមិនមានម៉ាស៊ីនត្រជាក់ទេ អ្នកនឹងសន្លប់។

5 ហើយខ្ញុំមកបែបនេះ នោះខ្ញុំអាចសម្រាកមួយ—ឬ—ពីរថ្ងៃមុនចាកចេញទៅ សាសកាតឈឺវីនខាងជើង(Northern Saskatchewan) សប្តាហ៍បន្ទាប់ ហើយឡើងទៅព្រីនអាល់ប៊ឺត(Prince Albert)។ នោះជាផ្លូវឆ្ងាយក្នុងលោក ពីផ្នែកម្ខាងទៀត។ វាហាក់ត្រូវឆ្លងកាត់ផ្លូវទូទាំងពិភពលោក គ្មានផ្លូវណាទៀតឡើយ ហើយមិនមានផ្លូវណាទៀតក្រៅពី អ៊ិនឌៀន និងអេសគីម៉ូស(Eskimos) កាលពីសម័យមុនដែលយើងឆ្លងកាត់ពេលនេះ។ ដូច្នេះយើងមានមនុស្សជាច្រើននៅការប្រជុំនេះពីទូទាំងកាណាដា។ មានពួកគេខ្លះមកតាម ខ្សែឆ្នេរភាគខាងលិច(West Coast) ពួកគេនិយាយ មកចុះ។ ហើយខ្ញុំចង់បានសេចក្តីអធិស្ឋានរបស់អ្នកទាំងអស់ជាមនុស្សដែលព្រះនឹងជួបយើងនិងប្រទានឲ្យយើងចម្រើនឡើង ជាបរិបូណ៌ការជួបជុំយ៉ាងធំ សម្រាប់សិរីរុងរឿងរបស់ទ្រង់។ វាមានរយៈពេលបួនទៅប្រាំឆ្នាំហើយតាំងពីខ្ញុំបានមកស្គាល់កាណាដា។ ហើយខ្ញុំមានរាជមិត្តនៅទីនោះ ជាមនុស្សល្អ។

6 ហើយពួកគេមានភាពស្មោះត្រង់ណាស់ក្នុងការទៅព្រះវិហារ។ មិនថាត្រជាក់យ៉ាងណាក្តី ពួកគេបានហ៊ុំខ្លួនដោយភួយនិងអង្គុយលើគៀរទឹកកក និងជិះសេះចំងាយសាបសិបម៉ាយ ដើម្បីទៅក្រុមជំនុំ។ ពួកគេដើរពួកគេដើរដោយស្ដីរទឹកកកទាំងចាស់ទាំងក្មេង។ ពួកគេនៅ ជាក្រុមជាមួយគ្នា។ ហើយគ្រួសារមួយទៅកាន់គ្រួសារមួយហើយគេដើរជាមួយគ្នាហើយក៏ចេញទៅ។វា—វាជាការលះបង់សម្រាប់បុព្វហេតុនោះដែលនាំឲ្យពួកគេទទួលបានច្រើនពីការបម្រើ។ បើគ្មានការលះបង់ វាក៏មិនស័ក្តសមសម្រាប់កម្មវិធីដែរ។ អ្នកត្រូវតែបន្ទាបខ្លួន និងធ្វើអ្វីដែលឈឺចាប់ខ្លាំង ត្រូវទុកអ្វីមួយចោលនិងបញ្ឈប់ការងារ ហើយ*ធ្វើនេះ* ឬ *ធ្វើនោះ* ដើម្បីទៅ

ព្រះវិហារនិងបង្ហាញព្រះ ថាអ្នកស្រឡាញ់ទ្រង់ ហើយអ្នកធ្វើការលះបង់ដើម្បីទៅ វាជាអ្វីបន្ទាប់អ្នកទទួលបានអ្វីពីនោះ។

7 វាដូចជាកូនៗរបស់ខ្ញុំចឹង។ ប៊ីលីប៉ុល(Billy Paul)ខ្ញុំគិត ខ្ញុំគួរ...ខ្ញុំមិនទទួលបានអ្វីទេឡើយពេលខ្ញុំនៅក្មេង។ អ្នកម៉ែធ្លាប់មានស្ករគ្រាប់មួយថង់ហើយគាត់បានរាប់ពីរ ឬបីគ្រាប់សម្រាប់ម្នាក់ៗ។ អាចប្រហែលជាបុណ្យគ្រីស្ទម៉ាសយើងអាចទទួលបានកំប៉ុងស្នែង ឬកាំភ្លើងដៃតូចមួយ ឬអ្វីផ្សេងទៀត។ ហើយខ្ញុំឃើញគេមានប្រដាប់ជិះទឹកកកឬកង់និង ខោអាវស្អាតនិងអាវរងាដ៏កក់ក្តៅ។ ហើយខ្ញុំ—ខ្ញុំវាធ្វើឲ្យខ្ញុំមានអារម្មណ៍មិនល្អ ខ្ញុំនិយាយថា "បើខ្ញុំមានកូនផ្ទាល់ខ្លួន ខ្ញុំនឹងធ្វើអ្វីៗសម្រាប់គេតាមតែអាចធ្វើទៅបាន" ល្អ ខ្ញុំសុខចិត្តអត់ឃ្លាន ដើម្បីឲ្យបានអ្វីៗសម្រាប់កូនខ្ញុំ។ ហើយពេលខ្ញុំរស់...ពេលប៊ីលី (Billy) នៅជាក្មេងតូចនៅឡើយខ្ញុំផ្តល់ឲ្យកង់ មានកង់បីដល់គាត់ហើយខ្ញុំផ្តល់ឲ្យគាត់អ្វីៗគ្រប់យ៉ាង។ ហើយមេដា(Meda) ព្យាយាមគ្រប់យ៉ាង ដើម្បីលះបង់ទាំងសម្លៀកបំពាក់របស់នាងនិងអ្វីៗ។ ប៉ុន្តែអ្នកដឹងទេថាយើងរកឃើញយ៉ាងណា? ខ្ញុំផ្តល់កង់កង់បីឲ្យគាត់ហើយមានផ្ទះមួយនិងផ្លែព្រូញ និងអ្វីផ្សេងទៀតខ្ញុំឃើញនៅជាមួយគាត់—ស្លាបព្រាឬចបជីកនៅសួនខាងក្រៅ ជីកអ្វីនៅទីនោះ។ ឃើញ? ខ្ញុំនិយាយ "អ្នកបន្ទាប់ទៀតមិនដូច្នោះឡើយ" ឃើញ? អ្នកអាចឲ្យនរណាម្នាក់នូវអ្វីៗដល់ គេប៉ុន្តែគេមិនត្រូវការ។ វាជាអ្វីដែលអ្នកត្រូវលះបង់!

8 ហើយនោះជារបៀបនៃសេចក្តីសង្គ្រោះដូច្នោះដែរ។ វាជាការលះបង់ទាំងស្រុង។ វាជាបងប្អូនប្រុសរ៉ូយ(Roy)។ វាជា—វាជាការលះបង់ដែលអ្នកត្រូវធ្វើរាល់ថ្ងៃ—ដើម្បីទៅជិតស្និទ្ធិជាមួយព្រះនិងត្រូវធ្វើអ្វីមួយ។ ហើយខ្ញុំដឹងថាវាជាការលះបង់របស់អ្នកទាំងអស់គ្នានៅ ព្រឹកនេះអង្គុយនៅក្នុងអគារក្តៅនេះ។ កាលយើងអង្គុយនៅទីនេះចូររក្សាគំនិតរបស់ យើងលើការលះបង់ធំដែល មនុស្សមិនធ្លាប់ធ្វើ នោះគឺព្រះយេស៊ូវគ្រីស្ទពេលទ្រង់ត្រូវកាត់សេចក្តីឲ្យ មកលើផែនដីដើម្បីសុគតជំនួសយើង។ មិនត្រឹមតែប៉ុណ្ណោះ ប៉ុន្តែព្រលឹងរបស់ទ្រង់ត្រូវចុះទៅស្ថាននរកនិងនៅទីនោះបីថ្ងៃបីយប់ និងនៅថ្ងៃទីបីទ្រង់រស់ឡើងវិញ ហើយឥឡូវត្រូវលើកឡើងគង់ប្រថាប់នៅខាងស្តាំព្រះបិតាដើម្បីទូលអង្វរសម្រាប់ការរំលងរបស់យើងទៅលើការសងថ្លៃរបស់ទ្រង់ និងព្រះគុណរបស់ទ្រង់ដែលប្រទានសម្រាប់យើង។

9 ឥឡូវមកដល់...ដល់កន្លែងយើងត្រូវទៅ នឹងមានមនុស្សជាច្រើន ពិតជាក្រីក្រ ពិតជាក្រីក្រនឹងត្រូវលក់គោមួយរបស់គេចៀម ពីរ ឬបីរបស់ពួកគេ ឬអ្វីៗ ដើម្បីបានមកការប្រជុំគ្នា។ អេសគីម៉ូ (Eskimo) ចាស់ប្រហែលអាចនាំជាមួយនូវស្បែក និងលក់វា ដែលពួកគេត្រូវការសម្រាប់គ្រួសាររបស់ពួកគេ ដើម្បីចេញមក។ ហើយអ្នករកស៊ីជនជាតិឥណ្ឌា ត្រូវធ្វើដូចគ្នា។ ឥឡូវយ៉ាងហោចណាស់ យើងអធិស្ឋានសម្រាប់អ្នកទាំងនោះ អាចទេ? ហើយយើងអធិស្ឋានសម្រាប់ព្រះប្រទានពរឲ្យពួកគេធ្វើកិច្ចការធំ។

10 ឥឡូវវាក្តៅ ខ្ញុំមិនចង់ទុកឲ្យអ្នកនៅយូឡើយ។ ហើយខ្ញុំចង់ឲ្យយើងនៅព្រឹកនេះដើម្បីផ្ទង់គំនិតដូចមុនយើងអធិស្ឋានសម្រាប់អ្នកជំងឺលើ*ក្រុមជំនុំនិងស្ថានភាពរបស់វា*។ ហើយឥឡូវ ខ្ញុំមានអារម្មណ៍ថាពីរបីថ្ងៃកន្លងទៅ សារនោះចំពោះក្រុមជំនុំត្រូវផ្តល់ឲ្យស្រ្វីវផត(Shreveport)ឡូវីសស៊ីណា និងខ្ញុំ—ខ្ញុំជឿថាវាជាលក្ខខ័ណនៃក្រុមជំនុំ។ ហើយយើងនឹងប្រឈមមុខជាមួយព្រះនៅព្រឹកនេះ និងអធិស្ឋាននិងសូមព្រះឲ្យជួយយើង។ កុំគិតតម្រង់ចង់ចូលទៅដូចរបៀបដូចគ្នា ប៉ុន្តែសូមឲ្យព្រះជួយយើងក្នុងថ្ងៃ ដែលយើងរស់នៅ។ និងត្រឹមតែ...នេះជាព្រះគម្ពីរចាស់ ប៉ុន្តែក្នុងនោះមាននូវមាតិកានៃជីវិតអស់កល្ប។

11 ហើយចងចាំថាព្រះបន្ទូលគឺជាព្រះ ព្រះមិនមែនជាអ្វីក្រៅពីព្រះបន្ទូលឡើយ។ ហើយយើងក៏មិនជាអ្វីក្រៅ ពីពាក្យរបស់យើងដែរ ហើយបើយើងធ្វើ...ការសិក្សាឥឡូវ អ្នកនិងខ្ញុំមានជំហរខុសគ្នា...មានវិញ្ញាណដឹង ទាំងអស់គ្នាអាច—យើងអាចនិយាយ "អូ ខ្ញុំនឹងធ្វើអ្វីមួយពិតប្រាកដ" យើងមានន័យពិតក្នុងចិត្ត ប៉ុន្តែកាលៈទេសៈអាចកើតឡើង ដែលយើងមិនអាច—យើងមិនអាចធ្វើអ្វី ដែលយើងនិយាយថាយើងនឹងធ្វើ។ ប៉ុន្តែព្រះមិនអាចធ្វើដូច្នោះឡើយ ព្រោះទ្រង់មិនមានកំណត់ និងទ្រង់ជ្រាបគ្រប់យ៉ាង និងគ្រប់យ៉ាងកាលពីមុន នឹងមក ឬ...ដូច្នេះទ្រង់មិនអាចធ្វើសេចក្តីថ្លែងប្រកាសនូវអ្វី ក្រៅពីអ្វីដែលទ្រង់ជ្រាប ដែលទ្រង់អាចនាំត្រឡប់វិញ។

12 ហើយអ័ប្រាហាំពេលគាត់មានអាយុមួយរយឆ្នាំ គាត់បានហៅអ្វីដែលមិនទាន់មាន ហាក់ដូចជាមានរួចហើយ។ ឥឡូវខ្ញុំនិយាយថានេះជាការលើកទឹកចិត្តដើម្បីឲ្យអស់អ្នកដែលយើងអធិស្ឋានសម្រាប់គេ គឺអ្នកជំងឺ។ អ័ប្រាហាំបានហៅអ្វី ដែលមិនមានហាក់ដូចជាមានហើយ ដោយចាត់ទុកថាអង្គដែលបានសន្យានឹងអាចធ្វើ

វាឡើង ឬ រក្សាអ្វីដែលទ្រង់បានសន្យា។ ឥឡូវពេលព្រះមានបន្ទូលកាន់អ័ប្រាហាំ ពេលគាត់មានអាយុហុក...ចិតសិបប្រាំឆ្នាំ និងសារ៉ាមាន អាយុហុកសិបប្រាំឆ្នាំ ដែលពួកគេនឹងមានកូន ព្រោះ វាជាការសម្រេចទៅបានទាំងអស់គ្នា។ ហើយគាត់ជឿការនោះ និងរង់ចាំកូន និងរាប់កូនថាជាសេចក្ដីល្អត្រង់នោះ ព្រោះមានអាយុចិតសិបប្រាំឆ្នាំមុន នឹងកូនបាកកើតមក។ ហើយអ័ប្រាហាំមានអាយុមួយរយឆ្នាំ ពេលកូនកើតមក និងសារ៉ាមានអាយុកៅសិបឆ្នាំព្រោះគាត់ជឿដល់ទ្រង់។ និងគាត់បានហៅអ្វីដែលមិនមាន ដូចជាមានហើយ។

13 ឥឡូវ នោះសម្រាប់អ្នកជំងឺនិងអ្នករងទុក្ខដែលត្រូវការអធិស្ឋាន។ មិនថាមានអ្វីដែលអ្នកកពុងមានបញ្ហា ថាតើអ្នក...តើជំងឺអ្វីដែលអ្នកមាន តើវាអាក្រក់ប៉ុណ្ណាពេលអ្នកទទួលព្រះគ្រីស្ទ ព្រះបន្ទូលទ្រង់ ដូច្នេះអ្នកអាចហៅអ្វីដែលមាន ដូចជាវាមិនមាន បើសិនជាវានោះប្រឆាំងនឹងព្រះបន្ទូលរបស់ព្រះ។ ឥឡូវ ព្រះមានបន្ទូល "សេចក្ដីអធិស្ឋានដោយជំនឿនឹងជួយអ្នកជំងឺ" ល្អបើព្រះមានបន្ទូលបែបនោះ នោះមានហើយ។ ដូច្នេះចូរដាក់គំនិតយើង សង្ឃឹម និងធ្វើដូចជាវាបានសម្រេចហើយ។ វាបានចប់ហើយពេលយើងទទួលវា។

14 សេចក្ដីសង្គ្រោះគឺរបៀបដូចគ្នា។ យើងជឿវាទទួលវាដាក់ក្នុងចិត្ត ដើរនៅពីមុខព្រះនិងទទួលព្រះគ្រីស្ទជាព្រះសង្គ្រោះផ្ទាល់ខ្លួន និងទទួលទ្រង់។ បើអ្នកនៅទីនេះព្រឹកនេះ ហើយជាមនុស្សមានបាប និងមិនទាន់បានសេចក្ដីសង្គ្រោះ ហើយអ្នកចង់បានការប្រោសឲ្យជា អ្នកកំពុងឈឺ ដំបូងត្រូវរកព្រះអម្ចាស់មុន។ ទទួលទ្រង់ជាព្រះអង្គសង្គ្រោះ ដូច្នេះជំងឺរបស់អ្នកនឹងបានប្រសើរ។ ហើយធ្លាប់ជាអ្វី ដាក់គំនិតអ្នកទាំងស្រុង (គ្រប់យ៉ាងដែលអ្នកមាន)ខ្លួនអ្នកទាំងមូល លើព្រះគ្រីស្ទយេស៊ូវ គ្រប់យ៉ាងនឹងដោះស្រាយបាន។

15 ដូច្នេះឥឡូវរក្សាគំនិតរបស់ អ្នកលើនោះ ព្រោះខ្ញុំនិយាយពាក្យមួយចំនួនទាំងនេះសម្រាប់អ្នកជំងឺ និងរងទុក្ខ ដូច្នេះខ្ញុំនឹងនិយាយនៅព្រឹកនេះពីក្រុមជំនុំ និងស្ថានភាពរបស់វា។ ព្រោះខ្ញុំមានអារម្មណ៍ថាការប្រោសឲ្យជាមកពីព្រះអស្ចារ្យក៏ដោយ ប៉ុន្តែពេលខ្ញុំនៅស្រ៊ីវផត (Shreveport) ខ្ញុំមានកម្មវិធីប្រោសឲ្យជាបីប៉ុណ្ណោះពេលខ្ញុំនៅទីនោះបីឬប្រហែលបួន គឺច្រើនបំផុត ក្នុងរយៈពេលដប់មួយថ្ងៃ។ វាមានភាពចាំបាច់ជាងដែលត្រូវអធិប្បាយដល់ព្រលឹងមនុស្សជាងការចំណាយពេលច្រើនលើ ការប្រោសឲ្យជាមកពីព្រះ។ ទោះបីជាមនុស្សមាន ជំងឺ

និងត្រូវការជំនួយព្រះជាម្ចាស់អាចប្រោសគេ អោយបានជា។ ហើយវាបានបង្ហាញ ជាក់ហើយនៅពិភពលោកជុំវិញ ថាទ្រង់បានធ្វើ។ ប៉ុន្តែរឿងចំបង ឥឡូវ គឺសម្រាប់ ព្រលឹងដែលមិនចេះស្លាប់។ រាងកាយនឹងស្លាប់ ប៉ុន្តែព្រលឹងមិនស្លាប់ឡើយ ហើយ យើងត្រូវរក្សាកម្រិតនិងត្រង់ចំពោះព្រះ។

16 ខ្ញុំតែងនិយាយការនេះ។ ខ្ញុំចង់បានគ្រប់យ៉ាងសម្រេច ព្រោះពេលខ្ញុំទៅទន្លេ ព្រឹកនេះ ខ្ញុំមិនចង់មានបញ្ហានៅទីនោះឡើយ។ ខ្ញុំចង់មានសំបុត្រនៅក្នុងដៃ ចាំ ឈ្មោះរបស់ខ្ញុំ។ ហើយខ្ញុំចង់និយាយដូចជាប៉ូលពីមុន បងប្អូនគ្រីច "ខ្ញុំស្គាល់ គាត់ដោយសារអំណាចនៃការរស់ឡើងវិញ" ពេលទ្រង់បានហៅពីចំណោមមនុស្ស ស្លាប់ ខ្ញុំនឹងចេញមក...ខ្ញុំចង់ស្គាល់ទ្រង់ក្នុងអំណាចនៃការរស់ឡើងវិញ។

17 ដូច្នេះឥឡូវទ្រង់ដែលជាអ្នកនិពន្ធនៃសៀវភៅចូរយើងឱនក្បាលនិង ចិត្តចំពោះ ទ្រង់ពេលនេះមួយភ្លែតចុះ។

18 ហើយព្រះជាព្រះបិតារបស់យើង យើងចូលមកចំពោះទ្រង់ឥឡូវ ដែលទ្រង់ នឹងបើកព្រះបន្ទូលសម្រាប់យើង។ ទូលបង្គំអាច ទាញទំព័រឡើង ប៉ុន្តែមានតែ ព្រះវិញ្ញាណបរិសុទ្ធទេ ដែលអាចបើកព្រះបន្ទូល។ ដូច្នេះសូមបើកនៅព្រឹកនេះ ចំពោះទូលបង្គំ ព្រះបិតាហើយសូមប្រទានព្រះគុណរបស់ទ្រង់កើនជាបរិបូណ៌។ ទូលបង្គំយើងខ្ញុំរង់ចាំទ្រង់។ ហើយសូមឲ្យព្រះវិញ្ញាណបរិសុទ្ធរួមជាមួយព្រះបន្ទូល និងបានរួមគ្នានិងបានផ្តល់មកតាមរយៈបបូរមាត់របស់មនុស្សចូលទៅកាន់ចិត្ត មនុស្ស និងសូមឲ្យទ្រង់ទទួលនិងដាក់នៅ ក្នុងគ្រប់ទាំងចិត្តដូចដែលយើងខ្ញុំ ត្រូវការ។ ហើយពេលកម្មវិធីចប់ទៅ យើងខ្ញុំត្រៀមត្រឡប់ទៅផ្ទះវិញ យើង បន្ទាបខ្លួននិងឱនក្បាល និងថ្វាយដល់ទ្រង់នូវការសរសើរ សម្រាប់អស់ទាំងអ្វី ដែលទូលបង្គំបានរៀនពីទ្រង់និងអ្វីដែលទ្រង់បានធ្វើសម្រាប់យើងខ្ញុំ។ ក្នុងព្រះនាម ព្រះយេស៊ូគ្រីស្ទ។ អាម៉ែន។

19 ការអានព្រះបន្ទូល លើសាវកយ៉ូហាន ជំពូកទីមួយ អ្នកដែលមានព្រះគម្ពីរ និងសូមអានជាមួយខ្ញុំឬកត់ចំណាំអត្ថបទ។ ហើយយើងអានអត្ថបទពីព្រះបន្ទូល បន្ទាប់មកអធិស្ឋានហើយព្រះវិញ្ញាណបរិសុទ្ធនឹងយកអត្ថបទនៃព្រះបន្ទូល សម្រាប់យើង។ យើងអាចអាន យើងដែលជាអ្នកអាចអានបានសូមអានប៉ុន្តែ មានតែព្រះទេដែលអាចនាំយកអត្ថបទចេញមកបាន។ អត្ថបទត្រូវបានអាន ព្រោះវាជាព្រះបន្ទូលរបស់ទ្រង់ ប៉ុន្តែ—អត្ថបទត្រូវបានប្រទានមកពីព្រះ។ ឥឡូវ

នៅក្នុងសាវកយ៉ូហានជំពូកទីមួយនិងចាប់ផ្ដើមនៅខទី28ហើយសូមអានចុះមកខ32រាប់បញ្ចូលផង។

*ឯការទាំងនេះ បានកើតមកនៅភូមិបេថានី ខាងនាយទន្លេយ័រដាន់ ជាកន្លែងដែលយ៉ូហានកំពុងតែធ្វើបុណ្យជ្រមុជទឹក។ ព្រះយេស៊ូវជាកូនចៀមរបស់ព្រះ។*

*...លុះស្អែកឡើង យ៉ូហានឃើញព្រះយេស៊ូវ ដែលទ្រង់កំពុងតែយាងមកឯគាត់ នោះក៏ពោលថា នុ៎ះន៍ កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក។*

*គឺពីព្រះអង្គនេះហើយ ដែលខ្ញុំប្រាប់ថា ក្រោយខ្ញុំមានព្រះ១អង្គយាងមក ដែលបានត្រឡប់ជាមុនខ្ញុំ ដ្បិតទ្រង់គង់នៅមុនខ្ញុំ។*

*ខ្ញុំមិនបានស្គាល់ទ្រង់ទេ តែខ្ញុំមកធ្វើបុណ្យជ្រមុជនេះ គឺដើម្បីនឹងសំដែង ឲ្យសាសន៍អ៊ីស្រាអែលបានស្គាល់ទ្រង់ប៉ុណ្ណោះ។*

*...យ៉ូហានក៏ធ្វើបន្ទាល់ថា ខ្ញុំបានឃើញព្រះវិញ្ញាណយាងចុះពីលើមេឃ មានរូបដូចជាព្រាប មកសណ្ឋិតលើទ្រង់*

ខ្ញុំចង់អានម្តងទៀត ខចុងក្រោយ ខទី32។

*យ៉ូហានក៏ធ្វើបន្ទាល់ថា ខ្ញុំបានឃើញព្រះវិញ្ញាណយាងចុះពីលើមេឃ មានរូបដូចជាព្រាប មកសណ្ឋិតលើទ្រង់*

20 ឥឡូវ សូមឲ្យព្រះអម្ចាស់បន្ថែមព្រះពររបស់ទ្រង់ដល់ព្រះបន្ទូល។ ខ្ញុំចង់ឲ្យអ្នកព្យាយាម—ចាប់យកព្រះបន្ទូលតាមតែអាចធ្វើទៅបាន។ តើអ្នកស្តាប់ឮខ្ញុំទេអ្នកនៅខាងក្រោយ? ត្រូវហើយ តើអ្នកឮខ្ញុំទេនៅខាងក្រោយ? បើអ្នកឮ សូមលើកដៃ។ ល្អណាស់។

21 ឥឡូវខ្ញុំចង់ និយាយទៅកាន់ អ្នកនៅព្រឹកនេះ—ជាប្រស្នា លើរបៀបដែលអាច—អ្នកដែលមិនចូលព្រះវិហារនៅទីនេះក៏អាចយល់បាន។ ឥឡូវ យើងទៅព្រះវិហារដើម្បីឲ្យខ្លួនមានភាពប្រសើរ។ យើងមកដើម្បីឲ្យខ្លួនឯងក្លាយជាមនុស្សប្រសើរ ជាគ្រីស្ទានល្អ ជាពលរដ្ឋល្អ ជាឪពុកល្អ ម្ដាយល្អ អ្នកជិតខាងល្អ។ យើងបានចូលមកដោយព្រោះព្រះគ្រីស្ទបង្គាប់ថាគួរតែមក ទូលសូមអ្វីដោយនូវឈ្មោះទ្រង់ ដែលជាកន្លែងយើងប្រជុំគ្នា មិនថាពីរឬបីនាក់ ទ្រង់នឹងគង់ជាមួយយើងនិងយល់ព្រម

តាមសំណើររបស់យើង។ ដូច្នេះ តើអាចមានអ្វីទៀត មានអ្វីប្រសើរសម្រាប់យើងថ្ងៃនេះជាងអ្វីដែលយើងទៅព្រះវិហារដើម្បីតែធ្វើឲ្យខ្លួនឯងបានប្រសើរ ដើម្បីពង្រីកការយល់ដឹងរបស់យើង? តើប៉ុន្មាននាក់ដែលអាចនិយាយ "នោះជាអ្វីដែលខ្ញុំនៅទីនេះ"? ចូរមើល។ "ខ្ញុំ—ខ្ញុំចង់មានការយល់ដឹងប្រសើរជាងមុន" ហើយយើងមិនអាច—យើងមិនអាច មានការយល់ដឹង ប្រសើរជាងមុនទេ ទាល់តែ...ហើយបើយើងនឹងមានការយល់ដឹងពីព្រះ វាត្រូវតែបានមកពីព្រះបន្ទូលរបស់ព្រះ ព្រោះព្រះបន្ទូលដែលទ្រង់ប្រទានមកយើងគឺ សម្រាប់ចំអែតព្រលឹង ដែលស្រេកឃ្លាន។ ហើយព្រះវិញ្ញាណបរិសុទ្ធ ត្រូវបានបញ្ជូនមក ដើម្បីយកព្រះបន្ទូល របស់ព្រះនិងចំអែតយើងដោយព្រះបន្ទូល។ អ្នកឃើញទេ? ឃើញ យើង...ព្រះវិញ្ញាណបរិសុទ្ធត្រូវបានបញ្ជូនពីព្រះ ដើម្បីយកព្រះបន្ទូលរបស់ព្រះនិងផ្តល់ឲ្យយើងពេលយើងត្រូវការ។ ឥឡូវ ខ្ញុំរីករាយដែលព្រះប្រទានការផ្គត់ផ្គង់បែបនោះ។ តើមិនអ៊ីចឹងឬ? គឺទ្រង់នឹងចំអែតយើង។

22 យើងជាចៀមក្នុង ការឃ្វាលរបស់ទ្រង់។ យើងនឹងនិយាយពី រឿងនោះបន្តិចចៀម។ យើងមានព្រះដែលមានទម្រង់បី ហើយពេលទ្រង់អាច មានការគ្រប់គ្រងពេញលេញ ទ្រង់អាចដឹកនាំ និងនាំមុខយើង។

23 ឥឡូវ វាជាការគាប់ព្រះទ័យដល់ព្រះដែលពេលទ្រង់បញ្ជូនព្រះយេស៊ូវមកលើផែនដី នោះជាការគាប់ព្រះទ័យ ដែលបង្ហាញព្រះអង្គជាសត្វ ហើយសត្វនោះគឺកូនចៀម។ ត្រឡប់ទៅខាងដើមវិញ ក្នុងសួនអេដែន ជាស្រមោលនៃការយាងមករបស់ព្រះយេស៊ូវ ជាយញ្ញបូជារបស់ព្រះ ឬមានកូនចៀមជា តង្វាយសងលោះនៃស្រមោលនៃការយាងមករបស់ព្រះគ្រីស្ទ។ ឥឡូវ ខ្ញុំតែងឆ្ងល់ថាហេតុអ្វីបានជាព្រះបានធ្វើស្រមោលនៃព្រះគ្រីស្ទជាសត្វ ជាសត្វចតុបាត។ ប៉ុន្តែយើងបានរកឃើញថាជាចៀម ហេតុផលដែលទ្រង់រើសសត្វចៀម ចៀមជាសត្វកំសាកនិងសុភាពជាងអ្វីដែលបានបង្កើតមកទាំងអស់លើផែនដី។ គ្មានអ្វីដែលកំសាកនិងសុភាពជាងសត្វចៀមឡើយគឺមិនដឹងអ្វីមិនអាចទ្រទ្រង់ខ្លួនឯងបាន។ វា—វាមិនមានភាពព្រហើន។ វាសុភាព ជាស្នាព្រះហស្តតូចកំសាកមួយ។ ហើយពេលព្រះបានបង្ហាញព្រះគ្រីស្ទមកពិភពលោក ទ្រង់បង្ហាញព្រះអង្គជាសត្វចៀម។

24 ឥឡូវ ប៉ុន្តែពេលព្រះ ព្រះវរបិតា ព្រះយេហូវ៉ា ត្រូវបង្ហាញព្រះអង្គពីស្ថានសួគ៌ទ្រង់បង្ហាញជាភាព សុភាពបំផុត បន្ទាបជាងអស់ទាំងសត្វស្លាបហើរលើមេឃ

នោះគឺ សត្វព្រាប។ គ្មានសត្វបក្សីណាសុភាពជាងសត្វព្រាបឡើយ។ ខ្ញុំបានសិក្សាពីជីវិត សត្វស្លាបនិងសត្វព្រៃ ហើយព្រាបជាសត្វ ចម្លែកពីប្រភេទសត្វហើរលើអាកាស។ ព្រាបជា—ជា—សត្វគួរឲ្យស្រឡាញ់។ ព្រាបមានលក្ខណៈសុភាព។ ហើយព្រាប មិនមានប្រម៉ាត់ឡើយ។ នោះហើយជាមូលហេតុដែលឃើញព្រាបនៅកន្លែងមានតែធញ្ញជាតិប៉ុណ្ណោះ។ ឥឡូវ...

25 ក្នុងទូកធំ មានសត្វព្រាប។ ហើយព្រាបបង្ហាញជាច្រើនកន្លែងក្នុងព្រះគម្ពីរ។ ជានិមិត្តសញ្ញាពីព្រះវិញ្ញាណបរិសុទ្ធ។ ហើយសត្វចៀមក៏បង្ហាញច្រើនកន្លែងក្នុងព្រះគម្ពីរ ជាព្រះគ្រីស្ទ ក្នុងគម្ពីរវិវរណៈ ទៅកាន់គម្ពីរលោកុប្បត្តិ គឺជាសត្វព្រាប។

26 ហើយក្នុងគម្ពីរលោកុប្បត្តិ សត្វព្រាបគឺនៅក្នុងទូក ទុំលើទ្រនុំជាមួយ—ជាមួយនឹងសត្វស្លាបលើអាកាសផ្សេងទៀត ហើយមួយក្នុងចំណោមនោះគឺសត្វក្អែកធំ ក្អែក។ ហើយសត្វក្អែកជាសត្វបក្សីកំណាញ់បំផុតសត្វក្អែកនិងបក្សីចាយ(jaybird) ខ្ញុំទាយ គឺជាសត្វបក្សីកំណាញ់បំផុតដែលយើងរកឃើញ។ ក្អែកជាសត្វដែលមានអាយុវែង ហើយពួកវារស់(ពួកវាអះអាង) ជួនកាល មានអាយុពីរទៅបីរយឆ្នាំ នោះគឺក្អែក...សេកវិញរស់បានយូជាងនោះផង។

27 ប៉ុន្តែសត្វព្រាបជាសត្វមួយ ឬជាបក្សីគ្មានប្រម៉ាត់។ ឥឡូវសត្វក្អែកអាចអង្គុយនៅទីនេះនិង ស៊ីសាកសពងាប់។ អ្នកមិនដែលឃើញ ព្រាបនៅក្បែរសាកសពឡើយ។ វាមិនអាចទ្រាំបានឡើយ។ គឺក្លិនស្អុយនៅច្រមុះវា វាមិនអាចទ្រាំទេ។ វាអាចធ្វើ អោយវាឈឺបាន។ ពួកវាមិនអាចទ្រាំជាមួយអ្វី ដែលរលួយខូចនោះទេ។ ពួកវាមិនអាចទ្រាំបានទេ ដូច្នេះវាមិនអាចស៊ីវាឡើយ។ បើវាស៊ីវា វាអាចធ្វើអោយព្រាបងាប់ភ្លាម ព្រោះអ្វីដែលទំពាររៀងអាហារ គឺវាជ្រុលពេកពីប្រម៉ាត់ទៅក្រពះដែលត្រូវរំលាយអាហារ។ ហើយបើគ្មានប្រម៉ាត់ត្រូវទៅ វានឹងធ្វើឲ្យវាពេញ ដូច្នេះវានឹងធ្វើអោយព្រាបងាប់។ ដូច្នេះអ្នកតែងឃើញព្រាប នៅកន្លែងស្អាត ប៉ុណ្ណោះ អ្វីដែលល្អដល់សុខភាព។

28 ឥឡូវ ក្អែកមានភាពខុសគ្នា។ ឥឡូវសូមសម្គាល់ថា ក្អែកជាប្រភេទមនុស្សកំពុត។ សត្វក្អែកអាចអង្គុយ នៅទីនោះមាន—មានសាកសព ស្លាប់និងស៊ីច្រើនតាមតែវាអាច ហើយក៏ហើរចេញទៅវាលនិងស៊ីស្រូវសាឡីទៀត។ ប៉ុន្តែព្រាបមិនអាចស៊ីស្រូវសាឡីនិងហើយទៅស៊ីសាកសពឡើយ។

29 ដូច្នេះមនុស្សកំពុត មនុស្សអាចជាកំពុត និងអាចបរិភោគបានទាំងពីរអាហារខាងវិញ្ញាណទាំងរបស់ល្អនិងរបស់អាក្រក់។ ប៉ុន្តែគ្រីស្ទបរិស័ទដែលកើតជាថ្មីពិតប្រាកដ មិនអាចទ្រាំនៅជាមួយអ្វីដែលខុសនោះទេ ហើយអាចបរិភោគបានតែរបស់ល្អ។ ចំណាំរឿងនោះ! ពេលអ្នកអាចឃើញមិត្តភ័ក្រដែលអាចទៅរាំ ចេញទៅផឹកចេញទៅរស់ក្នុងបាប ចូលមកក្រុមជំនុំវិញ ហើយអាចស្រែកខ្លាំងដូចជាពួកបរិសុទ្ធដែរ នោះជាអ្វី? គាត់ជាសត្វដើររកអាហារខ្លួនឯងគាត់អាចបរិភោគទាំងរបស់រលួយនិង របស់ល្អ។ ប៉ុន្តែគ្រីស្ទបរិស័ទ ពិតប្រាកដមិនអាចទ្រាំ ជាមួយការនោះទៀតឡើយ ព្រោះគាត់បានឆ្លងពី សេចក្តីស្លាប់មកឯជីវិត។ ហើយវាក៏អាចកាត់ទោសគាត់ផងដែរ គ្រាន់តែមានគំនិតនោះក៏អាចជាការកាត់ទោសដល់គាត់រហូតដល់គាត់ត្រូវបែរ មុខចេញនិងដើរចេញផង។ អូ រូបភាពអីទៅហ្ន!

30 ឥឡូវចៀមមានភាពសុភាពជាមិត្តតូចមួយ។ គាត់មិន គាត់មិនអាចជួយខ្លួនឯងបាន។ គាត់មិនមែនជាអ្នកពឹងខ្លួនឯង ព្រោះគាត់មិនអាចជួយខ្លួនឯង។ ហើយត្រង់នេះមានពេលមួយយូមកហើយ ខ្ញុំធ្លាប់ឃ្វាលពេលខ្ញុំនៅជាមេព្រៃ ហើយខ្ញុំរកឃើញចៀមតូចមួយ ហើយពួកវាផ្សេងទៀតចេញទៅបាត់ពីវា ហើយវាមានស្នាមរបួសដោយសារខ្សែរជុំចុងស្រួច។ ហើយសត្វគួរអោយអាណិតនោះដេកនៅទីនោះ ចេញឈាមនិងស្រែក។ ហើយខ្ញុំចូលមក ខ្ញុំឃើញពីចំងាយប្រហែលកន្លះម៉ាយ ឃើញតែចៀមទាំងមូល។ ឥឡូវ គាត់ជាប់នៅទីនោះហើយក្អែកអាចចឹកយកគ្រាប់ភ្នែកស្អាតរបស់វាឆាប់ៗបើយើងមិនជួយដោះវា។ ប៉ុន្តែខ្ញុំដោះស្នាមរបួសសត្វតូចនេះ លើកដាក់ដៃ។ វាមិនបដិសេធឡើយ។ វាដេកយ៉ាងស្ងៀម។ ខ្ញុំលើកវាឡើងដាក់ក្នុងដៃ។ ដំបូង—ដំបូង ប្រហែល មនុស្សមិនដែលដាក់ដៃលើវាផង ប៉ុន្តែវាសុភាព។ វាមានបំណងឲ្យគេដឹកនាំ។ វាមានបំណងចង់ឲ្យគេជួយ។ ខ្ញុំសង្ឃឹមថាអ្នកនឹងឃើញ។ វានឹងមិនព្យាយាមសាកល្បងប្រឆាំង ឬធាក់ឡើយ ឬខាំ។ ចៀមមិនធាក់តបតពួកវា ក៏មិនខាំដែរពួកវាបន្ទាបខ្លួន។ ហើយសត្វតូចនេះខ្ញុំលើកវាឡើងហើយ ដាក់វាកន្លែងចៀមសម្រាក។ បីបួននាទីមេរបស់វា រកវាឃើញវាសប្បាយចិត្តណាស់! ឥឡូវតើចៀមប្រភេទណាជាចៀមរបស់ព្រះ!

31 អ្នកដឹងថាកន្លែងណាគេសម្លាប់ចៀម អ្នកដឹងទេថាអ្វីនាំចៀមយកទៅកន្លែងសម្លាប់គឺពពែ។ ប៉ុន្តែពពែនឹងនាំចៀមទៅកន្លែង វិនាសនៃកន្លែងសត្វឃាតហើយ

គ្រាន់តែនាំចៀមមកដល់កន្លែងសម្លាប់ភ្លាមវាលោតចេញភ្លាម។ ប៉ុន្តែ អូ ពួកគេ និយាយ ពេលសម្លាប់ពពែម្តងៗវាធាក់ដូចខ្យល់ព្យុះចឹង។ ឃើញ?

32 ហើយនោះជារបៀបដែលពួកអារក្សធ្វើ។ ពួកវាព្យាយាមដឹកនាំកូនរបស់ព្រះ ចូលទៅភាពលំអៀងបំផុត ប៉ុន្តែ ដល់វាត្រូវស្លាប់ ថាក៏រើបំរាស់ឡើង នោះជារបៀប ដែលអារក្សធ្វើ។ ហើយនោះជារបៀបជួនកាល ក្មេងស្រី ស្រស់ស្អាតតូចមួយ ឬ ក្មេងប្រុស ជាមួយកញ្ចប់បារី ឬដបស្រាវីស្គី អាចនាំក្មេងស្រីចេញពីផ្លូវបានដែរ ជា ចៀមនៃក្រោលនរណាម្នាក់ ចេញទៅកន្លែងខុស។"អូវាត្រូវហើយ។ គ្មានអ្វីដែល ល្អ—ល្អពីក្រុមជំនុំទេ។" ប៉ុន្តែចូរឲ្យសេចក្តីស្លាប់វាយក្មេងប្រុសតូចមួយនោះម្តងអ្នក នឹងឮគាត់ស្រែក ស្រែកបង្ហូកពេញប្រទេស។ ហើយនោះជារបៀបអារក្សធ្វើ។

33 ប៉ុន្តែចៀមមានភាពសុភាពណាស់ នោះដែលវាអាចដឹកនាំបាន។ ហើយ នោះជាហេតុផលដែលព្រះបង្ហាញព្រះគ្រីស្ទជាចៀម ហើយទ្រង់ជាព្រាប។ ហើយ នៅថ្ងៃយ៉ូហានជ្រមុជទឹកដល់ព្រះយេស៊ូវនៅទន្លេយ័ដាន់ នោះជាព្រឹត្តិការណ៍ មួយដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រ បានកើតឡើង។ ចំណាំតើចៀមស្អាត យ៉ាងណា! ចៀមសត្វកំសាកបំផុតលើផែនដី និងព្រាប ជាសត្វកំសាកបំផុតនៃ សត្វស្លាបលើអាកាស។ ឥឡូវមានតែរបៀបមួយដែលព្រាបអាចមករកសត្វចៀម បាន។ ឥឡូវ ពេលដែលព្រាបចុះមកយ៉ូហានឃើញព្រះយេស៊ូវហើយនិយាយថា "មើលកូនចៀមនៃព្រះដែលដោះ បាបមនុស្សលោក" រួចលោកយ៉ូហាននិយាយ "យ៉ូហានក៏ធ្វើបន្ទាល់ថា ខ្ញុំបានឃើញព្រះវិញ្ញាណយាងចុះពីលើមេឃ មានរូប ដូចជាព្រាប មកសណ្ឋិតលើទ្រង់" ហាលេលូយ៉ា! នោះគឺអ្នក។ ចៀមនិងព្រាបបាន រួមចូលគ្នា។ ពេលដែលព្រះនិងមនុស្សរួមជាមួយគ្នា។ នោះជាពេលដែលផែនដី និងស្ថានសួគ៌អោបផ្តុំគ្នា។ ហាលេលូយ៉ា! នោះជាពេលព្រះក្លាយជាសាច់ឈាម នាំមក នោះជាពេលដែលព្រះយាងចុះមក ជាទម្រង់វិញ្ញាណនិងកើត ជាមនុស្ស និងរស់នៅក្នុងចំណោមយើង។ នោះជាពេលដែលភាពអស់ កល្បក្តោបចូលគ្នា ទៅវិញទៅមក។ នោះជាពេលជាតិមនុស្ស ដែលធ្លាក់ចុះនៃមនុស្ស របស់អ័ដាំនិង ព្រះយេហូវ៉ានិងទេវតាទាំងអស់បាន ចូលមកជាមួយគ្នា ពេលដែលព្រះនិងមនុស្ស បានក្លាយជារួមតែមួយ ជាថ្ងៃគួរ ចងចាំមួយដ៏ធំជាពេលយ៉ូហានជ្រមុជទឹកដល់ ព្រះយេស៊ូវ។

ឥឡូវ ចុះបើគេមានចចកនោះយ៉ាងណាវិញ? ភាពផ្អែមល្ហែមនៃការថ្ងូរបស់សត្វព្រាបមិនអាចនៅក្បែរចចកឡើយ។

34 អ្វីទៅដែលល្អជាងពេលល្ងាចដែល ពព្រាបអណ្តើកអង្គុយ និងស្រែកថ្ងូរ? បន្ទាប់ពីខ្ញុំបាត់ប្រពន្ធនិងកូន...ខ្ញុំមិនអនុញ្ញាតិ ឲ្យនរណាម្នាក់ដឹងថាខ្ញុំកំពុងធ្វើអ្វីឡើយ។ ខ្ញុំធ្លាប់នៅក្នុងឡានចាស់របស់ខ្ញុំ ខ្ញុំបានបើកឆ្លងផ្លូវនៅទីនេះ ចេញទៅនៅតាមវាលផ្នូរវ៉លនុតរីដ(Walnut Ridge)អង្គុយនៅទីនោះក្បែរដើមឈើនិងមើលមកផ្នូរ។ ខ្ញុំមិនអាចបោះបង់ពួកគេឡើយ។ ហាក់ដូចជាខ្ញុំមិនអាចតស៊ូទៀតបានឡើយ។ ខ្ញុំគិតកូនតូចរបស់ខ្ញុំដេកនៅទីនោះ អាយុប្រាំបីខែ។ នឹកពីរបៀបនាងទប់ដៃរបស់នាង ឈោងមករកខ្ញុំ ហើយខ្ញុំផ្តុំស្នែងឬនិយាយអ្វីទៅនាង ហើយនាងធ្វើ "ហ្គោ—ហ្គោ" ហុចដៃតូចរបស់នាងមក។ ហើយខ្ញុំអង្គុយក្បែរដើមឈើ ជាពិសេសពេលល្ងាច។ ហើយទីនោះធ្លាប់មានព្រាបចាស់មួយអង្គុយនៅក្បែរគម្ពោតព្រៃនៅទីនោះ វាក៏ថ្ងូរដែរ។ អូ ខ្ញុំអើយ! ខ្ញុំធ្លាប់ឆ្ងល់ថា តើមានព្រលឹងអមតៈនៃកូនរបស់ខ្ញុំត្រឡប់មកវិញព្យាយាមជាមួយខ្ញុំ។ គ្មានអ្វីដែលផ្អែមល្ហែមជាងសម្លេងថ្ងូរបស់ព្រាបឡើយ។ វាគួរឲ្យស្រឡាញ់! វានាំដំណឹងមក។ របៀបដែលវាព្យាយាមនាំសេចក្តីសុខសាន្ត! ក្រោកពីព្រលឹម ចេញទៅក្នុងគម្ពោតព្រៃស្ដាប់ទីនោះក្បែរកន្លែងខ្ញុំរស់នៅ វាជាសន្តិភាពណាស់ដែលបានស្តាប់! អង្គុយលើដើមឈើខ្ពស់នោះ ព្រាបទាំងនោះថ្ងូរដាក់គ្នាទៅវិញទៅមក។

35 នៅថ្ងៃមួយ នៅជាមួយបងប្អូនប្រុសខ៍ច (Cox) មេព្រាបចាស់មួយមានកូនពីរក្បាល។ ហើយពួកគេអង្គុយនៅកំពូលអាគារ ដូច្នេះឆ្មាមិនអាចចាប់ពួកគេបានឡើយ។ ហើយមេព្រាបចាស់ឲ្យចំណីពួកវា។ រួចវាចុះមកនិងនាំពួកវា ទៅលើដើមឈើវិញ ហើយពួកវាអង្គុយនៅទីនោះ ថ្ពក់កគ្នាទៅវិញទៅមកនិងថ្ងូរ ហើយបង្កើតសេចក្តីស្រឡាញ់ ពេញមួយថ្ងៃ មានពីរតូចៗ ជាព្រាបសុភាព។

36 ហើយខ្ញុំគិតពីរបៀបដែលព្រះ(ព្រាបជាសត្វគួរឲ្យស្រឡាញ់) និងព្រាបព្រះចង់ បង្កើតសេចក្តីស្រឡាញ់ ជាមួយមនុស្សជាតិរបស់ទ្រង់។ ព្រះចង់ទទួលការស្រឡាញ់។ ព្រះស្រឡាញ់អ្នក។ "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះបានជាទ្រង់ប្រទាន ព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ" ព្រះអម្ចាស់ដ៏មានពរ! ដូច្នេះព្រះចង់បង្កើតការស្រឡាញ់ទ្រង់ធ្លាប់...ធ្វើអ្វី

ជាទីស្រឡាញ់។ ទ្រង់ធ្លាប់បង្កើតអ្វីដែលសុភាពដូចជាទ្រង់។ ទ្រង់ធ្លាប់បង្កើតអ្វីដែលអាចទទួលការស្រឡាញ់។ ទ្រង់ធ្លាប់បង្កើតអ្វីជានិស្ស័យរបស់ទ្រង់ផ្ទាល់។

37 អ្នកមិនអាចស្រឡាញ់អ្វី ដែលមិនមែនជានិស្ស័យរបស់អ្នកផ្ទាល់។ សេចក្ដីស្រឡាញ់ត្រូវរួមគ្នាជាមួយការស្រឡាញ់។ ប្ដីនិងប្រពន្ធត្រូវស្រឡាញ់គ្នាទៅវិញទៅមក ពួកគេមិនដែលដាក់កម្រិតឡើយ។ គ្រួសារត្រូវស្រឡាញ់គ្នា មិនមានកម្រិតឡើយ។ មានអ្វីត្រូវតែមានការស្រឡាញ់! អ្នកស្វែងរកគ្រប់កន្លែងដើម្បីរកស្រីណាម្នាក់ធ្វើជាប្រពន្ធដែលអ្នកស្រឡាញ់។ នាងស្វែងរកប្ដីដែលនាងស្រឡាញ់។

38 ព្រះស្វែងរកនិងសាកល្បងព្រលឹងដែលទ្រង់អាចស្រឡាញ់។ ដូច្នេះទ្រង់បានបង្ហាញព្រះអង្គ ទ្រង់ត្រង់នេះលើផែនដី ជាព្រាបសុភាពនិងជាចៀមសុភាព។ បើសិនជាសត្វចៀមនោះ អាចយកចេញបានមួយនាទីជា និស្ស័យចចកដែលគ្រហឹម សត្វព្រាបនោះនឹងហើរចេញភ្លាម នាងត្រូវចេញឆ្ងាយ។

39 ប៉ុន្តែសត្វ—សត្វ—សត្វចៀម មិនមានគំនិតធំណាជារបស់ខ្លួនឡើយ។ សត្វចៀមមានការមួយ ពេលវាវង្វេង វាវង្វេងដោយគ្មានសង្ឃឹម។ ចៀមមិនអាចរកវិធីត្រឡប់ទៅវិញឡើយ។ នោះហើយជាហេតុផល ដែលពពែនាំវាទៅរកសេចក្ដីស្លាប់។ វាមិនអាចរកផ្លូវដោយខ្លួនឯង ចៀមនោះគឺវង្វេងយើងជាមនុស្សវង្វេង។ គ្មានផ្លូវដែលយើងអាចរកខ្លួនឯងឃើញឡើយ។ ហើយមានផ្លូវតែមួយដែលអាចធ្វើបាន នោះគឺ ចុះចូលខ្លួនយើងជាមួយអ្នកគង្វាលហ្វូងចៀម ហើយលោកនឹងធ្វើការដឹកនាំ។

40 ឥឡូវ កាលបើខ្ញុំសម្គាល់ចៀមនេះនិងចៀមផ្សេងទៀតនៅជាមួយគ្នា...ចៀមនិងព្រាប គួរតែនៅរួមគ្នាតែមួយ។ រួចពិនិត្យមើលរបៀបសត្វព្រាបដឹកនាំចៀម ជាព្រះបុត្រារបស់ព្រះ។ តើទ្រង់សុភាពប៉ុណ្ណា ទោះបីដឹងថាទ្រង់ត្រូវនាំយកទៅសម្លាប់ក៏ដោយ។ តើទ្រង់សុភាពប៉ុណ្ណា មិនព្យាយាមធ្វើអ្វីតាមព្រះហឫទ័យទ្រង់ ឡើយ មិនព្យាយាមផ្គាប់ចិត្តខ្លួនឡើយ។ ទ្រង់មានបន្ទូល "ខ្ញុំមិនអាចធ្វើអ្វីបាន លើកតែព្រះវរបិតាបង្ហាញខ្ញុំមុន ហើយព្រះវរបិតាគង់ក្នុងខ្ញុំ"។

41 ឥឡូវ មានភាពផ្សេងទៀតនៃចៀម ចៀមមានឆន្ទៈចុះចូលសិទ្ធិរបស់វា។ ឥឡូវព្រះសព្វព្រះទ័យឲ្យយើងធ្វើជាចៀម ប៉ុន្តែមានពេលជាច្រើនយើងមិនចុះចូលសិទ្ធិរបស់យើង ចុះញ៉មសិទ្ធិរបស់យើង។ ក្នុងចំនោមអ្នករាល់គ្នាខ្លះនិយាយថា "ចឹង ខ្ញុំ

មាន សិទ្ធដែរឬ បងប្រុសប្រាណហាំ"។ ពិតណាស់ ប៉ុន្តែ តើអ្នកស្ម័គ្រចិត្តចុះចូលសិទ្ធិរបស់អ្នកឬទេ? តើអ្នកស្ម័គ្រចិត្តផ្តល់សិទ្ធរបស់អ្នកឲ្យព្រះដឹកនាំដែរឬទេ? នោះជាបញ្ហារបស់ក្រុមជំនុំសព្វថ្ងៃ ក្នុងភាពសំខាន់មួយ ជាភាពសុភាពរបស់ចៀមនៃព្រះ...យើងត្រូវធ្វើជាចៀម យើងមិនមែនជាអ្វី ទៀតក្រៅពីចៀមឡើយ។ ហើយនោះជាហេតុផលដរាបណាទាល់តែយើងមានលក្ខណៈ បែបនោះបើមិនដូច្នោះ ព្រាបនៃព្រះវិញ្ញាណបរិសុទ្ធនឹងហើរចេញ។

42 បើសិនជាចៀមរបស់ព្រះចាប់ផ្តើមគ្រហឹមដូចជាចចក ឬធ្វើអ្វីដែលបញ្រ្ចាសពីអ្វីដែលជាសត្វព្រាបសុភាពដែលអនុញ្ញាតិ សត្វព្រាបអាចនឹងហើរចេញ។ នាងអាចហើរចេញភ្លាមៗ។

43 ហើយនោះជាហេតុផលថ្ងៃនេះដែលយើងឆ្ងល់ "មានអ្វីកើតឡើងជាមួយក្រុមជំនុំពេនតេកុស្ត?"គឺដោយព្រោះយើងចាប់យកនិស្ស័យប្លែកផ្សេង។ "យើងចង់បានសិទ្ធិរបស់យើង។ យើងធ្វើអ្វី ដែលយើងយល់ថាត្រូវ" បែរជាយើងក្លាយជាមនុស្សព្រហើន។ យើងក្លាយជាសត្រូវ។ យើងក្លាយជាផ្លាស់ប្តូរ។ យើងអនុញ្ញាតិឲ្យកំហឹងចូលមក។ យើងអនុញ្ញាតិឲ្យភាពអាត្មានិយមចូលមក។

44 ចៀម ពេលដល់វេលា...គាត់មានរោមផ្ទាល់ខ្លួននោះ ជាសិទ្ធិរបស់គាត់ជាចៀម។ គាត់មានរោម ប៉ុន្តែវាបានធ្វើឲ្យចៀមធ្លាក់ចូលក្នុងភាពរាំងស្ទះ និងចងជើងជាប់។ គាត់មិនដែលទាត់ មិនដែលស្រែក។ អ្នកអាចយកសិទ្ធិរបស់គាត់ចេញព្រោះគាត់ជាចៀម។ គាត់មិនអាចធ្វើអ្វីផ្សេងទៀតឡើយ ព្រោះនោះជានិស្ស័យរបស់លោក។ ប៉ុន្តែមានពេលមួយឆ្លងកាត់ផ្លូវរបស់ព្រះគ្រីស្ទ អ្នកនឹងឃើញថាគាត់ជាចៀមឬពពែ។ អ្នកនឹងរកឃើញថាគាត់ជាអ្វី ឆ្កាងគាត់បានម្តង។ ហើយនោះជាហេតុផលដែលក្រុមជំនុំនៅក្នុងលក្ខខ័ណយើងនោះ។

45 យើងហៅខ្លួនឯងថា ជាចៀមរបស់ព្រះ។ ស្ត្រីនិងបុរសទាំងអស់មិនសម្តែងជាអ្វីក្រៅពីចៀមរបស់ព្រះ។ អ្នកមើលគេដើរតាមផ្លូវវិញ ជាមួយសំពត់ខ្លី សក់ខ្លីរួញពេញក្បាល។ ហើយពីរបីឆ្នាំកន្លង អ្នកហៅ...អ្នក ពួកគេ...អ្នកមិនបាច់ជួលគេឲ្យធ្វើបែបនោះឡើយ។ ហើយអ្នកឆ្ងល់ថាហេតុអ្វីបានជាក្រុមជំនុំស្ថិតក្នុងស្ថានភាពបែបនេះ។ ពីព្រោះតែអ្នកចាប់យកនិស្ស័យជាចចក ឬពពែ ជំនួសឲ្យភាពសុភាពស្លូតបូត។ ហើយអ្នកនិយាយ"នោះជាឯកសិទ្ធិរបស់ខ្ញុំបងប្រុសប្រាណហាំ" ខ្ញុំដឹងថាជាសិទ្ធិរបស់អ្នក។ "ជាងកាត់សក់កាត់សក់។ ទោះជាងកាត់សក់

កាត់សក់យ៉ាងម៉េចក៏ជាសិទ្ធរបស់ខ្ញុំដែរមែនទេ?" ត្រូវហើយ នោះជាសិទ្ធិរបស់អ្នកជាជនជាតិអាមេរិក។ ប៉ុន្តែតើអ្នកស្ម័គ្រចិត្តបោះបង់វា ឲ្យក្លាយជាចៀមឬទេ? តើអ្នកស្ម័គ្រចិត្តចុះចូលដែរឬទេ?

46 ហើយអ្នកជាស្ត្រី មិនជាយូប៉ុន្មានឡើយ អ្នកដើរតាមផ្លូវ...វាជាការគួរភ្ញាក់ផ្អើលណាស់ បើយើងមើលទៅការស្លៀកពាក់របស់ស្ត្រីបច្ចុប្បន្ន។ ហើយខ្ញុំមិននិយាយពីប្រីសប៊ីធីរៀន និងមេតូឌីសឡើយ ខ្ញុំនិយាយពីអ្នកដែលជាស្ត្រីបរិសុទ្ធ។ ទៅតាមផ្លូវនិងវាជា...

47 ខ្ញុំមានឈើឆ្កាងព្យួរពីមុខឡានរបស់ខ្ញុំ និងមានគេនិយាយមកកាន់ខ្ញុំថា "ប៊ីលី(Billy) អ្នកដឹងទេថានោះជាបដិរូបកាតូលិក?"

48 ខ្ញុំនិយាយ "ពេលណាដែលកាតូលិកមានជម្រើសជាឈើឆ្កាង?" មិនដែលឡើយ! នោះមិនមែនជាបដិរូបនៃជំនឿកាតូលិកឡើយ នោះជាបដិរូបជំនឿគ្រីស្ទបរិស័ទ។ ជំនឿកាតូលិកជាពួកបរិសុទ្ធស្លាប់តូចមួយ ជាម៉ារីឬ—ឬរបៀបមនុស្សស្លាប់ដែលថ្វាយបង្គំ។ យើងមិនថ្វាយបង្គំមនុស្សស្លាប់ឡើយ។ យើងមិនថ្វាយបង្គំសាវកសេស៊ីលីយា(Cecilia)និងពួកសាវកផ្សេងៗទាំងនោះឡើយ។ នោះជាកាតូលិកនិយមដែលជាទម្រង់ខ្ពស់មួយនៃវិញ្ញាណនិយម។ ប៉ុន្តែឈើឆ្កាងជាការ តំណាងអង្គដែលសុគតនិងរស់ឡើងវិញ។

49 ហើយខ្ញុំនិយាយ "ខ្ញុំរក្សានៅត្រង់នោះ មើលតាមផ្លូវ ម្ភៃប្រាំឆ្នាំកន្លងទៅឬសាមសិប ពេលខ្ញុំស្ទើរតែងងិតភ្នែកទៅហើយ។ ខ្ញុំសន្យាជាមួយព្រះថាបើទ្រង់ព្យាបាលភ្នែករបស់ខ្ញុំ ខ្ញុំនឹងសម្លឹងមើលអ្វីដែលត្រឹមត្រូវប៉ុណ្ណោះ"។ ហើយខ្ញុំនិយាយ "គ្រប់កន្លែងដែលអ្នកមើល វាមិនមានភាពមិនល្អឡើយ ស្ត្រីស្លៀកពាក់តែពាក់កណ្តាល និងស្ត្រីស្រាតដេកតាមវាលស្មួនគ្រប់កន្លែង។ ខ្ញុំមើលទៅឈើឆ្កាងជំនួសឲ្យមើល (ហើយចាំថាព្រះគ្រីស្ទធ្វើសម្រាប់ខ្ញុំ និងបង្វែរក្បាលរបស់ខ្ញុំ) ទៅអារក្ស។" ហាលេលូយ៉ា!

50 ហើយនោះជាមនុស្ស...កុំនិយាយថា "ព្រីសប៊ីធើរៀន កាតូលិក" នោះជាពេនទីកុស្ត! អាម៉ែន។ អ្នកនិយាយ "ខ្ញុំមានសិទ្ធិបងប្រុសប្រាណហាំ" ត្រូវហើយ ប៉ុន្តែបើអ្នកជាចៀម អ្នកនឹងចុះញម សិទ្ធិរបស់អ្នក។ ហើយពេលអ្នកសម្តែងបែបនោះ ព្រះវិញ្ញាណបរិសុទ្ធជាព្រាបសុភាព ចាប់ដំណើរហើររបស់នាង។ នាងមិននៅអាប់ឱនជាមួយអ្នកឡើយ។ ទេ ទេ ទេ។ អ្នកមិនអាចគិតថា អ្នកធ្វើបែប

នោះហើយព្រះវិញ្ញាណគង់ជាមួយឡើយ។ អ្នកមិនអាចធ្វើវាដូច្នេះឡើយ! ព្រះគម្ពីរនិយាយដូច្នេះ។ អ្នកត្រូវចុះញមសិទ្ធិរបស់អ្នក...ល្អ និយាយ "ស្ត្រីទាំងអស់គឺធ្វើវាហើយ"។

51 ហើយអ្នកជាមនុស្សប្រុស អ្នកក្រីក្រ តូចល្អិត អត់ឆ្អឹង ជារបស់ទន់ជ្រាយ អ្នកអនុញ្ញាតិឲ្យប្រពន្ធធ្វើបែបនោះ នោះបង្ហាញថាអ្នកបង្កើតពីអ្វី នោះជាហេតុផលដែលអ្នកមិនមានព្រះវិញ្ញាណបរិសុទ្ធដូចដែលអ្នកធ្លាប់មាន ឬអ្នកមានអ្វីគ្រប់គ្រាន់សម្រាប់ឲ្យនាងល្មមនឹងសម្តែងបែបស្ត្រីពេលនាងនៅជាមួយអ្នកទៀតឬរបៀបណាក៏ដោយ។ អាម៉ែន។ ស្តាប់ទៅដូចជាម៉ូដចាស់ កាត់។ ប៉ុន្តែនោះជាអ្វីដែលក្រុមជំនុំត្រូវមាននាបច្ចុប្បន្ន គឺម៉ូដចាស់ ព្រះវិញ្ញាណបរិសុទ្ធសំអាត ព្យួរខាងក្រៅ សំងួត និងអ៊ុត ដោយព្រះវិញ្ញាណបរិសុទ្ធ។ ប្រាកដណាស់!

52 តើស្ថានភាពអ្វីដែលលោកិយកំពុងស្ថិតនៅ! របៀបដែលគេទៅតាមផ្លូវហើយបន្តធ្វើ! ការដែលក្បាលរបស់អ្នកនៅតែនឹងទូរទស្សន៍នៅថ្ងៃពុធ ហើយមិនទៅព្រះវិហារ! របៀបដែលអ្នក...ហេតុអ្វី ប៉ុន្តែវាមិនខុសអ្វីពីក្មេង នៅជនបទ...ដែលស្គាល់ពីដាវីឌក្រូកឃីត(David Crockett)។ ហើយនោះជាការកុហកដ៏កខ្វក់និយាយថាគាត់សម្លាប់ខ្លាឃ្មុំនៅអាយុបីឆ្នាំ អ្នកដឹងទេថានោះជាការកុហក ប៉ុន្តែអ្នកអនុញ្ញាតិឲ្យកូនៗរបស់អ្នកជាប់គំនិតក្នុងការនោះ។ ហើយ មិនមានសូម្បីមួយភាគរយដែលស្គាល់ពីព្រះយេស៊ូវគ្រីស្ទផង។ គឺក្លាយជាលោកកិយ៍នេះពេញដោយការកខ្វក់! ប្រជាជាតិនេះគួរឲ្យអស់សំណើចណាស់នៅឆ្ងាយពីព្រះបានបដិសេធព្រះវិញ្ញាណបរិសុទ្ធ។

53 អូ អ្នកនិយាយ "ខ្ញុំទៅព្រះវិហារហើយស្រែក"។ អ្នកអាចធ្វើបែបនោះ។ ប៉ុន្តែរហូតដល់ចៀមសុភាពរបស់ព្រះតាំងនៅក្នុងចិត្តរបស់អ្នក និង សំអាតជីវិតរបស់អ្នកនិងសម្តែងជាមនុស្សផ្សេងវានឹងមិនមានភាពល្អឲ្យអ្នកគ្រាន់តែត្រាប់តាមគ្រីស្ទានឡើយ។ អ្នកត្រូវតែមាន។ អាម៉ែន។

54 ខ្ញុំបានទៅផ្ទះនៅទីនេះ មិនជាយូប៉ុន្មានទេ ដើម្បីសួរសុខទុក្ខអ្នកជំងឺ ហើយមានស្ត្រីម្នាក់ដេកនៅទីនោះ អង្គុយទីនោះ។ ហើយក្មេងប្រុសអូស្វាល(Oswald) បានចូលមកបានអង្គុយនៅចំហៀងក្បាលរបស់គាត់ និយាយ "ម៉ាក់ តើអាហារល្ងាចរៀបចំរួចឬនៅ?"

55 នាងនិយាយ "កូនសម្លាញ់ យើងមិនមានពេលទេ" និយាយ "ព្រឹកនេះ ដើម្បីទទួលអាហារល្ងាច" និយាយ"ខ្ញុំនឹងរៀបចំសាន់វិចឲ្យអ្នក"និយាយ "មានក្រូចខ្លះ"។

56 គាត់ដើរទៅរួចយកក្រូច មួយមើលទៅវា ខាំវា គប់វាទៅលើជញ្ជាំងយ៉ាងខ្លាំង ទឹកក្រូចស្រក់ហៀរចុះនិយាយ "បើនេះជាអ្វីដែលអ្នកមាននៅកន្លែងនេះ ដូច្នេះខ្ញុំទៅហើយ" បែបនេះ។

57 ខ្ញុំនិយាយ "អូ ព្រះអង្គអើយ គាត់គួរតែនៅជាមួយខ្ញុំត្រឹម ប្រាំនាទី!" ក្មេងប្រុសខ្ញុំរុញការលាក់ពុតចេញមកដូចជាគាត់មិនធ្លាប់ដឹង រុញចេញមក! ប៉ុន្តែវាលាក់ត្រង់នោះអាណិតទារក។ អ្វីដែលគាត់ត្រូវការ គឺស្បែកម៉ូដចាស់ល្អមួយ។ នោះជាអ្វីយើងត្រូវការ ផ្ទះម៉ូដចាស់ទៀតហើយ និងគ្រូអធិប្បាយដែលឈរក្បែរអាសនានិងអធិប្បាយសេចក្តីពិត និងផ្តេកវាកន្លែងដែលវានៅ។ អាម៉ែន។ នោះជាការពិត។ អូខ្ញុំអើយ!

58 ម៉ារីតូចទន្ទ្រាំជើងនាង និងបាស់ច្រមុះឡើង និងមានបបូរមាត់ឡើងក្រហម (ដោយរបស់របរម៉ាកហ្វេកទ័រ)លើអាកាស និង ក្បាលងើបបន្តិចដើរចេញពីផ្ទះ។ មើលទៅអីក៏អាប់ឱនម្លេះ! តើកូនអីក៏មិនស្តាប់បង្គាប់សោះ! ព្រះគម្ពីរនិយាយពួកគេគួរតែស្តាប់បង្គាប់។ ខគម្ពីរនិយាយថាគេគួរតែស្តាប់បង្គាប់។ របៀបដែលគេប្រព្រឹត្តិអ្វីដែលគេធ្វើ និងតើអ្វីដែលកើតឡើងក្នុងពិភពលោកសព្វថ្ងៃនេះ គឺព្រោះពួកគេធ្វើឲ្យព្រះវិញ្ញាណព្រួយព្រះទ័យ។

59 បីបួនឆ្នាំមុន។ ខ្ញុំនឹងទៅឥឡូវក្នុងបីបួនថ្ងៃនេះ ប្រារព្ធពិធីការធ្លាក់ចុះមកនៃព្រះវិញ្ញាណបរិសុទ្ធលើកដំបូងនៅអាមេរិកឆ្នាំនេះត្រូវជាហាសិបឆ្នាំកន្លងហើយ ការជួបជុំនៅផ្លូវអាស៊ូសាចាស់ជាការជួបជុំពេនទីកុស្តនៅឡូសអេនចេលេស ជាកន្លែងដែលមានការចុះមកនៃ ព្រះវិញ្ញាណបរិសុទ្ធលើកដំបូង ពេលដែលមនុស្សមកជុំគ្នា។ ពេលព្រះគ្រីស្ទចុះមកចំណោមមនុស្សទាំងនោះ ពួកគេមានចិត្តសុភាពមានសន្តិភាព។ ពួកគេរស់នៅជីវិតកោតខ្លាចព្រះ។ ពួកគេរស់នៅជីវិតលះបង់។ ពួកគេមានបំណងឆន្ទៈ ក្នុងការដាក់ចូល។ ពួកគេមានបំណង ឲ្យមានការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ។ ពួកគេមិនខ្វល់ថាគេនិយាយអ្វី ពួកគេជា "ម៉ូដចាស់" មិនថាគេនិយាយថាពួកគេ "ឆ្កួត" ឬអ្វីបែបនោះ ពួកគេមានបំណងឲ្យមានការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ។

60 ប៉ុន្តែ សព្វថ្ងៃ អូ ខ្ញុំអើយ ជាមួយនឹងម្សៅនិងគ្រឿងតុបតែងមុខ ជាមួយនឹងខោខ្លីៗ ចេញតាមផ្លូវ ហេតុអ្វី វាជាភាពអាប់ឱន! ហើយហៅខ្លួនឯងថា "មានព្រះវិញ្ញាណបរិសុទ្ធ" អូ អ្នកនិយាយ "ប៉ុន្តែខ្ញុំនិយាយភាសាដទៃ។" បាទ ហើយអារក្សក៏ធ្វើចឹងដែរ។ "អូ ខ្ញុំស្រែក" អារក្សក៏ស្រែកដែរ។ អារក្សអាចត្រាប់តាមគ្រប់យ៉ាងដែលព្រះមាន លើកលែងតែសេចក្ដីស្រឡាញ់ ហើយវាមិនអាចត្រាប់តាមសេចក្ដីស្រឡាញ់ឡើយ។ មែន។

61 ដូច្នេះ អ្វីទីមួយអ្នកដឹងទេ ពេលអ្នកចាប់ផ្ដើមធ្វើអ្វីទាំងនោះអ្នកដាក់របាចុះអ្នកចាប់ផ្ដើមចុះចូល ដូច្នេះក្រុមជំនុំក្លាយជាមាន់ក្រុកៗ ចូលបក្សជាមួយគេ ហើយនេះនិយាយ "អ្នកដឹងទេថាគ្រូគង្វាលនិយាយ *ដូចនេះ—និង—ដូចនេះ*" ឬ "ពួកចាស់ទុំ *ដូចនេះ—និង—ដូចនេះ*។" ហើយសេចក្ដីដំបូងដែលអ្នកដឹងអ្នកស្ដាប់តាម! នោះជាហេតុផលដែលយើងមានបញ្ហាខ្លាំង ព្រោះអ្នកចាប់ផ្ដើមស្ដាប់តាមអារក្សនឹងចាប់គ្រហឹមជំនួសឲ្យស្ដាប់ព្រាបដែលសុភាព ជាព្រះវិញ្ញាណបរិសុទ្ធ ព្រាបរបស់ព្រះដែលអាចនាំអ្នកនិងដឹកនាំអ្នក ស្រឡាញ់អ្នកនិងប្រទានពរអ្នក។

62 ពីដំបូងអ្នកក៏មានកំហឹងក្នុងចំណោមនោះដែរ ព្រាមបានហើរចេញពីអ្នក។ គឺអ៊ីចឹង។ នាងមិនអាចទ្រាំបាន។ និស្ស័យរបស់នាងគឺផ្សេងពីគេ។ អូ នាងមិនអាចទ្រាំបានទៀតឡើយ។ ព្រោះអ្នកបាននិយាយពីអ្នកជិតខាងរបស់អ្នក នាងមិនអាចទ្រាំបាន នាងមិនអាចទ្រាំក្នុងចិត្តបាន។ គាត់គ្រាន់តែហើរចេញ។ គាត់មិនអាចទ្រាំបានទៀតឡើយ។ ព្រាបគឺសុភាព។ សត្វព្រាបស្លូតបូតហើយសត្វព្រាប ហើយ—ហើយវាមិនអាចទ្រាំបានទេលុះត្រាតែប្រភេទនិស្ស័យដូចគ្នា។

63 ឥឡូវព្រះអាចធ្វើឲ្យអ្នកមាននិស្ស័យផ្សេងបានមិនថាមនុស្សប្រុសឬស្រី ទ្រង់អាចប្រទានឲ្យអ្នកនិស្ស័យផ្សេងមួយ។ហើយអ្នកនិយាយ "ចឹងបងប្រុសប្រាណហាំ តើយើងអាចធ្វើអ្វីពីវា?" គ្រាន់តែធ្វើជាចៀមម្ដងទៀត។ វាជាសត្វពីរដែលនឹងរួមជាមួយគ្នានោះជាព្រាបនិងចៀម។ ព្រាបមិនទៅកន្លែងណាទៀតក្រៅពីចៀមឡើយ។ ហើយបើអ្នកក្លាយជាសត្វពពែ ដូច្នេះយកវិញ្ញាណសត្វពពែចាស់នោះចេញពីអ្នក។ ហ្នឹងហើយ។ បើអ្នកក្លាយជាអ្វីទៀតយកវាចេញពីអ្នកបើអ្នកនិងមានពេលក្រោយ។

64 ទីនេះមានពេលមួយ ខ្ញុំអធិប្បាយខំប្រឹងតាមតែអាចធ្វើទៅបានក្នុងក្រុងមួយហើយមានមនុស្ស រាប់ពាន់នាក់នៅទីនោះ។ ខ្ញុំបានហៅមនុស្សមកអាសនា។ ខ្ញុំ

គិតថាខ្ញុំបានគ្របដណ្តប់ដែននៃអំពើបាប ខ្ញុំបានគ្របដណ្តប់ទាំងអស់តាមដែលខ្ញុំគិតឃើញ។ នៅយប់នោះបន្ទាប់ពីកម្មវិធីចប់មានស្ត្រីដែលរអ៊ូរទាំដើរក្បែរនោះនិយាយ"ហិម បងប្រុសប្រាណហាំ ខ្ញុំមានចិត្តត្រេកអរពិតដែលអ្នកមិនប៉ះពាល់ខ្ញុំយប់នេះ"។

ខ្ញុំគិត "នោះជាគ្រីស្ទានពិត" និយាយ "អ្នកមិនបានប៉ះពាល់ខ្ញុំទេនៅយប់នេះ"។

65 ខ្ញុំនិយាយ "ល្អ ខ្ញុំរីករាយនឹងឮបែបនោះ អ្នកនាង អ្នកពិតជានៅជិតនគរព្រះណាស់"។ រួចនាងចេញទៅបាត់។

66 មានស្ត្រីជាចាស់ទុំឈរនៅទីនោះ។ ខ្ញុំនិយាយ "និយាយចឹង តើអ្នកស្គាល់ស្ត្រីនោះឬទេ?"

"ចាស"។

ខ្ញុំនិយាយ "នាងប្រាកដជាគ្រីស្ទានពិត"។

67 និយាយ "រឿងមួយដែលអ្នកមិនបានវាយចំនៅថ្ងៃនេះ បងប្អូនប្រុសប្រាណហាំនោះគឺ ការនិយាយដើម។ នាងជាមេនិយាយដើមក្នុងប្រទេស"។ ហ្នឹងហើយ គឺចឹងហើយ ឃើញទេ។

68 ប៉ុន្តែពេលអ្នកមកជាមួយនឹងចំនុចមួយក្នុងចំនោមនោះ មិនថាអ្នកអធិប្បាយវាយចំវានៅលើវេទិកាឬអត់ ពេលអ្នកឃើញអ្វីជាសាច់ឈាមនៃលោកកិយ៍បែបនោះ កាលណាអ្នកនៅស៊ូទ្រាំជាមួយវាកាន់តែខ្លាំង អ្នកនឹងនៅឆ្ងាយពីព្រះ ហើយព្រះវិញ្ញាណបរិសុទ្ធនឹងនៅឆ្ងាយពីអ្នក។ នោះហើយជាហេតុផល ដែលការប្រជុំគ្នាមិនដូចអ្វីដែលគេធ្លាប់ធ្វើ។ នោះជាហេតុផល ដែលគ្មានឧបសគ្គ កើតមានព្រឹកនេះក្នុងរោងឧបោសថ។ នោះជាមូលហេតុ ដែលការប្រជុំតង់ធំមិនមានទូទាំងប្រទេស ព្រោះយើងបានធ្វើឲ្យមានការព្រួយដល់ព្រាបសុភាពនៃព្រះ។ នោះត្រូវហើយ។ ទ្រង់មិនគង់ជាមួយយើងបើយើងនៅមានភាពខុសគ្នាដរាបយើងនៅតែ និយាយដើមគេ"យើងចង់បានរបៀបរបស់យើង!"

69 ឥឡូវខ្ញុំចង់ឲ្យអ្នកកត់ចំណាំ ចៀមគឺជាចៀមស្ងប់ស្ងាត់។ ព្រះគម្ពីរនិយាយថា "ទ្រង់មិនហើបមាត់សោះ ដូចជាចៀមនៅមុខអ្នកកាត់រោម ទ្រង់នៅស្ងៀម" ទ្រង់មិន

ហើបមាត់ ទ្រង់មិនមែនជាមនុស្សដែលត្រូវការសិទ្ធិទ្រង់។ អត់ទេ ទ្រង់មានស្ម័គ្រចិត្តចុះញ៉ូមសិទ្ធិរបស់ទ្រង់។ ទ្រង់ជាចៀមដែលនៅស្ងៀម។

70 ប៉ុន្តែនៅថ្ងៃនេះ អូ ខ្ញុំអើយ ហេតុអ្វីបានជាយើងចង់ខុសគ្នា! អូ ខ្ញុំអើយ! "ខ្ញុំប្រាប់អ្នក អ្នកអាចឲ្យគេនិយាយអ្វីពីខ្ញុំបាន ខ្ញុំនឹងទៅហើយជួបគាត់ ក្មេងប្រុស ខ្ញុំនឹងយកគាត់ចេញ" "ខ្ញុំនឹងប្រាប់ថាជាការកំពុតពីមុន ពេលខ្ញុំឃើញនាង! អ្នកគ្រាន់តែចាំរហូតដល់ខ្ញុំឃើញនាង! ព្រះប្រទានពរ ហាលេលូយ៉ា! អូ ហូ!" ព្រាបគ្រាន់តែយកការហោះហើរហើយចេញទៅ។ នោះត្រឹមត្រូវ។ ព្រះវិញ្ញាណបរិសុទ្ធមិននៅជាមួយអ្នកទៀតឡើយដរាបណាអ្នកនៅមានអារម្មណ៍បែបនោះ។ ចូរកត់ត្រាវាក្នុងសៀវភៅរបស់អ្នក វានឹងមិនដែលធ្វើវាឡើយ។ ព្រះវិញ្ញាណបរិសុទ្ធមិននៅក្បែរកន្លែងជាប្រភេទវិញ្ញាណនោះ។ វាត្រូវតែមានវិញ្ញាណនៃចៀម វិញ្ញាណសុភាព បើមិនដូច្នេះនោះវាមិននៅជាមួយឡើយ នោះគឺវាមិនមានបែបនោះ បើវាមិនមែនសុភាព កំសាក ដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ។ ហើយបើមានអ្វីចូលមកវាមិនទាំងស្គាល់ផង គឺវាបន្ត។ ឃើញ? ហើយនៅនាទីណាដែលវាប្រែប្រួល អ្នកដឹងទេនោះ គឺ...ពេលអ្នកបែរម្ខាងទៀត។

71 អ្នកដឹងទេ បាបដំបូងចាប់ផ្តើមពីមនុស្ស ម្នាក់ដែលបែរចេញតែមួយនាទីប៉ុណ្ណោះ។ តើអ្នកដឹងទេ? ព្រះគម្ពីរនិយាយដូច្នេះ។ ទោះបីជាប្តូរប្រែតែមួយភ្លែតដើម្បីស្តាប់អារក្សនិយាយ។ ហើយវាគូររូបភាពស្អាតទៅ កាន់នាងរហូតដល់នាងគិតថាវាជាសេចក្តីពិត។ ហើយនាងស្តាប់វា។

72 ហើយអ្វីមួយដែលអារក្សវាចង់ធ្វើចំពោះអ្នក គឺត្រូវបែរចេញតែបីបួននាទី។ វាអាចគូររូបនិយាយ "ឥឡូវ មើលទីនេះ។ អ្នកដឹងទេ បងប្អូនប្រុស អ្នកដឹងទេបងប្អូនស្រី បើសិនជាយកវាជាប្រភេទមនុស្ស ពួកគេមិនធ្វើបែប*នេះ*ឡើយ។ បើសិនជាពួកគេធ្វើ*បែបនេះ* ត្រង់នេះអ្នកដឹងទេ" វាអាចធ្វើឲ្យហាក់ដូចជាពិតដល់អ្នករហូតវាក្លាយជាពិតនៃសេចក្តីពិត។ នោះគឺត្រូវហើយ! ប៉ុន្តែចងចាំ វាជាអារក្ស!

73 ខ្ញុំមិនខ្វល់ថាវាធ្លាក់ចុះប៉ុណ្ណាទេ តើឆ្ងាយប៉ុណ្ណាដែលវាឱនចុះក្នុងបាប វាជាការងាររបស់អ្នកត្រូវដាក់ដៃជុំវិញគេនិងលើកគេដោយសេចក្តីស្រឡាញ់របស់ព្រះ។ អ្នកនៅឯណាពេលព្រាបរបស់ ព្រះលើកអ្នកឡើងចេញពីដីឥដ្ឋ? នោះជាកិច្ចការរបស់អ្នកមិត្តរបស់ខ្ញុំអើយ។ ពិភពលោកនេះត្រូវស្លាប់ដោយព្រោះសេចក្តីស្រឡាញ់តិច។ គឺ...

74 ខ្ញុំចង់ឲ្យអ្នកចំណាំពីសត្វនេះ ដែរ សត្វតូចនេះ វាជាចៀមស្ងាត់ស្ងៀមព្រោះវាមិន...ពេលទ្រង់ត្រូវគេប្រមាថ ទ្រង់មិនប្រមាថតបវិញឡើយ។ ទ្រង់មិនរាថយ ហើយបន្ត មិនស្ទាក់ស្ទើរ មិនខឹង ជាដើម ទ្រង់មិនតបតឡើយ។ ពេលនរណា... ពេលទ្រង់ត្រូវគេជេរ ទ្រង់មិនជេរតបវិញឡើយ។ ទ្រង់មិនបើកមាត់ឡើយ។

75 ប៉ុន្តែអ្នកអនុញ្ញាតិឲ្យនរណាម្នាក់ធ្វើអ្វីមួយទៅកាន់អ្នកឬខ្ញុំ អូ ខ្ញុំអើយ យើងនឹងជះកំហឹងដូចជាកង្កែបកន្ទុយស៊ីសត្វល្អិត ប៉ោងឡើងដូច—ដូចក្ងានចាស់។ "ខ្ញុំប្រាប់អ្នកឥឡូវនេះ បើគាត់ជាន់មេជើងខ្ញុំបែបនេះម្តងទៀត ខ្ញុំមិនទៅព្រះវិហារនោះទៀតឡើយ។ អត់ទេ លោក! សរសើរតម្កើងដល់ព្រះ! ហាលេលូយ៉ា! ណាសារ៉ែតនឹងទទួលខ្ញុំនូវក្បួនដង្ហែរបរិសុទ្ធពួកគេនឹងទទួលខ្ញុំ ហាលេលូយ៉ា។ ខ្ញុំមិនចាំបាច់ធ្វើវាទៀតឡើយ" ត្រូវហើយ ព្រាបចាប់ផ្តើមហើរ!

76 "អ្នកដឹងថាជាអ្វី? បើសិនជាមនុស្សកំពុតទៅព្រះវិហារនោះខ្ញុំនឹងមិនទៅទៀតឡើយ។ សរសើរតំកើងព្រះ ខ្ញុំមិនធ្វើអ៊ីចឹងឡើយ!" ពេលការនោះវាយអ្នកនោះជាការគ្រហឹមរបស់ចចកពីមុនព្រាបនឹចាប់ហើរចេញ។ ត្រូវហើយ។ ដូច្នេះព្រះវិញ្ញាណបរិសុទ្ធនឹងចេញ។

77 ដូច្នេះអ្នកប្រហែលជាឆ្ងល់ ថាមានរឿងអ្វីជាមួយអ្នក។ អ្នកឆ្ងល់ថាមានរឿងអ្វីជាមួយក្រុមជំនុំ។ អ្នកឆ្ងល់ថាមានអ្វីកើតឡើងជាមួយអ្នក។ ហេតុអ្វីអ្នកមិនមានជ័យជំនះដូចអ្នកធ្លាប់មាន? អ្នកបានផ្លាស់ប្តូរនិស្ស័យរបស់អ្នក។ អ្នកបានក្លាយជាពពែជំនួសឲ្យចៀម។ អ្នកបានក្លាយជាអ្វីផ្សេងក្រៅពីចៀម។

78 អ្នកត្រូវមានវិញ្ញាណសុភាពនោះ "ចូរឲ្យព្រះវិញ្ញាណបរិសុទ្ធដឹកនាំខ្ញុំទៅគ្រប់ទីកន្លែង។ ព្រះអង្គអើយខ្ញុំស្រឡាញ់គ្រប់មនុស្សមានបាប មិនថាពួកគេយ៉ាងណានោះឡើយ" របៀបនោះបានដាក់នៅក្នុងចិត្តមនុស្ស រួចអ្នកនឹងឃើញអ្វីផ្សេងកើតឡើងព្រលឹងរបស់អ្នក។

79 អ្នកនិយាយ "អឺរ បងប្រុសប្រាណហាំ តើមានដំណោះស្រាយសម្រាប់វាទេ?" បាទ គ្រាន់ឲ្យតែក្លាយជាចៀមប៉ុនោះ។ អ្នកនិយាយ "តែប៉ុណ្ណឹងទេ បងប្រុសប្រាណហាំ!"

80 ខ្ញុំជួបស្ត្រីម្នាក់ទៀតនៅយប់មួយទៀតនៅស្ទ្រីវផត។ ហើយខ្ញុំចុះទៅកន្លែងមួយដើម្បីបរិភោគសាន់វិច បន្ទាប់ពីកម្មវិធីចប់។ មានស្ត្រីក្មេងស្អាតម្នាក់ចូលមក

ប្រហែលជាក្មេងស្រី ឬអាយុម្ភៃឆ្នាំ ប្រហែលនោះ ស្លៀកពាក់ស្អាត។ នាងអង្គុយចុះ។ ខ្ញុំសម្គាល់ឃើញថានាងសម្លឹងមកបែបនោះ។ ខ្ញុំបន្តបរិភោគ។ បីបួននាទីមកស្ត្រីនោះបានចូលមក។ នាងនិយាយ "សុខសប្បាយទេ?" និយាយទៅកាន់នាង។ រួចខ្ញុំដឹងថានោះជាបងប្អូនស្រីដេវីសនៅទីនោះ។ ហើយនាងជាមួយស្ត្រីផ្សេងទៀតមកពីក្រុមជំនុំរោងឧបោសថជីវិត ខ្ញុំស្គាល់ពួកគេច្បាស់ណាស់ នាងចូលមកនិងនិយាយជាមួយខ្ញុំបន្ត។ រួចស្ត្រីក៏អង្គុយខ្វែង ជើងហើយនិយាយ "បងប្អូនប្រុសប្រាណហាំ នោះជាសារដ៏ល្អនៅយប់នេះ"។

81 ខ្ញុំនិយាយ "តើអ្នកសុខសប្បាយទេប្អូនស្រី?" ខ្ញុំនិយាយ "អរគុណអ្នកខ្លាំងណាស់" ហើយខ្ញុំនិយាយ "តើអ្នកជាសមាជិកនៅ ក្រុមជំនុំរោងឧបោសថជីវិត?"

82 នាងនិយាយ "ចាស ពិតមែន" នាងនិយាយ "អ្នកដឹងទេ បងប្រុសប្រាណហាំ ខ្ញុំអាចច្រៀងចម្រៀងជាក្រុមប៉ុន្តែមានភាពរាំងស្ទះត្រង់នោះ" នាងនិយាយ "ខ្ញុំមាន អូ មានការហ្វឹកហាត់សម្លេងស្ទួធជាច្រើនឆ្នាំនិងអ្វីៗផ្សេង។" និយាយ "ខ្ញុំច្រៀងចម្រៀងទោលនិងច្រៀងច្បាស់" និយាយ "ប៉ុន្តែ ខ្ញុំ—ខ្ញុំមិនអាចច្រៀង ព្រោះពួកគេ មាន—ពួកគេមានភាពរាំងស្ទះត្រង់នោះ 'មិនមានស្ត្រីណាស្លៀកខោ អាចច្រៀង—ច្រៀងចម្រៀងជាក្រុមបានឡើយ'"។

ខ្ញុំនិយាយ "ល្អ សរសើរព្រះសម្រាប់ក្រុមជំនុំរោងឧបោសថជីវិត!"

83 នាងនិយាយ "ល្អ ខ្ញុំប្រាប់អ្នក បងប្អូនប្រុសប្រាណហាំ" នាងនិយាយ "ខ្ញុំជាគ្រីស្ទាន"។

84 ខ្ញុំនិយាយ "ដូច្នេះប្អូនស្រីអើយ ទៅផ្ទះហើយលុបមុខ ឬគ្រប់អ្វីដែលអ្នកតុបតែង" ខ្ញុំនិយាយ "អ្នកមានន័យថាអ្នកកំពុងប្រាប់ខ្ញុំថា អ្នកអនុញ្ញាតិឲ្យការតូចមួយនោះ ពាក់នៅលើរបស់អ្នក..."

85 ហើយខ្ញុំអាចបង្ហាញអ្នកថា នោះមកពីអារក្ស។ ខ្ញុំអាចបង្ហាញអ្នកថាមិនមានអ្វីនៅក្នុង...ភាពដើមឡើយ វាគឺផ្តេសផ្តាស។ ហើយដរាបណាអ្នកពាក់វា វាសម្គាល់ថាជាអ្នកមិនជឿ។ ឥឡូវខ្ញុំទើបមកពីអាហ្វ្រិក ហើយខ្ញុំនៅព្រៃហូតថិនថុត (Hottentot) ហើយរកឃើញពីប្រភពក្រវិល របស់ទាំងអស់មកពីណា ហើយទាំងអស់នេះ មានគ្រឿងអាល័ង្គការជាច្រើនដែលនៅជុំវិញករបស់អ្នកនិងត្រចៀកនិងអ្វីទៀត មានប្រភពមកពីណា។ វាជាអ្នកមិនជឿ។ ហើយព្រះគម្ពីរមិនចង់ឲ្យ

គ្រីស្ទានក្លាយជាអ្នកមិនជឿឡើយ។ ហើយអ្នកមិនចង់…ខ្ញុំមិនបាននិយាយថាអ្នកជាអ្នកមិនជឿដោយសារធ្វើការទាំងនេះទេ ប៉ុន្តែអ្នកធ្វើខ្លួនឯងឲ្យ ដូចជាគេម្នាក់ដែរ។ ពីព្រោះគ្រូគង្វាល របស់អ្នកមិនបានប្រាប់សេចក្តីពិតទាំងនោះ។ ព្រះគម្ពីរនិយាយដូច្នេះ។

86 ហើយឥឡូវ អ្នកនិយាយ "បងប្អូនប្រុសប្រាណហាំ ខ្ញុំគិតថាបើអ្នកមានសក់ខ្លីវាធ្វើឲ្យខ្ញុំមានអារម្មណ៍ល្អនិងអ្វីផ្សេងទៀត"។ នោះត្រូវហើយ ប៉ុន្តែបើអ្នកមានសក់វែង អ្នកកាន់តែល្អទៀត។ វានឹងក្តោបយកករបស់អ្នក និងរុំវានិងធ្វើឲ្យវាមានភាពត្រឹមត្រូវ។

87 ហេតុអ្វីអ្នកដឹងទេថាព្រះគម្ពីរនិយាយយ៉ាងណា? នោះ មនុស្សប្រុសមានសិទ្ធិយកប្រពន្ធចេញនិងលះលែងពីនាងបើនាងកាត់សក់។ បើសិនជានាងកាត់សក់ វាបង្ហាញថានាងរស់នៅមិនត្រង់ជាមួយគាត់។ ព្រះគម្ពីរនិយាយដូច្នេះ កូរិនថូសខ្សែរទីមួយ 12 ស្វែងរកទៅថាវាត្រឹមត្រូវឬទេ។ នាងដែល…ស្ត្រីដែលកាត់សក់មិនបានលើកតម្កើងក្បាលនាងឡើយគឺជាប្តីរបស់នាង។ ហើយបើនាងមិនអាចលើកតម្កើងបាន នាងត្រូវតែទទួល ការលះលែងនិងនៅឲ្យឆ្ងាយពីនាង។ នោះជាការត្រឹមត្រូវ។ ប៉ុន្តែ ឃើញទេ គ្រូគង្វាលមិនដែលប្រាប់អ្នកពីសេចក្តីនោះឡើយ។ នោះហើយជាមូលហេតុដែលអ្នកធ្វើបែបនោះ។ ហើយ—ហើយ មនុស្សប្រុស ព្រះគម្ពីរនិយាយ…

88 នៅទីនេះមិនជាយូប៉ុន្មានឡើយមាន ម្នាក់សរសេរនិងនិយាយថា "បងប្រុសប្រាណហាំអាវ—អាវទ្រនាប់ទាំងនេះដែលស្ត្រីពាក់"និយាយ "ហេតុអ្វីវាជា…អ្នកនឹងមិនឃើញវាទៀតឡើយ ហើយវាជាការត្រឹមត្រូវសម្រាប់យើង ជាស្ត្រីគ្រីស្ទានដែលពាក់ក្រណាត់នីឡុង ឬអ្វីដែលដូចនោះ?"

89 ខ្ញុំនិយាយ "មើល បងប្អូនស្រី វាមានរឿងមួយពីវា។ នេះមានមួយជាការពិត។ អ្នកអាចធ្វើបែបនេះ: បើអ្នកមិនអាចទិញមួយមក ពួកគេលក់ម៉ាស៊ីនដេរ អ្នកអាចធ្វើវាបាន" ខ្ញុំនិយាយ "នោះត្រឹមត្រូវហើយ។ ធ្វើឲ្យវាមើលទៅបែបនោះ…"ខ្ញុំជឿ…អ្នកដឹង អ្វីនៅក្នុងចិត្តអ្នកគឺបញ្ជាក់ខ្លួនវាផ្ទាល់។ របៀបដែលអ្នកធ្វើនិងរបៀបអ្នកសម្តែងចេញ នោះបង្ហាញអ្វីដែលនៅក្នុងអ្នក។

90 នោះជាហេតុផលដែលការគ្រហឹម ហើយជំលោះនិងការនិយាយដើមគ្នា—ទៅវិញទៅមកគឺនៅក្បែរក្រុមជំនុំជានិច្ចនោះជាអ្វីដែលបំបែកក្រុមជំនុំ។ នោះបង្ហាញថាអារក្សបានចូលទៅក្នុងអ្នក ហើយបង្ហាញថាព្រះវិញ្ញាណបរិសុទ្ធបាន

ចេញពីអ្នក។ ឥឡូវ ខ្ញុំដឹងថា នោះជាការដុតដំរចេញពីអ្នករាល់គ្នាមួយចំនួន ប៉ុន្តែវាគួរតែធ្វើបែបនោះ។ វាគួរហើយ! នោះជាអ្វីដែលនិយាយ មិនមែនជាការឆ្លាតទេ មិនមែនជាការសម្តែងភាពស្អាត ប៉ុន្តែដើម្បីប្រាប់អ្នកពីកន្លែងបញ្ហា ព្រោះថ្ងៃណាមួយខ្ញុំត្រូវឈរឡើងដើម្បីផ្តល់ចម្លើយដល់អ្នក។ ហើយហេតុផលរបៀបដែលអ្នកធ្វើនិងរបៀបអ្នកសម្តែងឡើង នោះបង្ហាញ ថាអ្នកជានរណា។ បើអ្នកមានតែកំដៅចាស់ដែលហើរចេញពីការគ្រប់គ្រងតិចតួចចូរចេញមកនេះហើយបន្ត ឬរិះគន់ ឬភាពថោកទាបដូចនោះ ដែលបង្ហាញថាវាមកពីណា។

91 ឥឡូវមានរឿងតែមួយគត់ដែលត្រូវធ្វើ គឺយកអ្វីនោះចេញពីត្រង់នោះ នោះសត្វព្រាបនឹងត្រឡប់មកចិត្តអ្នកវិញ។ ពេលព្រាបចេញពីទូក នាងបែរចេញ។ ប៉ុន្តែនាងត្រឡប់មកវិញ គោះទ្វាទូកធំរហូតណូអេបើកឲ្យនាងចូលមកវិញ។ [បងប្រុស ប្រាណហាំគោះអាសនា—Ed.] ព្រះវិញ្ញាណបរិសុទ្ធនៅទីនេះ។ ព្រះវិញ្ញាណបរិសុទ្ធចង់ចូលមក។ នោះជាហេតុផលសម្រាប់ថ្ងៃនេះ ដែលព្រះវិញ្ញាណបរិសុទ្ធ ទ្រង់មិនបានចេញពីអ្នករៀងរហូតឡើយ។ គឺគង់នៅទីនោះជាមែកឈើកន្លែងណាមួយ ត្រៀមខ្លួននឹងហើរមកវិញនិងត្រឡប់មករកអ្នក និងប្រទាន ឲ្យអ្នកនូវសេចក្តីស្រឡាញ់ សុខសាន្ត និងអំណរដូចអ្នកធ្លាប់មាន។ ប្រាកដណាស់ គឺបែបនោះ។ ទ្រង់ត្រៀមរួចរាល់ដើម្បីធ្វើវា។ ទ្រង់ចង់ធ្វើ។ ទ្រង់ប្រាថ្នាចង់ធ្វើ។ ប៉ុន្តែអ្នកមិនអនុញ្ញាតិឲ្យទ្រង់ធ្វើវា!

92 ឥឡូវខ្ញុំមិននិយាយទៅកាន់អ្នក របៀបជាអ្នកដ៏ទៃទេឡើយ។ ខ្ញុំមិនដឹងអ្វីពីគ្រូគង្វាលអ្នក...ខ្ញុំកំពុងនិយាយទៅកាន់ អ្នកនៅរោងឧបោសថប្រាណហាំ។ ខ្ញុំមិននិយាយទៅកាន់អ្នក មកពីក្រុមជំនុំផ្សេងឡើយ។ ខ្ញុំនិយាយទៅអ្នកនៅរោងឧបោសថប្រាណហាំ។ នោះជាបញ្ហានៅទីនេះ។

93 នោះជាអ្វីដែលធ្វើឲ្យ ព្រាបបានហើរទៅ។ សូមឲ្យមាននរណា ម្នាក់ចាប់ផ្តើមអ្វីមួយនៅក្នុងព្រះវិហារនិងជារឿងដំបូង"អូគឺបែបនោះ? អូ តើ...? អ្នកមិនមានន័យបែបនោះទេ?" ត្រូវហើយព្រះវិញ្ញាណបរិសុទ្ធចេញទៅ ហើរចេញ។ ដោយមិនអាចទ្រាំជាមួយវិញ្ញាណបែបនោះបាន។ ដរាបណានិស្ស័យរបស់ សត្វចៀមចេញពីអ្នក ដូច្នេះព្រះវិញ្ញាណបរិសុទ្ធក៏ចេញពីអ្នកដែរ។ នោះត្រូវហើយ ។នោះជាបញ្ហានាសព្វថ្ងៃ។ នេះជាហេតុផលដែលមនុស្សស្ថិតក្នុងលក្ខខ័ណរបស់គេ ព្រោះគេ

អនុញ្ញាតិឲ្យវិញ្ញាណដែលខុសចូលមកក្នុងចិត្តរបស់គេ ក្នុងជីវិតរបស់ពួកគេ។ ឥឡូវនេះជាហេតុផលយើងមាន...

94 ព្រះគម្ពីរនិយាយថាមូលហេតុ ដែលមានអ្នកជំងឺច្រើន និងអ្នករងទុក្ខចំណោម យើង ពីព្រោះការនោះ។ យើងត្រូវមានសេចក្ដីសុភាព។ យើងត្រូវមានសេចក្ដីសុខសាន្ត។ យើងត្រូវធ្វើជាចៀម ដូច្នេះនោះជាសត្វព្រាបអាចនៅជាប់ជាមួយយើង។

95 ឥឡូវចងចាំព្រាបនឹងមក។ គាត់និយាយ "អូ បងប្អូនប្រុសប្រាណហាំ កុំប្រាប់ខ្ញុំថាខ្ញុំមិនដែលទទួលព្រះវិញ្ញាណបរិសុទ្ធ។ ហាលេលូយ៉ា! ចុះមក យប់នៅទីនោះមានយប់មួយ អូ ពេលទ្រង់ចូលមក ខ្ញុំអាចដើរបាន..."ពិត នោះជាទ្រង់! "អូ ខ្ញុំមានអារម្មណ៍ល្អ ខ្ញុំមានអារម្មណ៍ដូចខ្ញុំអាចចាប់បានបក្សីតូចមួយចេញពីដើមឈើ និងអោបវាហើយស្រឡាញ់វា។ មនុស្សអាក្រក់បំផុតរបស់ខ្ញុំ ដែលធ្លាប់ធ្វើអ្វីមកលើខ្ញុំ ខ្ញុំមានអារម្មណ៍ដូចខ្ញុំអាចដាក់ដៃជុំវិញពួកគេនិងអោបបាន។ អូ បងប្អូនប្រុសប្រាណហាំ របៀបខ្ញុំនិយាយ!" ប្រាកដ នោះជាព្រះវិញ្ញាណបរិសុទ្ធ។

96 ប៉ុន្តែ អ្នកឃើញហេតុផលដែលទ្រង់មិនអាចនៅជាប់បាន។ អ្នកជាសត្វចៀម ប៉ុន្តែពេលអ្នកក្លាយជាចចកទ្រង់នឹងហើរចេញ។ គ្មានអ្វីខុសជាមួយ—ជាមួយ—ជាមួយព្រាបឡើយគឺជាអ្នកវិញ ហើយ...អ្នកអនុញ្ញាតិឲ្យវិញ្ញាណនោះ មករកអ្នក។ "តើខ្ញុំធ្វើឬបងប្អូនប្រុសប្រាណហាំ?" មែន ពេលអ្នកទៅស្ដាប់ការកុហកនោះ ពេលអ្នកទៅនិយាយ "អើ ខ្ញុំក៏មានសិទ្ធិដែរ!"

97 អ្នកមិនមានសិទ្ធិ! អ្នកត្រូវបានទិញមកដោយតម្លៃ ដែលជាតម្លៃថ្លៃនៃព្រះលោហិតព្រះបុត្រារបស់ព្រះ។ អ្នកមិនមានសិទ្ធិស្របច្បាប់ឡើយ។ ហាលេលូយ៉ា! សិទ្ធិដែលអ្នកមាននោះគឺ មកប្រភពទឹកពេញ ដោយលោហិតចេញពីសសៃព្រះអេម៉ាញូអែល ពេលមនុស្សមានបាបជាប់នៅខាងក្រោមទឹកជំនន់ បាត់អស់ទាំងកំហុសស្នាម។ ហ្នឹងហើយ។ នោះជាសិទ្ធិដែលអ្នកមាន ជាការចុះចូលឆន្ទះផ្ទាល់ខ្លួនចំពោះព្រះហើយព្រះនឹងដឹកនាំពីពេលនោះតទៅ។ នោះជាហេតុនាំឲ្យប៉ះពាល់ដល់ការប្រជុំ...នោះជាហេតុនាំឲ្យមានរឿងចម្លែកជាច្រើន ព្រះវិញ្ញាណបរិសុទ្ធនឹងទៅកន្លែងមួយ ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូល "នេះជាការមិនត្រឹមត្រូវ។ ឈប់ជួបជុំប្ដូរទៅ" ខ្ញុំនឹងឈប់ដែរ បងប្អូនអើយ បន្តទៀត។ នោះត្រូវហើយ ព្រោះអ្នកត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធនៃព្រះ។ ហើយជារបៀបតែមួយដែល

ត្រូវបានដឹកនាំដោយព្រះវិញ្ញាណនៃព្រះ ចូរនៅជាសុភាព មិនចាំបាច់ស្គាល់អ្វីទាំងអស់។

98 "អូ" អ្នកគិត "ខ្ញុំស្គាល់រឿងទាំងមូល" មែន អ្នកយកខួរក្បាលទៅគិតនិងវាមិនទាំងមានដំណើរការផង។ អ្នកស្គាល់សៀវភៅនិងចម្លើយ និងភាសាក្រិកនិងភាសាហេព្រើរ និងមិនមានទាំងកន្លែងសម្រាប់ព្រាបទុំផង។ នោះត្រូវហើយ។ ប៉ុន្តែអ្នកដឹងទាំងអស់ ដូច្នេះព្រាបមិនអាចដឹកនាំបានឡើយ ព្រោះអ្នកដឹងច្រើនពេក។

99 ចៀមមិនប្រកាសថា ដឹងអ្វីទាំងអស់។ វាត្រូវតែមាននរណាម្នាក់ទៀតដឹកនាំ។ សិរីរុងរឿង! នោះគឺវា។ មិនស្គាល់អ្វីទាំងអស់! អាម៉ែន។ អ្វីដែលខ្ញុំដឹង គឺ ព្រះគ្រីស្ទយេស៊ូវសុគតដើម្បីសង្គ្រោះខ្ញុំ។

100 ចុះមកតាមកាលីហ្វនីញ៉ា មានមនុស្សម្នាក់មក មានទីសម្គាល់នៅពីមុខគាត់និយាយ "ខ្ញុំជាមនុស្សល្ងង់សម្រាប់ព្រះគ្រីស្ទ" និងនៅពីក្រោយ និយាយ "មនុស្សល្ងង់នោះជានរណា?" នោះត្រូវហើយ។ ព្រោះមនុស្សល្ងង់ ចំពោះលោកិយ ដើម្បីឲ្យអ្នកបានការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ព្រោះកូនប្រុសស្រីរបស់ព្រះត្រូវដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ។ រ៉ូម8:1 និយាយ "ហេតុនោះ នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវនោះគ្មានទោសសោះ ដ្បិតអំណាចរបស់ព្រះវិញ្ញាណនៃជីវិត ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ" កុំដើរតាមចចក ប៉ុន្តែដើរតាមសត្វព្រាប។ អាម៉ែន។

101 ដុក(Doc) ធ្លាប់ច្រៀងចម្រៀង "បំពេញផ្លូវរបស់ខ្ញុំដោយក្តីស្រឡាញ់ ពេលខ្ញុំដើរជាមួយសត្វព្រាបស្ថានសួគ៌ ចូរឲ្យខ្ញុំចេញទៅជាមួយបទចម្រៀងនិងស្នាមញញឹម ចូរបំពេញផ្លូវខ្ញុំរៀងរាល់ថ្ងៃដោយក្តីស្រឡាញ់។" នេះជាថ្ងៃសុខសាន្ត វាជាថ្ងៃនៃរោងឧបោសថប្រាណហាំ ឬក្រុមជំនុំណាផ្សេងទៀត ឬបុគ្គលណាទៀត ពេលពួកគេចុះញមសិទ្ធិរបស់ខ្លួន ដើម្បីក្លាយជាចៀម។

"អ្វីទៅជាសំណួរ បងប្អូនប្រុសប្រាណហាំ?"

102 ត្រឡប់មករកចៀម ត្រឡប់មកសេចក្តីសុភាព ត្រឡប់មកជាភាពមិនស្គាល់អ្វី ត្រឡប់មកដោយគ្រាន់តែចុះចូលខ្លួនជាមួយព្រះគ្រីស្ទ។ កុំព្យាយាម កុំព្យាយាមធ្វើជាមិនដឹងអ្វី។ ចូរដើរដោយស្លូតបូត ស្ងាត់ស្ងៀម បន្ទាបខ្លួន សុភាព នោះព្រាបនឹងដឹកនាំអ្នក។ ប៉ុន្តែពេលណាអ្នកឃើញ...ទៅស្តាប់ការនិយាយដើមនោះ ពេល

អ្នកទៅដាក់កំហឹងឡើង ពេលអ្នកគិតថាអ្នកមានសិទ្ធិធ្វើ *នេះ* ធ្វើ*នោះ* ព្រាបនឹងចាប់ដំណើរហើរចេញ។ ហើយអ្នកនឹងមិនមានវាទៀតឡើយ។ ឥឡូវនាងមិននៅឆ្ងាយ ពីអ្នកទេនៅព្រឹកនេះក្រុមជំនុំ។ នាងអង្គុយនៅខាងនោះជាសេចក្តីសុខសាន្តរង់ចាំ និស្ស័យរបស់អ្នកផ្លាស់ប្តូរ។ អាម៉ែន។

103 អ្វីដែលអ្នកត្រូវធ្វើនៅថ្ងៃនេះគឺចុះចូលខ្លួនសិទ្ធិរបស់អ្នកទាំងអស់ គឺឲ្យព្រះដាក់ផ្តេកអ្នក និងកោរសម្អាតសិទ្ធិរបស់អ្នកចេញពីអ្នក។ អាម៉ែន។ តើអ្នកអាចស្រមៃទេ ពីចៀមចាស់ទាំងអស់—រោមទាំងអស់តោង ជាប់ពេញខ្លួនទាំងមូល? នោះជាសិទ្ធិរបស់វា។ មែន [បងប្អូនប្រុសប្រាណហាំធ្វើត្រាប់ចៀមដែលខ្សោះខ្សោយ—Ed។] ផ្ទុះកំហឹង រួចគ្រាន់តែដេកលើតុកាត់កោរ។ ពួកគេដឹងថាអ្វីដែលល្អបំផុតសម្រាប់គាត់។ យកសិទ្ធិទាំងអស់របស់គាត់ចេញនិងកាត់កោរវាចេញ តើវាល្អនិងស្រាលខ្លួនប៉ុណ្ណាពេលវារត់។ ខ្ញុំអើយ ខ្ញុំអើយ វាសប្បាយ និងលោតចុះឡើងហើយមានពេលវេលារីករាយមួយ។ ហ្នឹងហើយ។ បើអ្នកចុះញមសិទ្ធិរបស់អ្នកនោះជាអ្វីដែលអ្នកមាន។ ប៉ុន្តែអ្នកត្រូវតែចុះញមសិទ្ធិរបស់អ្នកនិងឲ្យព្រះបន្ទូលរបស់ព្រះកាត់កោរ អ្នកពីអ្វីជាលោកិយចេញ យកទម្លាប់របស់លោកិយចេញ និងអ្នកក្លាយជាជីវិតថ្មីក្នុងព្រះគ្រីស្ទ

104 ទីនេះមានពេលមួយកន្លងទៅហើយ នៅអាហ្វ្រិក ខ្ញុំនិយាយ—ជាអ្នកបរិសុទ្ធចាស់។ គាត់និយាយ "បងប្អូនប្រុសប្រាណហាំ ខ្ញុំស្គាល់អ្នកថាជឿក្នុងការអស្ចារ្យ"

ខ្ញុំនិយាយ "ពិតហើយ បងប្អូនប្រុស"។

105 គាត់និយាយ "ជាច្រើនឆ្នាំកន្លង ខ្ញុំធ្លាប់គិតថាខ្ញុំជានរណាម្នាក់"។ និយាយ "ខ្ញុំគិតថាខ្ញុំជាគ្រីស្ទានពិត"។ ហើយគាត់បន្ត "ដូច្នេះនៅក្នុងក្រុមជំនុំរបស់យើង…ខ្ញុំត្រូវឡើងភ្នំ ដែលជាកន្លែងខ្ញុំឈប់ឡាន"។ ហើយនិយាយ "ខ្ញុំបានឡើងទៅលើភ្នំ អូ បីឬបួនរយទីឆ្ងា និងនៅជុំវិញគុម្ពោត និងងើបឡើង"។ ហើយនិយាយ "យើងមានការអធិស្ឋាននៅទីនោះ"។ ហើយនិយាយ "ខ្ញុំគិតថាខ្ញុំជាគ្រីស្ទានពិត" គាត់និយាយ "ខ្ញុំស្គាល់ព្រះគម្ពីរទាំងអស់។ ខ្ញុំសិក្សាភាសាហេព្រើ។ ខ្ញុំសិក្សាការបញ្ចេញសម្លេងត្រឹមត្រូវនៃព្រះបន្ទូល" និងនិយាយ "នរណាដែលដើរមកខ្ញុំ ខ្ញុំអាច" [បងប្អូនប្រុសប្រាណហាំយកម្រាមជាកាំភ្លើងស្នេប—Ed។] "និយាយទៅកាន់ពួកគេពីព្រះគម្ពីរ។ ខ្ញុំដឹងពីអ្វីដែលខ្ញុំនិយាយ" គាត់និយាយ "យប់មួយខ្ញុំទៅព្រះវិហារ។ មានទំនាស់ជាច្រើននៅក្នុងក្រុមជំនុំរបស់យើង" និយាយ

"មានក្រុមតូចៗ ប្រឆាំងគ្នាទៅវិញទៅមក។ អ្នកដឹងហើយថាវាកើតឡើងដោយរបៀបណា"។

ខ្ញុំនិយាយ "ហ្នឹងហើយ"។

106 គាត់និយាយ "អូ ផ្លូវរបស់ខ្ញុំឡើងទៅលើភ្នំ ខ្ញុំកំពុងដើរហើយពេលជាមួយគ្នា ខ្ញុំមានអារម្មណ៍ដឹងថាមានអ្នកមកតាមពីក្រោយខ្ញុំ" និងគាត់និយាយ "ខ្ញុំគិតថាខ្ញុំគួររង់ចាំបន្តិចទៀតថានោះជានរណា ដើម្បីឲ្យដឹង ហើយខ្ញុំនិយាយទៅកាន់ពួកគេមួយស្របក់តូចយើងក៏ទៅដល់ផ្លូវ" អ្នកដឹង នោះជាអ្វីដែលល្អ អ្នកត្រឹមតែរងចាំបន្តិច។ ហើយបន្ត "ពេលខ្ញុំដើរឡើងភ្នំ" និយាយ "ខ្ញុំមក មានមនុស្សឡើងមកលើភ្នំ" និងនិយាយ "គាត់មានអ្វីស្ពាយលើខ្នងធំជាងខ្លួនមនុស្សទៅទៀត" ហើយនិយាយ "គាត់ដង្ហក់ដង្ហើមនិងផ្លុំគាត់ដើរជំហានខ្លីព្យាយាមងើប ហើយខ្ញុំនិយាយថា 'សម្លាញ់ តើខ្ញុំអាចជួយអ្នកស្ពាយឥវ៉ាន់ឡើងភ្នំទេ?'គាត់និយាយ "ទេ ខ្ញុំត្រូវតែស្ពាយវា" និយាយ "ខ្ញុំមើលដៃរបស់គាត់" និយាយ "ខ្ញុំដឹងហើយថាវាជានិមិត្តទ្រង់មានស្នាមនៅលើដៃ" និយាយ "ខ្ញុំដួលចុះ រួចខ្ញុំនិយាយ 'ព្រះអម្ចាស់ទ្រង់បានស្ពាយបាបរបស់លោកិយនោះក្នុងកាតាបនោះ?" ទ្រង់មានបន្ទូល 'ទេ ខ្ញុំស្ពាយតែរបស់អ្នកប៉ុណ្ណោះ ជួយអ្នកឡើងលើភ្នំ ដើម្បីឲ្យអ្នកឡើងទៅបាន'"។

107 នោះជារបៀបនោះ។ បើយើងគ្រាន់តែសម្លឹងមើលជុំវិញ យើងនឹងឃើញថាទ្រង់កំពុងស្ពាយរបស់យើង។ តើមិនធ្វើឲ្យអ្នកមានអារម្មណ៍ថាតូចតាចទេឬ? ភាពអាក្រក់របស់យើង ចិត្តឃោឃៅ គឺព្រោះតែយើងអាចធ្វើវា!

108 ទីនេះជាយូកន្លងទៅហើយខ្ញុំបានបរបាញ់ ដូចដែលអ្នកបានដឹងហើយ ខ្ញុំចូលចិត្តបរបាញ់។ ហើយមានមនុស្សសាហាវម្នាក់នៅទីជនបទ គាត់ជាមិត្តដែលឃោឃៅ។ ហើយគាត់តែងតែចំអកឲ្យខ្ញុំដោយព្រោះខ្ញុំមិនបាញ់កូនឈ្លូស។ ខ្ញុំនិយាយ "វាឃោឃៅណាស់" ខ្ញុំនិយាយ "តើហេតុអ្វីអ្នកមិនធ្វើជាអ្នកប្រមាញ់ស្អាតស្អំហើយបាញ់តែក្តាន់ចាស់និងអ្វីដែលចាស់ វាបម្រុងនឹងជិតស្លាប់ហើយ? ព្រះប្រទានពួកវាមកយើង។ លើកលែងឲ្យមេក្មេងទាំងនោះទៅ..."

109 គាត់និយាយ "អា អ្នកជាអ្នកអធិប្បាយកំសាក!" នៅតែប្រាប់ខ្ញុំបែបនោះ។

110 ខ្ញុំនិយាយ "ឥឡូវមើលបើខ្ញុំឃ្លានហើយចង់បានកូនឈ្លូសមួយទាំងនោះខ្ញុំជឿថាព្រះនឹងប្រទានវាមកខ្ញុំ។ ប៉ុន្តែគ្រាន់តែបាញ់វា ហើយសម្តែងថាឆ្លាត" ល្អ គាត់

បានបំពេញរទេះ។ ហើយចេញទៅ និងបានហៅវា ជាសម្លេងស្រដៀងហួច ហើយគាត់អាចផ្លុំជាសម្លេងនោះហើយសូរដូចជាកូនឈ្លូសស្រែកហៅ។ ថ្ងៃមួយយើងនៅក្នុងព្រៃជាមួយគ្នា។ ខ្ញុំធ្វើឲ្យគាត់អាម៉ាស ខ្ញុំនិយាយ "ខ្ញុំសុខចិត្តខ្មាស់ខ្លួនឯង"។ សម្លាប់កូនឈ្លូសប្រាំបី ឬដប់មួយពេល បើខ្ញុំអាច ធ្វើនិងអ្វីៗទៀត គ្រាន់តែសម្តែងថាឆ្លាត ត្រូវកាត់ក្តាន់ជាបួននិងទុកចោលនៅទីនោះវិញ។ ខ្ញុំនិយាយ "អ្នកមិនអាចធ្វើចឹងទេ"។

"អា" និយាយ "អ្នកជាគ្រូអធិប្បាយ មានចិត្តកំសាក!"

111 ថ្ងៃមួយគាត់ឈរនៅក្នុងព្រៃ គាត់បានហួចសម្លេងគាត់ និងគាត់ស្រែក និងសម្លេងដូចជាកូនឈ្លូសយំ។ ពេលគាត់ធ្វើបែបនោះក្តាន់ញីដកកវាឡើងមកលោតឡើងចេញមក។ អ្នកអាចឃើញវាមានភ្នែកធំពណ៌ត្នោត។ វាចាប់ផ្តើម។ វាមើលជុំវិញ។ អ្នកប្រមាញ់ងើប កេះកៃកាំភ្លើងបាញ់ក្តាន់ញី។ ហើយក្តាន់ញីឃើញអ្នកប្រមាញ់។ ប៉ុន្តែ អ្នកដឹងថាអ្វីទេ សម្លេងស្រែកនៃកូនឈ្លូសនោះ វាមិនចាប់អារម្មណ៍នឹងកាំភ្លើងឡើយ។ វៃករកមើលកូន វាកំពុងមានបញ្ហា។ អ្នកដឹងទេការសម្តែងភាពជាម្តាយ និងការស្រឡាញ់របស់ម្តាយ ដែលវាប្រឈមមុខជាមួយកាំភ្លើងនៅពីមុខ ដោយសេចក្តីស្លាប់ សម្លឹងមើលចុងកាណុងកាំភ្លើង។ អ្នកដឹងថាអ្វីទេ ការបង្ហាញនោះអស្ចារ្យណាស់ វានៅក្បែរគាត់ គាត់បោះកាំភ្លើងចោល! គាត់រត់មករកខ្ញុំអោបដៃរបស់ខ្ញុំ គាត់និយាយ "ប៊ីលី(Billy) អធិស្ឋានសម្រាប់ខ្ញុំផង ខ្ញុំឆ្អែតនឹងរឿងនេះហើយ!" ពេលគាត់បានឃើញ ការសម្តែងនោះនៃភាពជាវីរៈភាពនៃម្តាយ!

112 អូ ពេលពិភពលោកបានឃើញការសម្តែងនៃ សេចក្តីស្រឡាញ់របស់ព្រះនិងភាព ក្លាហានក្នុងចិត្តមនុស្ស តើមានភាពខុសគ្នាយ៉ាងណា។ ពេលយើងអនុញ្ញាតិឲ្យព្រាបនៃព្រះចូលមកក្នុងចិត្តនិងធ្វើឲ្យយើងសុភាព ធ្វើឲ្យយើងស្លូតបូត។

113 មានទ្រើងជក់នៅទីនោះ ខ្ញុំឈរនិងអធិស្ឋាន សម្រាប់ក្មេងប្រុសចាស់នោះ ខ្ញុំនាំគាត់ទៅកាន់ព្រះអម្ចាស់យេស៊ូវ។ ពីពេលនោះមក គាត់ល្អ និងជាអ្នកប្រមាញ់ស្អាតស្អំ។

114 ប្រាកដ គាត់គិតថាគាត់មានសិទ្ធិ គាត់ចង់ធ្វើអ្វីគាត់ចង់។ "ពួកគេនៅកន្លែងខ្ញុំ ពួកគេបរិភោគរុក្ខជាតិ សត្វចិញ្ចឹម ខ្ញុំបានបើគេចង់។"

115 ខ្ញុំនិយាយ "ត្រឹមត្រូវហើយ ប៉ុន្តែមិនមែនមនុស្សទេដែលធ្វើបែបនោះ" អ្នកត្រូវចុះញមសិទ្ធិរបស់អ្នក។ អូ ព្រះ មានមេត្តា នោះយើងនឹងមានមេត្តាដែរ។

116 ទីនេះមានពេលកន្លងយូរមកហើយ អូ ប្រហែលរាប់រយឆ្នាំកន្លងទៅ មានគ្រីស្ទានដ៏ល្បីម្នាក់រស់នៅនិរតីប្រទេសហរដ្ឋអាមេរិក។ ឈ្មោះរបស់គាត់គឺដានីញ៉ែលឃើរី ជាមនុស្សអស្ចារ្យ ជាអ្នកកោតខ្លាចព្រះ ជាមនុស្សបរិសុទ្ធគ្រីស្ទបរិស័ទពិត ជាមនុស្សដែលគ្រប់គ្នាគិតថាគាត់ជាមនុស្សអស្ចារ្យ។ ហើយដំណើររឿងបន្តថា ពេលនោះគាត់ស្លាប់ ឬក៏ភ្លឹក ហើយគាត់និយាយ...ពេលគាត់ទៅស្ថានសួគ៌ ជាការពិត ពេលគាត់ស្លាប់។ ហើយពេលគាត់ទៅ ដល់ខ្លោងទ្វាគុជអ្នកថែរក្សាមកដល់ទ្វា និយាយ "អ្នកជានរណា?"

117 គាត់និយាយ "ខ្ញុំជាអ្នកផ្សាយដំណឹងល្អ ដានីញ៉ែលឃើរី ខ្ញុំបាននាំព្រលឹងរាប់ពាន់ថ្វាយព្រះគ្រីស្ទ។ ហើយខ្ញុំ...ខ្ញុំត្រូវមកព្រឹកនេះ។ ដំណើរជីវិតរបស់ខ្ញុំនៅលើផែនដីត្រូវចប់ហើយ ខ្ញុំមិនមានកន្លែងត្រូវទៅទេពេលនេះ។

118 នោះជារបៀបដែលនឹងកើតមាននៅពេលណាមួយអស់អ្នកមានបាបអើយ។ នោះជារបៀបដែលនឹងកើតមានដល់អ្នកដែរនៅព្រឹកនេះ អ្នកដែលបែរចេញ។ នោះជារបៀបដែលនឹង កើតមានដល់អ្នកដែរ អ្នកដែលធ្វើឲ្យព្រះវិញ្ញាណបរិសុទ្ធព្រួយចេញពីគេ មិនសុភាពនិងមិនទន់ភ្លន់។ អ្នកមិនបានយំសោករាប់ឆ្នាំ។ អ្នកគ្មានការខ្មាស ដោយខ្ញុំមិនដឹងថាពេលណានោះទេ។ អស់ទាំងភាពសុភាពរម្យទមបាត់ចេញពីអ្នកទៅហើយ។ ប៉ុន្តែប្រាកដណាស់វានឹង មកនៅទ្វាររបស់អ្នកនៅពេលព្រឹកណាមួយ។ ហើយពេលដែលព្រះវិញ្ញាណបរិសុទ្ធសុភាពបានមកគោះទ្វា ចុះហេតុអ្វីអ្នកមិនឲ្យទ្រង់ចូលមក?

119 ដូច្នេះពេលលោកដានីញ៉ែលឃើរីមកដល់—ដល់—ទីនោះ មាត់ទ្វា ពួកគេចូលទៅ និយាយ "អើ មើលតើមានឈ្មោះអ្នកនៅទីនោះទេ" ពួកគេមើលជុំវិញទាំងអស់ពួកគេមិនឃើញមានឈ្មោះនេះនោះទេ។ និយាយថា "ទេ មិនមានដានីញ៉ែលឃើរីទីនេះទ្បើយ"។

120 "អូ" គាត់និយាយ "ប្រាកដណាស់!" និយាយ "ខ្ញុំជាអ្នកផ្សាយដំណឹងល្អ"។ គាត់បន្ថែម "ខ្ញុំបានឈ្នះវិញ្ញាណមនុស្សសម្រាប់ព្រះគ្រីស្ទ"។ បន្ត "ខ្ញុំព្យាយាមធ្វើអ្វីដែលត្រឹមត្រូវ"។

121 អ្នកថែរក្សាទ្វារនិយាយ "លោក ខ្ញុំសូមទោសដែលប្រាប់អ្នកបែបនេះ ប៉ុន្តែមិនមាន ដានីញ៉ែលយើរីទីនេះទេ"។ និយាយ "ខ្ញុំនឹងប្រាប់អ្នកពីអ្វីដែលអ្នកត្រូវធ្វើ"។ និយាយ "ទីនេះយើងគ្មានសិទ្ធិ ដើម្បីតវ៉ាក្ដីរបស់អ្នកឡើយ"។ គាត់និយាយ "ប៉ុន្តែតើអ្នកចង់តវ៉ាក្ដីរបស់អ្នកទេ? អ្នកអាចតវ៉ានៅមុខការជំនុំជម្រះបល័ង្គស បើសិនជាអ្នកចង់"។ ប៉ុន្តែ និយាយ "យើងគ្មានការមេត្តាត្រង់នេះសម្រាប់អ្នកឡើយ មិនមានសោះ ព្រោះយើងគ្មានឈ្មោះអ្នកនៅទីនេះ។ គ្មានការមេត្តាសម្រាប់អ្នកឡើយ"។ និយាយ "តើអ្នកចង់តវ៉ាក្ដីរបស់អ្នកទេ?"

គាត់និយាយ "លោក តើអ្វីទៀតខ្ញុំអាចធ្វើបាន ក្រៅតែអំពីការតវ៉ាក្ដីរបស់ខ្ញុំនោះ?"

122 គាត់និយាយ "អើ ដូច្នេះ អ្នកទៅមុខការជំនុំជម្រះបល័ង្គសនិងតវ៉ាក្ដីរបស់អ្នកនៅទីនោះ"។

123 ដានីញ៉ែល យើរី និយាយថា ខ្លួនរបស់គាត់ធ្លាក់មកតាមអាកាសមកប្រហែលមួយម៉ោង។ និយាយ គាត់មកដល់កន្លែងមួយ វាភ្លឺឡើង ភ្លឺឡើង ភ្លឺឡើង ភ្លឺឡើង។ និយាយ គាត់ទៅមុខទៀត វាកាន់តែភ្លឺ។ វាមានពន្លឺភ្លឺរាប់រយ រាប់ពាន់ដងជាងព្រះអាទិត្យ។ ហើយនិយាយថាគាត់ញាប់ញ័រ ញ័រ។ ហើយនិយាយ ពេលគាត់ចូលក្នុងកណ្ដាលនៃពន្លឺនោះគាត់ឮសម្លេងនិយាយ "តើអ្នកបានល្អឥតខ្ចោះនៅលើផែនដីទេ?" សម្លេងដែលចេញពីពន្លឺនោះ។

គាត់និយាយ "ទេ ទូលបង្គំមិនល្អឥតខ្ចោះនោះទេ" ញាប់ញ័រ។

និយាយ "តើអ្នកតែងតែស្មោះត្រង់ជាមួយគេគ្រប់គ្នាឬ?"

124 និយាយ "ទេ" (និយាយ "មានបីបួនចំណុចក្នុងគំនិតខ្ញុំដែលខ្ញុំមិនស្មោះត្រង់")និយាយ "ទេ ខ្ញុំ—ខ្ញុំ—ខ្ញុំយល់ថាខ្ញុំមិនស្មោះត្រង់ទេ"។

និយាយ "តើអ្នកប្រាប់ការពិតឬទេក្នុងគ្រប់ករណី ក្នុងជីវិតរបស់អ្នក?"

125 និយាយ "ទេ។ ខ្ញុំចាំថា ខ្ញុំបានប្រាប់រឿងខ្លះដែលត្រឹមត្រូវ...ប៉ុន្តែវាមិនត្រឹមត្រូវទេ។ ខ្ញុំ—ខ្ញុំ—ខ្ញុំ—ខ្ញុំជាមនុស្សគ្មានសេចក្ដីពិតឡើយ"។

126 និយាយ "តើអ្នកធ្លាប់យកអ្វីដែលមិនមែនជាកម្មសិទ្ធិរបស់អ្នកឬទេ អ្វីដូចជាលុយ អ្វីទៀតដែលមិនមែនជារបស់អ្នក?"

127 និយាយគាត់គិតថានៅលើផែនដីគាត់ល្អ ប៉ុន្តែគាត់ជាប់មានទោស។ និយាយ "ទេ។ ទេ ខ្ញុំបានយកអ្វីដែលមិនមែនជារបស់ខ្ញុំ។"

គាត់និយាយ "ដូច្នេះអ្នកមិនបានល្អឥតខ្ចោះឡើយ" គាត់និយាយ "ទេ ខ្ញុំមិនល្អឥតខ្ចោះឡើយ។"

128 និយាយ គាត់រង់ចាំនូវការកាត់ទោសចេញពីពន្លឺដ៏អស្ចារ្យពីពន្លឺនៃព្រះវិញ្ញាណបរិសុទ្ធ "ការកាត់ទោស!" និយាយ បន្ទាប់មកគាត់ឮសម្លេងពីក្រោយគាត់ នោះគឺផ្អែមជាងសម្លេងម្តាយណាដែលធ្លាប់ឮទាំងអស់។ និយាយគាត់បែរងាកមើល។ ហើយឃើញទឹកមុខផ្អែមល្ហែម ដែលគាត់មិនដែលបានឃើញផ្អែមល្ហែម ជាងម្តាយណាៗទាំងអស់ កំពុងឈរពីមុខគាត់។ ហើយនិយាយ លោកនិយាយ "ព្រះបិតាដានីញ៉ែលឃើរីឈរសម្រាប់ទូលបង្គំនៅលើផែនដី។ វាជាការពិត ឥឡូវទូលបង្គំឈរសម្រាប់គាត់នៅស្ថានសួគ៌ដែរ។ យកបាបទាំងអស់របស់គាត់ ហើយដាក់លើទូលបង្គំចុះ"។

129 តើនរណានឹងឈរសម្រាប់អ្នកនៅថ្ងៃនោះ បងប្អូនអើយ បើអ្នកធ្វើឲ្យទ្រង់ព្រួយនៅឆ្ងាយពីអ្នកនៅថ្ងៃនេះ? ខ្ញុំមិនអាចអធិប្បាយទៀតឡើយ។ សូមឱនក្បាលរបស់យើងចុះ។

130 ព្រះវរបិតា ចៀមដែលជិតស្លាប់ជាទីស្រឡាញ់ សុភាព ទន់ភ្លន់ បន្ទាបខ្លួនទន់ទាប។ បក្សីមានសំបុកកញ្ជ្រោងមានរូងប៉ុន្តែទ្រង់មិនមានឡើយហើយនៅតែជាព្រះអម្ចាស់ពេញសិរីរុងរឿង! ពេលទ្រង់ប្រសូត្រមក ពួកគេមិនមានសម្លៀកបំពាក់ពាក់ឲ្យទ្រង់។ អូ ព្រះអង្គអើយ ដូច្នេះតើសម្លៀកបំពាក់លើទូលបង្គំល្អយ៉ាងណាទៅ? តើឡានទូលបង្គំមានល្អយ៉ាងណាទៅ? តើផ្ទះទូលបង្គំមានល្អយ៉ាងណាទៅ? តើល្អយ៉ាងណាដែលមាននៅថ្ងៃនោះ? ទ្រង់មិនមានមិត្ត គ្មាននរណាយកទ្រង់ជាមិត្តទេ។ គ្មាននរណាចង់បោះដៃជួយទ្រង់។ ទ្រង់មានបន្ទូលនៅថ្ងៃនោះ ទ្រង់មានបន្ទូល "ខ្ញុំឃ្លានអ្នក មិនបានចំអែតខ្ញុំ។ ខ្ញុំនៅអាក្រាត អ្នកមិនបានស្លៀកពាក់ឲ្យខ្ញុំ" តើល្អយ៉ាងណាបើទូលបង្គំត្រូវធ្វើនៅថ្ងៃនោះ ព្រះអម្ចាស់? ចូរឲ្យទូលបង្គំគ្រប់គ្នាឈរដើម្បីទ្រង់ ដើម្បីឲ្យថ្ងៃនោះមក ហើយទូលបង្គំដើរទៅក្នុងព្រះវត្តមានទ្រង់ មានគ្រប់ទាំងចេស្តា ព្រះវត្តមានគ្រប់កន្លែង ជ្រាបគ្រប់...អូ ព្រះអង្គអើយ ពេលទូលបង្គំឮព្រាប ដែលស្លាបមាននៅទីនោះក្នុងពន្លឺដ៏ធំ វាបានបញ្ចេញពន្លឺនៃភាពអសកល្ប។ ពេលទ្រង់គង់ក្នុងពន្លឺ។

131 “ពេលខ្ញុំត្រូវឈរទីនោះដោយខ្លួនឯង បងប្អូនរបស់ខ្ញុំទៅបាត់ គ្រូគង្វាលរបស់ខ្ញុំទៅបាត់ ម្ដាយរបស់ខ្ញុំទៅបាត់ ឪពុករបស់ខ្ញុំទៅបាត់ ប្រពន្ធរបស់ខ្ញុំទៅបាត់ កូនរបស់ខ្ញុំទៅបាត់ អូ ព្រះអង្គអើយ ដូច្នេះខ្ញុំត្រូវធ្វើដូចម្ដេច ព្រះអម្ចាស់? ខ្ញុំត្រូវធ្វើយ៉ាងណា? ហើយនោះប្រហែលមុនពេលព្រះអាទិត្យលិចយប់នេះផង។ ប៉ុន្តែតើខ្ញុំនឹងធ្វើអ្វី? ខ្ញុំអាចធ្វើអ្វីបាន? អូ ព្រះគ្រីស្ទ ទូលបង្គំនឹងឈរដើម្បីទ្រង់ពេលនេះ! ទូលបង្គំនឹងជ្រើសរើសនៅថ្ងៃនេះ។ ទូលបង្គំចុះចូលរាល់ការនិយាយដើមអ្នកដទៃ។ ទូលបង្គំចុះញមភាពមិនចុះសម្រុង។ ទូលបង្គំចុះញមកំហឹង។ ទូលបង្គំចុះចូលគ្រប់យ៉ាង។ សូមកាត់កោរទូលបង្គំចេញ ព្រះអម្ចាស់ យកអ្វីៗទូលបង្គំមានចេញ។ សូមទ្រង់យកទូលបង្គំ ព្រះអម្ចាស់អើយ។ ទូលបង្គំ—ទូលបង្គំ—ទូលបង្គំ ចង់ឈរកន្លែងទ្រង់។ ទូលបង្គំចង់បានការកាត់ការកោរ។ ទូលបង្គំបោះបង់ភាពអាត្មានិយម អំនួតទាំងអស់ភាពមិនចុះសម្រុង សូមយកចេញពីទូលបង្គំ។ រួចទូលបង្គំចង់ឈរសម្រាប់ទ្រង់ ដូចជាចៀមដែលកាត់កោរបោះបង់ភាពសប្បាយដែលគេហៅថាភាពរីករាយនៃជីវិត ការរាំរែក ការជប់លៀង និងសម្លៀកបំពាក់ថោកទាបចេញ ការតុបតែង ក្រែមលាបមាត់ ថ្នាំលាបក្រចក រាល់ភាពមិនចុះសម្រុងទាំងនេះដែលមើលទៅដូចជាលោកិយ។ អ្នកនិយាយ ‘កុំសម្ដែងដូចជាលោកិយ។ កុំសហការជាមួយលោកិយ។ ចេញពីពួកគេ!’ អូ ព្រះអង្គអើយ! សូមជួយទូលបង្គំ ព្រះអម្ចាស់។ សូមកាត់កោរទូលបង្គំថ្ងៃនេះ។ យកទូលបង្គំដូចជា ចៀមនិងឲ្យទូលបង្គំល្ងង់ កុំបើកមាត់ទូលបង្គំ មិននិយាយអ្វីពីវាគ្រាន់តែឈរនិងទទួលកាត់កោរ។”

132 អូ ព្រះអង្គអើយ តើវាខុសគ្នាយ៉ាងណាហ្ន៎! ទូលបង្គំចងចាំពេលទ្រង់កាត់កោរទូលបង្គំម្ដង យកប្រពន្ធទូលបង្គំ កូនទូលបង្គំ ឪពុកទូបង្គំ និងបងប្អូនប្រុសទូលបង្គំ។ ទ្រង់កាត់កោរទូលបង្គំស្អាត។ តែចិត្តទូលបង្គំនៅតែដឹងថា ទូលបង្គំស្រឡាញ់ទ្រង់។ ទ្រង់ប្រទានពរដល់ទូលបង្គំ! ទ្រង់ល្អយ៉ាងណា! អ្វីទាំងអស់នៃទូលបង្គំ អ្វីដែលទូលបង្គំអាច អស់ទាំងអ្វីដែលទូលបង្គំអាច គឺជាទ្រង់ ព្រះ វាជាទ្រង់ហើយ។ ទូលបង្គំសារភាពអ្វីដែលខុស ទូលបង្គំសារភាពអ្វីទាំងអស់ដែលទូលបង្គំធ្វើឬគិត។ សូមកាត់កោរទូលបង្គំ ព្រះអម្ចាស់ ទូលបង្គំចង់ក្លាយជាចៀមរបស់ទ្រង់។

133 មិនត្រឹមតែប៉ុណ្ណោះ ព្រះអម្ចាស់ ប៉ុន្តែយកមនុស្សគ្រប់គ្នាក្នុងទីនេះនៅព្រឹក

នេះ ចៀមទាំងអស់ និងអ្នកចង់ក្លាយជាចៀម កាត់កោរពួកគេទាំងអស់ នាព្រឹកនេះ ព្រះអម្ចាស់។ សូមដាក់ជើងតូចរបស់ ពួកគេជុំវិញឃ្លាំងនៃដំណឹងល្អ។ សូមព្រះវិញ្ញាណបរិសុទ្ធដឹកនាំគេទៅរកការប្រែចិត្តឥឡូវ ឲ្យគេដឹងថាគេមិនចុះសម្រុងនឹងព្រះ។ ហើយសូមឲ្យទ្រង់បានកាត់កោរគេចេញ អ្វីជាលោកិយ និងអស់ទាំងអ្វីនៃលោកិយ។ សូមទ្រង់កោរចេញទាំងអស់នៅព្រឹកនេះ ព្រះអម្ចាស់ ដែលទូលបង្គំទាំងអស់នៅតែមានជំហរនិងស្ងាត់ស្ងៀមពីមុខទ្រង់ ជាគ្រីស្ទបរិស័ទកើតជាថ្មី។ សូមទទួល ព្រះអម្ចាស់អើយ។

134 ទូលបង្គំស្រឡាញ់ទ្រង់។ ទូលបង្គំចង់ទៅ មិនថាមានបញ្ហាអ្វី ទោះជាអាកាសធាតុក្តៅមិនថាទូលបង្គំមានអារម្មណ៍ថាចូលចិត្តឬអត់។ ទូលបង្គំចង់ទៅ។ ទូលបង្គំចង់ឈរដើម្បីទ្រង់ ព្រោះទូលបង្គំចង់ឲ្យទ្រង់ការពារក្តីទូលបង្គំនៅថ្ងៃនោះ មានបន្ទូល "ល្អ គាត់បានឈរសម្រាប់ខ្ញុំ ឥឡូវ ខ្ញុំឈរសម្រាប់គាត់វិញ" អូ ព្រះអង្គអើយ សូមទទួលនៅថ្ងៃនេះ។

135 ហើយកាលបើក្បាលទាំងអស់កំពុងឱននិងចិត្តគ្រប់គ្នាឱនចុះ។ ខ្ញុំដូចជាមានពិភាល់នៅព្រឹកនេះ ពីនរណាម្នាក់នៅទីនេះ ដែលអ្នកព្យាយាមទៅតាមផ្លូវរបស់អ្នក អ្នកបានធ្វើការ ទាំងនេះដែលអ្នកមិនត្រូវធ្វើ ហើយអ្នកទើបមានអារម្មណ៍នៅព្រឹកនេះថាអ្នកចង់ឲ្យព្រះអម្ចាស់កាត់កោរអ្នកចេញ និងនិយាយ "ធ្វើឲ្យក្លាយជាចៀមពិតរបស់ទ្រង់" សូមលើកដៃ។ ព្រះប្រទានពរអ្នក ស្ត្រី។ ព្រះប្រទានពរបងប្អូនប្រុស។ ព្រះប្រទានពរបងប្អូនប្រុស។ នរណាទៀតនិយាយ "សូមកាត់កោរទូលបង្គំ ព្រះអម្ចាស់ ទូលបង្គំកំពុងឈរ។ ទូលបង្គំជាចៀម។ ទូលបង្គំនឹងមិនបើកមាត់ឡើយ ទូលបង្គំចង់ឲ្យទ្រង់ កាត់លោកិយរបស់ទូលបង្គំចេញ" សូមព្រះប្រទានពរបងប្អូនប្រុស។ សូមព្រះប្រទានពរស្ត្រី។ សូមព្រះប្រទានពរអ្នកកូនប្រុស។ សូមព្រះប្រទានពរស្ត្រី។ សូមព្រះប្រទានពរបងប្អូនស្រី។ "សូមកាត់កោរទូលបង្គំ ព្រះអម្ចាស់" បងប្អូនស្រីហ្គីទី...[អ្នកលេងព្យាណូ—Ed។] ហើយសូមព្រះប្រទានពរស្ត្រី។ សូមព្រះប្រទានពរអ្នកប្អូនស្រី។ "សូមកាត់កោរទូលបង្គំឥឡូវ ព្រះអម្ចាស់។ ទូលបង្គំ—ទូលបង្គំចង់ឲ្យអ្វីទាំងអស់នៃលោកិយ...ទូលបង្គំចង់ឈរសម្រាប់ទ្រង់នៅព្រឹកនេះ។ ទូលបង្គំចង់ឈរជាចៀមេះ ដែលកោររោមរួចហើយ។ ទូលបង្គំចង់ឲ្យអ្វីនៃលោកិយកាត់ចេញពីទូលបង្គំ។ ទូលបង្គំចង់ក្លាយជាកម្មសិទ្ធិទ្រង់ និងទ្រង់ក្លាយជារបស់ទូលបង្គំ។ តើទ្រង់នឹងទទួលទូលបង្គំឬទេ ព្រះអម្ចាស់ ពេល

ទូលបង្គំលើកដៃរបស់ទូលបង្គំដល់ទ្រង់?" សូមព្រះប្រទានពរអ្នកស្ត្រី។ ព្រះប្រទានពរអ្នកលោក។ សូមព្រះប្រទានពរអ្នក។ សូមព្រះប្រទានពរលោក។ សូមព្រះប្រទានពរលោក។ សូមព្រះប្រទានពរអ្នកស្ត្រី។ ព្រះប្រទានពរស្ត្រី ។ ខ្ញុំបានឃើញហើយ។ ព្រះប្រទានពរអ្នកដែលនៅខាងក្រោយនោះ ជាម្តាយ។ ព្រះប្រទានពរអ្នក បងប្អូនស្រី។ ត្រូវហើយគ្រាន់តែស្មោះត្រង់។ "ខ្ញុំចង់ឲ្យព្រះយកអ្វីទាំងអស់ចេញពីខ្ញុំដែលមិនដូចទ្រង់។ រាល់ទាំងការជម្រុញនៃភាពអាត្មានិយមដែលខ្ញុំមានភាពមិនចុះសម្រុងដែលខ្ញុំមាន។ ខ្ញុំចង់ឲ្យទ្រង់កាត់កោរគ្រប់ទាំងផ្លូវនៅព្រឹកនេះ។ ខ្ញុំចង់បានដូចជាទ្រង់។ ខ្ញុំមិនខ្វល់ថាវាត្រូវឬអត់ ខ្ញុំគ្មានសិទ្ធិឡើយ។ មានសិទ្ធិតែមួយ គត់នោះគឺការមករកទ្រង់។ ទ្រង់នឹងធ្វើការទាំងអស់វិញ"។

136 តើមានមនុស្សមានបាបនៅទីនេះទេដែលមិនធ្លាប់សារភាពយកព្រះគ្រីស្ទមិនទាន់បានសង្គ្រោះហើយអ្នកចង់បានការនឹកចាំក្នុងការអធិស្ឋានព្រឹកនេះ សូមលើកដៃ ជាមិត្តមានបាប? ព្រះប្រទានពរអ្នក។ អ្នកផ្សេងទៀតលើកដៃ និយាយ "សូមចងចាំខ្ញុំ បងប្អូនប្រុសប្រាណហាំ។ ខ្ញុំមិនមែនជាគ្រីស្ទបរិស័ទ ហើយខ្ញុំមិនដឹងថាជាពេលណាខ្ញុំនឹងទៅជួបព្រះ។ ហើយខ្ញុំ—ខ្ញុំចង់មានការនឹកចាំឥឡូវក្នុងពាក្យ អធិស្ឋាន ពេលអ្នកបញ្ចប់" ល្អ តើអ្នកលើកដៃឲ្យខ្ញុំអធិស្ឋានឲ្យអ្នកបានទេ? ទ្រង់ទតឃើញ។ សូមព្រះប្រទានពរស្ត្រីតូចនេះ។ សូមព្រះប្រទានពរស្ត្រី។ ព្រះប្រទានពរលោក។ នរណាទៀត "ខ្ញុំចង់ក្លាយជា ខ្ញុំចង់ក្លាយជា..."

137 តើប៉ុន្មានអ្នកទីនេះដែលរាថយ? "អូ" អ្នកនិយាយ "ខ្ញុំមិនទាន់ទទួលស្គាល់បងប្អូនប្រុសប្រាណហាំ" ប៉ុន្តែ មើល បើព្រាបស្លូតបូតនោះចេញពីអ្នក បងប្អូនប្រុសមានអ្វីខុស។ មានអ្វីខុសពេលអ្នកមិនអាចអត់ទោសគ្រប់មនុស្សពីជម្រៅចិត្តរបស់អ្នក មិនថាគេធ្វើអ្វី ឬ គេនិយាយអ្វី បើសិនជាអ្នកមិនអាចអត់ទោសឲ្យគេពីជម្រៅចិត្ត ព្រះយេស៊ូវមានបន្ទូល "បើសិនជាអ្នកមិនអត់ទោសកំហុងសមនុស្ស អស់ពីចិត្ត ព្រះវរបិតានៅស្ថានសួគ៌របស់អ្នកក៏មិនអត់ទោសឲ្យអ្នកដែរ"។

138 ឥឡូវ ចុះបើ នេះជាអាកាសធាតុក្តៅ ចុះបើព្រះអាចហៅអ្នក? កាលបើមានប្រភពទឹកបើកចំហរ ក្រុមជំនុំបានរួចរាល់ ព្រះវិញ្ញាណបរិសុទ្ធគង់នៅទីនេះនៅហោជាងនៃអាគារនេះ សូមត្រៀមខ្លួនរួចរាល់ចុះមកចិត្តនិងត្រឡប់រកសេចក្តីសុភាពវិញនិងសាងសន្តិភាព។ "តើខ្ញុំត្រូវធ្វើយ៉ាងណាបងប្អូនប្រុសប្រាណហាំ?" ព្រះយេស៊ូវក្លាយជាចៀម។ ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកពេលអ្នកក្លាយជា

ចៀម។ ប៉ុន្តែបើអ្នកមានការជម្រុញខុស—គំនិតខុស ចង់មានផ្លូវរបស់អ្នក និងមិនមានបំណងចិត្តចុះញម ដូច្នេះព្រះវិញ្ញាណបរិសុទ្ធនឹងមិនយាងមកឡើយ។

139 ឥឡូវជាមួយក្បាលយើងឱនចុះ ខ្ញុំមិនដឹងថាអ្នកដែលលើកដៃ...ឥឡូវព្រះយេស៊ូមានបន្ទូល "ប្រាកដមែនខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលស្តាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គ ដែលចាត់ឲ្យខ្ញុំមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជានិច្ចហើយមិនដែលត្រូវជំនុំជំរះឡើយ គឺបានកន្លងហួសពីសេចក្តីស្លាប់ ទៅដល់ជីវិតវិញ" យ៉ូហាន5:24។ ប៉ុន្តែឥឡូវបើអ្នកមករកអាសនា លុតជង្គង់ទីនេះ អធិស្ឋានជាមួយគ្នារហូតដល់អារម្មណ៍សុភាព សន្តិភាពនោះ អ្នកអាចទទួលបាន ឬចង់បាននឹងមករកអ្នកម្តងទៀត។ កាលយើងកំពុងបន្តឱនក្បាល និងយើងច្រៀង"មានប្រភពទឹកពេញដោយព្រះលោហិត" ខ្ញុំចង់ឲ្យអ្នកលុតជង្គង់ និងអធិស្ឋាន។ គ្រប់គ្នាឥឡូវចង់មកលុតជង្គង់ទីនេះ នៅអាសនាលើកដៃ និងអធិស្ឋានមួយភ្លែតចុះ។

មានប្រភពទឹកពេញដោយព្រះលោហិត
ហូរចេញពីសសៃព្រះអេម៉ាញ៉ូអែល
ហើយមនុស្សបាននៅពីក្រោម...(ព្រះប្រទានពរអ្នក ស្ត្រី មក ចុះនិងលុតជង្គង់)
ចេញ...

140 ដោយក្បាលឱនកាលអ្នកមានវាក្នុងចិត្ត។ អ្នកដឹងថានរណាបំបែកច្រករបៀងព្រឹកនេះ នឹងធ្វើឲ្យអ្នកខ្មាសខ្លួនឯង? ស្ត្រីជនជាតិស្បែកពណ៌ ក្រីក្រ មានកែងជើងហើម សក់ប្រផេះ បើកផ្លូវឲ្យគាត់មកអាសនា។

141 មានពេលមួយកន្លងទៅហើយ មានបុរសជនជាតិស្បែកពណ៌ម្នាក់ទទួលការសង្រ្គោះ ក្នុងសម័យកាលទាសករ។ គាត់ចេញទៅ ពេលគាត់បានសេចក្តីសង្រ្គោះ គាត់ប្រាប់ចៅហ្វាយថាគាត់មានសេរីភាព។ គាត់និយាយ "អ្នកគឺជាអ្វី?"

និយាយ "ខ្ញុំមានសេរីភាព" រួចមកគាត់ក៏ដោះឲ្យរួចខ្លួន។

142 ទីនេះក៏មានមនុស្សមួយក្រុមទៀត មកទទួលសេចក្តី សង្រ្គោះព្រឹកនេះ។ (និយាយ គាត់មានសេរីភាព) គ្រប់គ្នានៅក្នុងការអធិស្ឋាន និងអធិស្ឋានឲ្យខ្លាំង

តាមអ្នកចង់ធ្វើ ពេលដែលព្រះវិញ្ញាណបរិសុទ្ធដឹកនាំធ្វើការជាមួយមនុស្សក្នុងការសម្រេចចិត្ត។

គាត់និយាយ "ម៉ូសេ តើអ្នកនិយាយថាអ្នកមានសេរីភាពឬ?" និយាយ "បាទលោក។ ខ្ញុំមានសេរីភាព។

143 និយាយ"បើអ្នកមានសេរីភាពខ្ញុំនឹងធ្វើឲ្យអ្នកមានសេរីភាពដែរ។ ទៅអធិប្បាយដំណឹងល្អចុះ"។

144 ពេលគាត់ត្រៀមរួចរាល់សម្រាប់ស្លាប់ មានបងប្អូនប្រុសជនជាតិស្បែកសជាច្រើនមកសួរសុខទុក្ខគាត់ ហើយពេលពួកគេធ្វើដូច្នោះ គាត់និយាយ ទោះបីជាគាត់សន្លប់។ ពេលគាត់ក្រោកឡើងគាត់និយាយ "ខ្ញុំគិតថាខ្ញុំស្លាប់បាត់ហើយ" (សូមព្រះប្រទានពរបងប្អូនសូមលុតជង្គង់ចុះ ទីនោះ) និយាយ "ខ្ញុំគិតថាខ្ញុំទៅបាត់ហើយ"។

និយាយ "តើអ្នកឃើញអ្វីម៉ូសេ?"

145 គាត់និយាយ "ពេលខ្ញុំដើរនៅក្នុងទ្វារខ្ញុំឃើញទ្រង់" និយាយ "ខ្ញុំកំពុងឈរ និងមើលទៅទ្រង់" និងនិយាយ "មានទេវតាមួយមក និងនិយាយ 'មកម៉ូសេអ្នកបានអធិប្បាយដំណឹងល្អជាយូឆ្នាំ អ្នកមានអាវនិងមកុដសម្រាប់អ្នក'" គាត់និយាយ "'កុំនិយាយជាមួយខ្ញុំពីអាវនិងមកុដ។ ខ្ញុំមិនត្រូវការអាវនិងមកុដឡើយ។ ខ្ញុំចង់តែសម្លឹងមើលព្រះភក្ត្រ័ទ្រង់ប៉ុណ្ណោះ'" ខ្ញុំគិតថានោះជាឥរិយាបថនៃគ្រីស្ទានមួយចំនួន។

146 ទីនេះជាយូឆ្នាំមកហើយចេញពីឈីកាហ្គោខ្ញុំទៅកន្លែងសម្តែងកីឡា ជាសារៈ មន្ទីរ ជាងនេះខ្ញុំបានសម្លឹងមើលអ្វីៗជុំវិញទីនោះ។ ខ្ញុំឃើញជនជាតិនេក្រ៉ូ(Negro)ចាស់ម្នាក់មានសក់ពណ៌សខាងចុងតិចៗនៅលើក្បាលទៅមកនៅទីនោះ ដោយមានកាន់មួកនឹងដៃ ខ្ញុំសម្លឹងមើលគាត់។ គាត់រកកន្លែងតូចមួយ និងលោតមកវិញ ហើយទឹកភ្នែកក៏ស្រក់ហូរកាត់ថ្ពាល់ពណ៌ស្រគាំរបស់គាត់។ គាត់ចាប់ផ្តើមអធិស្ឋាន។ ខ្ញុំមើលគាត់មួយខណៈពេល។ គាត់មើលម្តងទៀត ចាប់ផ្តើមយំម្តងទៀត។ ខ្ញុំដើរទៅនិងនិយាយ "លោក"

គាត់និយាយ "បាទ មិត្តជនជាតិស្បែកស?"

ខ្ញុំ និយាយ "ខ្ញុំឃើញអ្នក...តើអ្នករំភើបពីអ្វី? តើអ្នកមានភាពភ្ញាក់ផ្អើលអ្វី?"

147 គាត់និយាយ "លោក បើសិនជាអ្នកអាចមានអារម្មណ៍ដូចខ្ញុំ ខ្ញុំរំភើបពីចិត្តមេត្តា" និយាយ "ខ្ញុំធ្លាប់ជាទាសករ" គាត់បន្ថែមថា "នៅក្នុងទ្រុងកញ្ច្រក់តូចមួយទីនេះ នោះមានសម្លៀកបំពាក់នៅទីនោះ។"

ខ្ញុំនិយាយ "ខ្ញុំឃើញមានសម្លៀកបំពាក់ ប៉ុន្តែតើវាមានអ្វីពិសេសពីនោះ?"

148 គាត់និយាយ "មានចំណុច ស្នាមនៅទីនោះ" និយាយ "នោះ ជាឈាមរបស់អាប្រាហាំលីនខុន" និយាយ "ឈាមនោះដែលយក ខ្សែរក្រវ៉ាត់ទាសករចេញពីខ្ញុំ" គាត់និយាយ "ឥឡូវ មនុស្ស ជនជាតិស្បែកស តើវាមិនធ្វើឲ្យ អ្នករំភើបដែរទេឬ?"

149 ខ្ញុំដាក់ដៃជុំវិញករបស់គាត់ ខ្ញុំនិយាយ "សូមព្រះប្រទានពរអ្នក បងប្អូនប្រុស។ ខ្ញុំស្គាល់ពីឈាមមួយទៀតដែលគួររំភើបជាងនេះ"។

គាត់និយាយ "ខ្ញុំស្គាល់ឈាមនោះ ដែរ លោក"។

150 ខ្ញុំនិយាយ "ទ្រង់បានដកខ្សែរក្រវ៉ាត់ទាសករចេញពីខ្ញុំ" មានពេលមួយខ្ញុំចេញពីថ្ងៃអាទិត្យ និងរត់ប្រណាំងនិងស្ដាយ និងនិយាយរឿងកំប្លែកស្មោគគ្រោគ។ និង អូ ព្រះអង្គអើយតើខ្ញុំធ្វើយ៉ាងនោះម្ដេចកើត? នៅមានស្លាកស្នាមក្នុងចិត្តរបស់ខ្ញុំ កន្លែងដែលខ្ញុំធ្លាប់ធ្វើ។ ប៉ុន្តែខ្ញុំមានអំណារដែលទ្រង់បានយកខ្សែរក្រវ៉ាត់ចេញពីខ្ញុំ។ វាទៅអស់ហើយឥឡូវនេះ ទ្រង់ឈរកន្លែងរបស់ខ្ញុំ។

151 ទីនេះជាយូមកហើយមើលទៅស្ត្រីម្នាក់ គាត់គឺថោកទាបណាស់ខ្ញុំចង់កាត់ទោសគាត់។ ព្រះប្រទាននិមិត្តមួយដល់ខ្ញុំ។ រួចខ្ញុំអធិស្ឋានឲ្យគាត់វិញ ព្រោះខ្ញុំឃើញបាបរបស់ខ្ញុំ គឺធំដូចជានាងដែរ។ ហើយខ្ញុំដើរទៅហើយអង្គុយក្បែរនាងនិងខ្នាសនាង ប្រាប់នាងថាខ្ញុំជាអ្នកដឹកនាំ។ មិត្តប្រុសទាំងពីររបស់នាង...នាងមានអាយុប្រហែលហុកសិបប្រាំ–ចិតសិបឆ្នាំ មិត្តប្រុសពីរនាក់របស់នាងលុតជង្គង់នៅទីនោះ ហើយពួកគេថ្វាយចិត្តដល់ព្រះគ្រីស្ទ។ អូ ខ្ញុំអើយ មានអ្វីខុសប្លែកណាស់!

152 តើអ្នកមិនចឹងទេឬ? តើអ្នកធ្វើបាបច្រើនទេ នៅព្រឹកនេះ តើអ្វីធ្វើឲ្យចិត្តក្លាយជាខ្មៅឬប្រឡាក់រហូតដល់ព្រះវិញ្ញាណបរិសុទ្ធប៉ះអ្នកមិនបាន? ប្រហែលសត្វព្រាបនឹងចាប់ហើរចេញងស់កល្បេ វានឹងជាការចេញជារៀងរហូត។

153 ព្រះប្រទានពរអ្នកជាទីស្រឡាញ់។ មានក្មេងស្រីម្នាក់ កំពុងដើរមក។ សូមព្រះប្រទានពរអ្នក មនុស្សជាទីស្រឡាញ់។ អ្នកនិយាយ "ក្មេងស្រីតូចនោះមិនដឹងទេ" អូ បាទ នាងដឹង។ នាងគ្រាន់តែមិនបានអានទស្សនាវដ្ដីច្រើននិងរឿងហាដូចអ្នកមាន

ប៉ុណ្ណោះ។ នោះមិនមានជាបញ្ហា នាងទន់ភ្លន់។ ព្រះយេស៊ូវមានបន្ទូល "ទុកឲ្យកូនតូចដែលរងទុក្ខមកខ្ញុំចុះ"។

154 មាននរណាទៀតចង់មកចូលរួមព្រឹកនេះ? អាសនាបើកហើយ។ គ្រាន់តែខណៈពេលមួយទៀត រួចពេលយើងច្រៀងម្តងទៀត ដូច្នេះយើងនឹងផ្តល់ការអធិស្ឋានពេលមនុស្សបាបដែលសោកស្តាយអធិស្ឋាន។

> ចោរដែលជិតស្លាប់មានអំនរដែលបានឃើញ
> ប្រភពទឹកក្នុង...(ប្រាកដណាស់គ្រប់យ៉ាងនឹងបាត់ទៅ មិត្តដែលគួរឲ្យអាណិតបានចប់)។
> ហើយទីនោះ សូមឲ្យខ្ញុំ ទោះអាក្រក់ដូចជាគាត់...

155 តើអ្នកមិនមកឥឡូវទេវឺ? តើអ្នកមិនមកទេឬ អ្នកដែលស្គាល់ច្បាស់? ព្រះគម្ពីរចែងថា "បើអ្នកដឹងរបៀបធ្វើល្អ តែមិនធ្វើអ្នករាប់ថាជាបាបអាក្រក់ជាងទៅទៀត" តើអ្នកមិនមកទេឬ? អ្នកដឹងថាអ្នកខុសទេ។ បើកផ្លូវចេញមកអាសនាមក ហើយទូលប្រាប់ដល់ព្រះពីការសូមទោសដែលអ្នកបានប្រព្រឹត្តិចំពោះទ្រង់។ សូមឲ្យព្រះវិញ្ញាណបរិសុទ្ធយាងមកនិងធ្វើឲ្យអ្នកមានចិត្តស្លូតបូត និងសុភាពនិងស្ងប់ស្ងាត់ម្តងទៀត។ តើអ្នកមិនដូច្នេះទេឬ? ចងចាំ បើអ្នកស្លាប់ និងទ្រង់ចេញទោសសម្រាប់អ្នក មិនមាននរណាទៀតដែលនឹងការពារក្តីរបស់អ្នកឡើយ។ ទ្រង់ចង់ឲ្យអ្នកឈរសម្រាប់ទ្រង់នៅព្រឹកនេះ។ ព្រះប្រទានពរអ្នក បងប្អូនប្រុស។

156 រង់ចាំ។ តើវាមិនដូច្នេះទេឬ ដែលមានភាពខុសគ្នា ក្នុងក្រុមជំនុំដែលពិតជាមានអារម្មណ៍ថា អ្នកមានការកាត់ទោស? អ្នកបានរស់នៅសុខសាន្ត ស្លូតបូតសុភាព ជីវិតស្ងប់ស្ងាត់? ឥឡូវ នេះជាការដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ។ អ្នកទទួលការអត់ទោស មិនមានសត្រូវ? រស់នៅក្នុងអតីតកាល លើសអស់ទាំងការកាត់ទោសនៃមនុស្សមានបាប? អ្នកមិនត្រូវរស់នៅដូចជាសាសន៍ដទៃ អ្នករស់នៅខុសពីគេ ជីវិតរបស់អ្នកមានគំរូខុសពីគេ? ព្រះវិញ្ញាណបរិសុទ្ធដែលសុភាពគង់ក្នុងបល្ល័ង្កចិត្តរបស់អ្នក ធ្វើឲ្យអ្នករស់នៅ ដោយសុភាពនិងស្ងប់ស្ងាត់និងមានសេចក្តីស្រឡាញ់មានមនុស្សជុំវិញ? អ្នកជិតខាងអ្នកនិងទាំងអស់គ្នាដឹងនិងអ្នកសហការទាំងអស់ស្គាល់ថាអ្នកសុភាព ស្ងប់ស្ងាត់ ស្លូតបូត ជាគ្រីស្ទបរិស័ទបន្ទាបខ្លួន? ព្រាបនៃព្រះគង់ ជាមួយអ្នក? អ្នកប្រាកដហើយឬ? នេះប្រហែលជាឱកាសចុងក្រោយរបស់អ្នក។ ត្រូវហើយ។

157 ដូច្នេះអ្នកនៅទីនេះជាអាសនា ព្រះប្រទានពរ។ អ្នកមិនចាំបាច់ទទួលការជំនុំជម្រះឡើយ។ ព្រះវិញ្ញាណបរិសុទ្ធនាំការជំនុំជម្រះមកកាន់អ្នក។ ហើយអ្នកមិនចាំបាច់កាន់ក្តោបសិទ្ធិរបស់អ្នក និយាយ "អូ ខ្ញុំក្លាយជាគ្រីស្ទានយូហើយ។ ខ្ញុំមិនចាំបាច់ទៅឡើយ"។ មានអ្នកខ្លះ ជាលើកទីមួយមិនធ្លាប់មកអាសនា។ "ខ្ញុំអាចនិយាយថាមនុស្សមានបាប បើខ្ញុំចង់ នោះជាសិទ្ធិរបស់ខ្ញុំ" បាទ នោះជាការត្រឹមត្រូវ។ តាមក្រមសីលធម៌អ្នកមានសេរីភាព អ្នកអាចសម្តែងតាមរបៀបអ្នកចង់។ ប៉ុន្តែអ្នកបោះបង់សិទ្ធិរបស់អ្នកនៅព្រឹកនេះចុះ។ និយាយ "តើពួកគេនឹងនិយាយអ្វី ខ្ញុំជាគ្រីស្ទានពិតប៉ុន្តែឡើងទៅអាសនា តើពួកគេនឹងនិយាយអ្វី?" ប៉ុន្តែព្រះមានបន្ទូលដូចម្តេច? ទ្រង់មានបន្ទូលអ្នក ដែលមកហើយបានធ្វើ។ ឥឡូវអ្នកបោះបង់សិទ្ធិរបស់អ្នក អ្នកមកដើម្បីបានព្រះវិញ្ញាណបរិសុទ្ធដែលសុភាព ដើម្បីតាំងនៅក្នុងចិត្តរបស់អ្នកថ្ងៃនេះ។ ខ្ញុំដឹងថាទ្រង់នឹងធ្វើ។ ខ្ញុំដឹងថាទ្រង់នឹងធ្វើ។ ទ្រង់សន្យាថានឹងធ្វើ។ នោះវាមិនត្រឹមតែមិនអាចជួយទេ មិនអាចជួយឲ្យមក។ គាត់អង្វរ យំ ស្លាប់ និងអ្វីទៀត មានកន្លែងត្រូវមក ចង់មករកអ្នក។

158 ហើយក្នុងម៉ោងនៃសេចក្តីស្លាប់ ពេលទេវតានៃសេចក្តីស្លាប់អង្គុយក្បែរជើងគ្រែជំនួសឲ្យសម្លឹងមើលអ្វីគួរខ្លាច ហើយត្រូវដឹងថាអ្នកបដិសេធម្តង ហើយព្រលឹងរបស់អ្នកក្លាយជាខ្មៅនិងកខ្វក់ មិនមានពេលទៀត មិនថាអ្នកស្រែកប៉ុណ្ណាទេ។ អេសាវធ្វើបាបជាបាបនៅឆ្ងាយពីព្រះគុណព្រះ...ថ្ងៃនៃព្រះគុណរបស់គាត់ ជាសជាងហើយមិនមានឱកាសទៀតឡើយ។ គាត់យំល្វីងជូចត់ ព្យាយាមរកកន្លែងដើម្បីដោះស្រាយ ប៉ុន្តែគាត់មិនអាចធ្វើបាន។ ព្រះហៅគាត់នៅថ្ងៃចុងក្រោយ។

159 ប៉ុន្តែអ្នកបានបោះបង់សិទ្ធិរបស់អ្នកនិងមិត្តរបស់អ្នក និងអារម្មណ៍របស់អ្នក និងអ្វីគ្រប់យ៉ាង ព្រឹកនេះដើម្បីមកទីនេះ។ អ្នកបោះបង់សិទ្ធិរបស់អ្នក លុតជង្គង់នៅ ទីនេះនិងនិយាយទៅកាន់ព្រះ។ ខ្ញុំនឹងប្រាប់អ្នកដោយព្រះបន្ទូលនៃព្រះអម្ចាស់ ដែលព្រះគ្រីស្ទមានបន្ទូលថា "អ្នកដែលមកកាន់ខ្ញុំ ខ្ញុំនឹងមិនបោះគេចោលឡើយ" ឥឡូវ កាលបើអ្នកមកកាន់អាសនា ចូរប្រែចិត្ត ប្រាប់ទ្រង់ពីការសោកស្តាយរបស់អ្នកដែលអ្នកបានធ្វើ។

160 នោះ ជាមូលហេតុមនុស្ស មិនទទួលព្រះវិញ្ញាណបរិសុទ្ធពេលព្យាយាមជ្រមុជទឹក ពួកគេមិនប្រែចិត្តពិត។ ព្រះព្យាយាមប្រទានព្រះវិញ្ញាណបរិសុទ្ធដល់គេ។ ទ្រង់សព្វព្រះទ័យឲ្យអ្នកស្លូតបូត និងសុភាពនិងស្ងប់ស្ងៀម។ នោះជាហេតុ

ផលដែលអ្នកក្រោកឡើងជាមួយ ភាពអាត្មានិយមដដែលក្នុងចិត្តរបស់អ្នក។ អូ អ្នកអាចក្រោកឡើងស្រែក និយាយភាសាដទៃនិងអ្វីៗ នោះមិនបានធ្វើឲ្យអ្នកមានព្រះវិញ្ញាណបរិសុទ្ធឡើយ។ អ្នកត្រូវតែ ក្រោកឡើងដោយចិត្តខុសពីមុន។ អ្នកត្រូវតែក្រោកឡើងពីរបៀបបែបនោះ គឺសុភាពនិងស្ងប់ស្ងៀម ស្លូតបូតបន្ទាបខ្លួនហើយព្រះវិញ្ញាណរបស់ព្រះនឹងនៅក្នុងអ្នក។ ឆ្នាំបន្ទាប់ ក្រលេកមើលទុក្ខលំបាក និងឃើញពីចំងាយដែលអ្នកបានចេញមក ឃើញថាអ្នកចាប់បានដែនដីគ្រប់ពេល។ នោះជាព្រះវិញ្ញាណបរិសុទ្ធ។ ព្រះវិញ្ញាណបរិសុទ្ធជាសេចក្តីស្រឡាញ់ អំណរ សេចក្តីសុខសាន្ត ការទ្រាំរងទុក្ខ ស្លូតបូត សុភាព អត់ធ្មត់ និងជំនឿ។ ឥឡូវ សូមប្រែចិត្តនិងប្រាប់ព្រះថាអ្នកចង់បានបែបនោះឥឡូវ។ ទ្រង់…ទ្រង់នឹងធ្វើ។

161 ក្មេងស្រីតូច អ្នកនៅទីនោះ អ្នកធ្វើដូចគ្នា។ ព្រះប្រទានពរអ្នក ម្តាយរបស់អ្នកឈរជាមួយនាងដាក់ដៃលើនាង។

162 នេះបងប្អូនស្រីចាស់ជនជាតិស្បែកខ្មៅនៅទីនេះ ឱនចំពោះអាសនា។ អ្នកប្រហែលជាបរិភោគពោត និងម្សៅពោត ប្រហែលរស់ក្បែរច្រកតូចមួយ នេះជាអ្វីខ្ញុំដឹងប្អូនស្រី។ ព្រះប្រទានពរដល់ចិត្តរបស់អ្នក មានរាជវាំងរៀបចំសម្រាប់អ្នកនៅក្នុងសិរីរុងរឿងព្រឹកនេះ។ ត្រូវហើយ។

163 មើល ទៅអាសនាឃើញស្ត្រីម្នាក់ សក់ប្រផេះ ជាក្មេងស្រី ដែលឱនក្បាលចុះស្ត្រីសក់ពណ៌ស។ អូ ព្រះ! ឃើញមនុស្សប្រុសលុតជង្គង់ ខុសពីគេនៅតាមទីនេះ។ ចូរប្រែចិត្ត ប្រាប់ទ្រង់ពីការសោកស្តាយរបស់អ្នក។ ប្រាប់ទ្រង់ថាអ្នកនឹងមិនធ្វើវាទៀតឡើយ។ ដោយព្រះគុណទ្រង់ អ្នកនឹងធ្វើឲ្យការមិនចុះសម្រុងរបស់អ្នកបានប្រសើរវិញ ពីថ្ងៃនេះទៅ។ អ្នកចង់បានសុភាពនិងស្ងប់ស្ងៀម។ អ្នកចង់បន្ទាបខ្លួន និងទៅកន្លែងដែលទ្រង់ដឹកនាំ។

164 ពេលមនុស្សនិយាយអ្វីមិនថាវាមើលសមទំនងយ៉ាងណាទេ អ្នកត្រូវចុះញមសិទ្ធិរបស់អ្នកដើម្បីនិយាយជាមួយអ្នកជិតខាង។ អ្នកត្រូវនិយាយ អ្នកត្រូវនិយាយពីព្រះយេស៊ូវ។ អ្នកត្រូវធ្វើអ្វីដែលត្រឹមត្រូវ។ អ្នកមិនត្រូវចេញទៅដូចជាឧក្រិដ្ឋជនឡើយ។ អ្នកមិនមែនលោតទៅដូចជាមនុស្សមិនយល់អ្វីឡើយ។ ប៉ុន្តែអ្នកឃើញការសម្តែងចេញដោយក្លាយហាន នៃវីរបុរសគ្រីស្ទានពិត និងអ្នកចង់ដូចពួកគេ។ អ្នកមិនចាំបាច់ប្រាប់គេថាអ្នកជាគ្រីស្ទានឡើយ បើសិនជាអ្នកពិតជា

ម្នាក់មែន គេនឹងឃើញនិងស្គាល់ពេលអ្នកនិយាយ។ អ្នកមានត្រាទាំងខាងក្នុងនិងខាងក្រៅ។

165 ឥឡូវ ពេលអ្នកបន្ទាបចិត្តប្រែចិត្តឥឡូវ។ ទូលប្រាប់ដល់ព្រះ អ្នក "សូមទោស" អ្នក "មិនធ្វើវាទៀតឡើយ" អ្នក "ខ្មាស"ខ្លួនឯង នៅរបៀបដែលអ្នកបានធ្វើ។ ដូច្នេះ ខ្ញុំនឹង អធិស្ឋានសម្រាប់អ្នក។ ហើយខ្ញុំជឿ បែបនេះ សេចក្ដីសុខសាន្តនឹងមានក្នុងចិត្តអ្នក សុខសាន្តដូចជាទន្លេហូរចូលព្រលឹងរបស់អ្នក។ អ្នកប្រហែលមិនបាច់ស្រែក ឬមិនចាំបាច់និយាយភាសាដទៃ អ្នកមិនចាំបាច់លោតចុះឡើង ប៉ុន្តែអ្នកនឹងចេញពីអាសនាទៅដោយមានអ្វីទៅជាមួយ អ្វីមួយនៅក្នុងអ្នកដែលភ្ជាប់អ្នកជាមួយឈើឆ្កាងពុកពេលអ្នករស់នៅ។ ឥឡូវអធិស្ឋាន ខ្ញុំធ្វើដូច្នេះ។ សារភាព។

166 ព្រះវរបិតានៅស្ថានសួគ៌របស់យើង។ សភាវៈគ្មានតំលៃនេះ បន្ទប់ក្ដៅ បែកញើសនៅព្រឹកនេះ ប្រអប់ក្ដៅ ប៉ុន្តែព្រះទ្រង់ធ្វើឲ្យយើងខ្ញុំបែកញើសចេញ។ ព្រះវិញ្ញាណបរិសុទ្ធយាងមក បំផ្លាស់បំប្រែចិត្តមនុស្សដែលគេខុស។ ពួកគេធ្វើបាប។ វិញ្ញាណរបស់ពួកគេព្រហើន។ ពួកគេក្លាយជារងអន្តរាយ ជ្រៀតជ្រែកស្គាល់រឿងទាំងអស់ មិនមានបំណងប្រែចិត្ត មិនមានបំណងអត់ទោសឲ្យអ្នកដែលធ្វើអ្វីទាស់នឹងគេ។ ពួកគេមិនមានបំណងឆន្ទៈ ប៉ុន្តែនៅថ្ងៃនេះព្រះវិញ្ញាណបរិសុទ្ធនាំព្រះបន្ទូលរបស់ព្រះមកដាក់ចូលក្នុងចិត្តសុភាពរបស់ពួកគេ និងនិយាយ "ឥឡូវតើអ្នកចង់ត្រឡប់មកកន្លែងដែលអ្នកបានមកអាសនាលើកដំបូង ត្រឡប់ទៅរកគ្រប់គ្នា អ្នកស្រឡាញ់គ្រប់គ្នា និងអ្នកស្រឡាញ់ខ្ញុំ ដោយសេចក្ដីស្រឡាញ់មិនចេះសាបសូន្យ? ដូច្នេះក្រោកឡើង និងមកអាសនា។" ពួកគេបានធ្វើវា ព្រះអម្ចាស់អើយ។

167 ឥឡូវ ខ្ញុំអធិស្ឋានឥឡូវដែលទ្រង់នឹងបន្សុតគំនិតរបស់ពួកគេ ព្រះអម្ចាស់។ ប្រោសចិត្តគេឲ្យបានបរិសុទ្ធ សូមជួយឲ្យពួកគេ មានចិត្តសុភាពនិងសុខសាន្ត។ សូមឲ្យពួកគេងើបឡើងពីអាសនានេះឥឡូវ បន្ទាប់មកគេប្រែចិត្ត ថ្វាយជីវិតគេដល់ទ្រង់ពេលត្រឡប់ទៅផ្ទះវិញ។ មិនថាមានអ្វីកើតឡើង បើសិនជាប្ដីមានការមិនសប្បាយចិត្ត ឬប្រពន្ធមិនសប្បាយចិត្ត ឬអ្នកជិតខាងមិនសប្បាយចិត្ត ឬអ្នកណាទៀតដែលគេធ្វើការ និងសហការជាមួយ "ទូលបង្គំនឹងបានសុភាពដូចជាព្រាប"។

168 បន្ទាប់ពីនោះ ការសងសឹកជារបស់ទ្រង់ "យើងនឹងសងគេ ព្រះបន្ទូលព្រះអម្ចាស់" តើយើងខ្ញុំអាចរកឃើញសេចក្ដីនោះដូចម្ដេច ព្រះអម្ចាស់។ គឺគ្រាន់តែ

ឈរនៅស្ងៀមចូរសុភាព មើលព្រះនឹង...យាងមកចៀមរបស់ទ្រង់។ ប្រាកដណាស់ ពិតហើយ។ អ្នកគង្វាលល្អនេះនឹងលះបង់ជីវិតទ្រង់សម្រាប់ពួកគេ ទ្រង់នឹងយាងចុះមករកចៀមទ្រង់។ ហើយទ្រង់នឹងដឹកនាំពួកគេ។ វេទនាហើយអ្នកដែលធ្វើបាបចៀម! វេទនាដល់អ្នកដែលនិយាយពាក្យទាស់នឹងពួកគេ! មានចែងទុកមកថា "ចូរឲ្យគេចងដុំថ្មជាប់នឹងក នឹងពន្លិចទៅសមុទ្រប្រសើរជាង។ ទេវតារបស់ពួកគេតែងនៅមុខព្រះភក្រ័ព្រះវរបិតាដែលនៅស្ថានសួគ៌" មើល? អូ ព្រះអង្គអើយ យើងចង់... "ដូចដែលទ្រង់ធ្វើចំពោះគេ ទ្រង់ក៏ធ្វើចំពោះខ្ញុំដែរ"។

169 ដូច្នេះ ព្រះអង្គអើយទូលបង្គំចង់សុភាព។ ទូលបង្គំប្រគល់ខ្លួនចំពោះអាសនាផងដែរ ព្រឹកនេះ មិនមែនតែព្រឹកនេះទេ ប៉ុន្តែរៀងរាល់ព្រឹកនិងរៀងរាល់ថ្ងៃ។ ទូលបង្គំចង់នៅស្ងប់ស្ងៀមនិងសុភាពនិងដូចជាព្រះយេស៊ូ។ ទទួលយក ព្រះបិតាជួយទូលបង្គំពីឥឡូវសូម ឲ្យរលកគ្មានជម្រៅនៃក្តីស្រឡាញ់ បានរមៀលកាត់ព្រលឹងរបស់ទូលបង្គំ។

សុខសាន្ត! សុខសាន្ត! សេចក្តីសុខសាន្តអស្ចារ្យ
សូមមកពីព្រះបិតាខ្ពស់បំផុត(តើអ្នកមិន មានអារម្មណ៍បែបនេះក្នុងចិត្តឥឡូវទេឬ?)
...លើ វិញ្ញាណរបស់ខ្ញុំរៀងរហូត (ហាលេលូយ៉ា ហាលេលូយ៉ា!)...
សុខសាន្ត! សុខសាន្ត! សេចក្តីសុខសាន្តអស្ចារ្យ...

170 បងប្អូនស្រីហ្គើទី(Gertie)និយាយថា ប្រាប់ក្រុមជំនុំទាំងអស់ថានាងទទួលការកាត់ទោសផងដែរប៉ុន្តែនាងបានយកព្យាណូជាអាសនារបស់នាង។ ព្រោះអាសនានោះព្យាណូជាអាសនានិយាយ"ប្រាប់ក្រុមជំនុំអធិស្ឋានឲ្យខ្ញុំផង" ពេលនាងអង្គុយនៅទីនោះ ទឹកភ្នែកក៏រមៀលចុះពីវ៉ែនតារបស់គាត់។ តុវេទិកានេះជាអាសនារបស់ខ្ញុំ។ ខ្ញុំបានប្រែចិត្ត ផងដែរ ព្រះគម្ពីរខ្ញុំសើមហើយ ។ អូ ព្រះ!

សុខសាន្ត សុខសាន្ត នៃព្រះ!
ចុះមក ពី ព្រះបិតាខ្ពស់បំផុត (អូ ហាលេលូយ៉ា!)
...លើវិញ្ញាណខ្ញុំរៀងរហូត...

171 ព្រះអង្គអើយ បើសិនជាអ្នកធ្វើបាបទាស់នរណាម្នាក់ ឬនរណាម្នាក់ទាស់នឹងអ្នកយកវាចេញ ព្រះអម្ចាស់អើយ។ យកបាបវាចេញពីក្រុមជំនុំតូច នៅព្រឹកនេះ។

172 តើមនុស្សប៉ុន្មាននាក់ដែលមានអារម្មណ៍ថាព្រះអត់ទោសឲ្យអ្នក ហើយព្រាប នៃសេចក្តីសុខសាន្តទុំ នៅក្នុងចិត្តរបស់អ្នកម្តងទៀត? នាងបានហោះ ទៅវិញ ឥឡូវ យកកន្លែងនាង។ ព្រះវិញ្ញាណបរិសុទ្ធទើប ធ្វើចលនានិងមានបន្ទូល "កូន របស់យើងអើយ យើងនៅតែចង់ស្រឡាញ់អ្នកគ្រប់ពេល អ្នកមិនចង់ឲ្យយើងធ្វើវា។ យើងមិនអាចរស់នៅក្នុងវិញ្ញាណអាត្មានិយមចាស់របស់អ្នក។ ប៉ុន្តែឥឡូវនេះអ្នក បានចុះចូលវា យើងបានត្រឡប់មកចិត្តអ្នកវិញនៅព្រឹកនេះ" តើមនុស្សប៉ុន្មាននាក់ ដែលមានអារម្មណ៍បែបនោះ? លើកដៃអ្នកឡើង។ លើកដៃអ្នកឡើង។ ត្រូវហើយ តាមអាសនា។ អូ នោះល្អហើយ។ តើប៉ុន្មាននាក់ដែលមកចូលរួមមានអារម្មណ៍ បែបនោះ? លើកដៃរបស់អ្នកឡើង។ អូ! [បងប្រុសប្រាណហាំ និយាយទៅអ្នកលេង ព្យាណូ "ឲ្យបានដូចព្រះយេស៊ូវ"—Ed។]

173 ព្រះបិតានៅស្ថានសួគ៌របស់ពួកទូលបង្គំ ពួកទូលបង្គំអរព្រះគុណទ្រង់សម្រាប់ ពេលវេលាស្រទន់ ជាការលះបង់ញែកប្រសុទ្ធ ដូចជាយកផ្លែប៉ោមនៅដៃ ចិត្តវា ដំវា រហូតដល់ទុំជោរ ដូច្នេះទុំជោរដែលក្មេងតូចអាចបរិភោគបាន។ នោះជាអ្វីដែលចិត្ត ទូលបង្គំចង់បានព្រះអម្ចាស់។ យកវានៅក្នុងដៃ ដែលមានស្នាមរបួសដែកគោល ជាស្នាម និយាយ "កូនអើយ តើអ្នកមិនឃើញទេ ដែលអ្នកធ្វើឲ្យយើងឈឺចាប់? អ្នកបានធ្វើឲ្យយើងឈឺពេលអ្នកហើរទៅធូររលុងនៅកន្លែងទុំបែបនោះ។ អ្នកកំពុង ធ្វើឲ្យយើងឈឺចាប់ អូ ចិត្តរបស់យើងគឺហូរឈាមសម្រាប់អ្នកកូនអើយ ពេលយើង ឃើញអ្នកធ្វើ*បែបនេះ–និងបែប–នោះ*។ ប៉ុន្តែឥឡូវយើងមានចិត្តរបស់អ្នកនៅក្នុង ដៃ យើងចង់មានវាជាភាពស្លូតបូតពិតប្រាកដ។ យើងចង់ធ្វើវាបែបនោះដែលយើង អាចប្រើវានិងគង់នៅក្នុងវាបាន។ យើងចង់ហើរមកទុំបង្គងវិញនៅព្រឹកនេះ យើង ចង់ហើរមកវិញនិងគង់ជាប់នៅ ដើម្បីតាំងការជាប់នៅរបស់យើងជាមួយអ្នក" សូម ទទួល ព្រះអើយ។ ពួកទូលបង្គំស្រឡាញ់ទ្រង់។ សូមទទួល សម្រាប់សិរីរុងរឿង ទ្រង់។ ពួកទូលបង្គំអធិស្ឋានដោយព្រះនាមព្រះយេស៊ូវ។

ឲ្យបានដូចព្រះយេស៊ូវ ឲ្យ...(តើអ្នកមិនស្រឡាញ់ ថ្វាយបង្គំ
បែបនេះ? អូ ព្រលឹងខ្ញុំបានដោះលាង)។
លើផែនដីដែលខ្ញុំ...(មើលទ្រង់យាងចុះមកក្នុង—ក្នុង
ចំណោមអ្នកថ្វាយបង្គំបែបនេះ ចិត្តរបស់អ្នកមាន

អារម្មណ៍សុភាពពិត? បេះដូងរបស់ខ្ញុំលោតកាន់តែញាប់។)
...ធ្វើដំណើរពីផែនដីទៅកាន់សិរីរុងរឿង
ខ្ញុំចង់បានដូចជាទ្រង់។

សូមលើកដៃពេលយើងកំពុងតែច្រៀង

ដូចជាព្រះយេស៊ូវ ដូច...
(Joe អ្នកចង់មក អធិស្ឋានព្រឹកនេះទេ បងប្អូនប្អូនប្រុស? ព្រះប្រទានពរអ្នក។ ចូររកទីកន្លែងអាសនា បងប្អូនប្រុសចូ Joe។ ព្រះប្រទានពរអ្នក។)
...ធ្វើដំណើរពីរផែនដីទៅសិរីរុងរឿង
ខ្ញុំគ្រាន់តែសូមឲ្យបានដូចជាទ្រង់។

174 ខ្ញុំដឹងថាវាក្តៅមិត្ត។ ខ្ញុំដឹង។ ប៉ុន្តែខ្ញុំ—ខ្ញុំសង្ឃឹមថាអ្នកមានអារម្មណ៍បែបនេះ។ អូ ខ្ញុំត្រឹមតែមានអារម្មណ៍ដូចខ្ញុំហើរឡើង។ គួរអោយស្រឡាញ់ណាស់! តើខ្ញុំគួរធ្វើអ្វី? តើខ្ញុំគួរទៅណា? អូ ព្រះ! តើទូលបង្គំទៅណា? តើទូលបង្គំឆ្ពោះទៅណា? តើវានឹង—នឹងក្លាយជាយ៉ាងណា? តើខ្ញុំនឹងទៅជាមានអាយុមួយរយឆ្នាំ? តើយ៉ាងណាបានជាខ្ញុំមិនមានទ្រង់? ឯណា តើទីជ្រកកោនមានឯណាទៀត?

ចេញពីស្នូកសត្វនៅបេថ្លេហិមមានមនុស្សចម្លែកចេញមក
លើផែនដីខ្ញុំចង់បានដូចជាទ្រង់។
ទោះបីដំណើរជីវិតពីផែនដីទៅសិរីរុងរឿង
ខ្ញុំត្រឹមតែសូមឲ្យបានដូចជាទ្រង់។

ទាំងអស់គ្នាឥឡូវ។

ឲ្យបានដូចជាព្រះយេស៊ូវ...(សរសើរដល់ព្រះ! មែនហើយ ព្រះអម្ចាស់! មែនហើយ ព្រះអម្ចាស់! មិនមាននៅលើផែនដី ដូចជាទ្រង់!)
...បានដូចជាទ្រង់
ឆ្លងកាត់ដំណើរជីវិតពី ផែនដីទៅកាន់សិរីរុងរឿង
ខ្ញុំត្រឹមតែសូម...?...

175 ពេលអ្នកឱនក្បាល ខ្ញុំសុំសួរអ្នកអ្វីមួយ។ មាននរណាម្នាក់នៅ ទីនេះធ្វើឲ្យព្រះវិញ្ញាណបរិសុទ្ធមិនសព្វព្រះហឫទ័យ។ មានអ្នកដែលត្រូវបានហៅ។ ខ្ញុំអធិស្ឋានដោយព្រះនាមព្រះអម្ចាស់យេស៊ូវ ជាព្យាការីរបស់ទ្រង់។ ខ្ញុំអាចមានអារម្មណ៍ដឹងថាព្រះហឫទ័យទ្រង់មានរបួស។ ក្រៅទីនោះ មានអ្នកមិនស្តាប់បង្គាប់ទ្រង់ គួរតែចេញមក។ តើអ្នកមិនមកទេឬ?

ឆ្លងកាត់ពីដំណើរជីវិតពី...(បាទ បងប្អូនស្រី ប៉ុន្តែ មានអ្វីច្រើនជាងអ្នក)...សិរីរុងរឿង
ទូលបង្គំត្រឹមតែសូមឲ្យបានដូចជាទ្រង់។

ត្រឹមតែដូចជាព្រះយេស៊ូវ...(នោះជាបំណងចិត្តរបស់ខ្ញុំ ស្លូតបូត និងទន់ ទាប បន្ទាបខ្លួន ដូចជាទ្រង់)
លើផែនដីខ្ញុំ...(តើអ្នកមិនមកឥឡូវទេរឺ? ព្រះសព្វព្រះទ័យឲ្យអ្នកមាន សកម្មភាព មានក្នុងចំនោមអ្នកមួយចំនួន)។
ឆ្លងកាត់អស់ទាំង...

176 ខ្ញុំដឹងអ្នកបានមក។ សូមព្រះប្រទានពរដល់អ្នក។ សូមព្រះប្រទានពរអ្នក។ សូមព្រះប្រទានពរដល់អ្នក។ គឺបែបនោះ។ ខ្ញុំមើលទៅអ្នកចូលរួមទាំងនេះ មានស្រមោលខ្ញុំអាក្រក់ដែលព្យួរ នៅទីនោះដែលខ្ញុំមិនធ្លាប់ឃើញ។ ព្រះវិញ្ញាណបរិសុទ្ធនៅទីនេះឥឡូវនេះ។ វានៅលើខ្ញុំឥឡូវ។ "ធ្វើឲ្យព្រះវិញ្ញាណបរិសុទ្ធព្រួយ"។

ដូចជាព្រះយេស៊ូវ...

177 តើទ្រង់ធ្វើអ្វី? ទៅកន្លែងដែលព្រះបិតាដឹកនាំ។ សូមព្រះប្រទានពរអ្នក បងប្អូនប្រុស។ ព្រះប្រទានពរអ្នកបងប្អូនប្រុស។ នោះគឺត្រឹមត្រូវហើយ ធ្វើសកម្មភាពឡើង និងលុតជង្គង់ចុះ។

លើផែនដីខ្ញុំប្រាថ្នា...

178 ឥឡូវជាពេលសម្រាប់សារភាពពេលវេលាចាស់ តម្រង់ ធ្វើឲ្យបានត្រឹមត្រូវ។ ធ្វើឡើង។ នៅមានអារម្មណ៍ថែមទៀតពីនោះ។ សូមព្រះប្រទានពរអ្នកស្ត្រី។ សូមព្រះប្រទានពរអ្នកស្ត្រី។ សូមព្រះប្រទានពរអ្នក។ សូមព្រះប្រទានពរអ្នក។ សូមព្រះប្រទានពរអ្នក។ ព្រះវិញ្ញាណបរិសុទ្ធតែងតែត្រឹមត្រូវ។ មកចុះ។ នោះត្រូវហើយ ធ្វើសកម្មភាពឡើង។

...ទ្រង់។
ឲ្យបានដូចជាព្រះយេស៊ូវ ឲ្យបានដូច បាទ ព្រះយេស៊ូវ
លើផែនដីខ្ញុំ...(អូ ខ្ញុំអើយ នោះត្រូវហើយ! នោះជាផ្លូវ សូម
បំពេញផ្លូវដើរ ធ្វើសកម្មភាពនិងអធិស្ឋាន)
ឆ្លងកាត់ដំណើរជីវិតពីផែនដីទៅសិរីរុងរឿង (សូម ប្រែចិត្ត
ទូលដល់ព្រះពីការសោកស្ដាយរបស់អ្នក នោះជាអ្វីដែល
អ្នកត្រូវធ្វើ)
...ឲ្យបានដូចជាទ្រង់។

179 តើអ្នកមិនបន្តមករហូតទេឬ? "ទៅ..."នោះត្រូវហើយ ត្រឹមតែហែក និងស្រាយចេញមក។ "ឲ្យបានដូចជា..."

180 តើអ្នកនឹងធ្វើអ្វី? នរណានឹងឈរសម្រាប់អ្នកប្រហែលជាយប់នេះ? តើនរណាឈរសម្រាប់អ្នកពេលសេចក្ដីស្លាប់ចូលក្នុងអាវរបស់អ្នក? មិនថាអ្នកបានប្រព្រឹត្តិអ្វីទេព្រះវិញ្ញាណបរិសុទ្ធគង់នៅទីនោះក្បែរអ្នក។ គឺទ្រង់ហើយដែលចង់ឲ្យអ្នកមក។

ឆ្លងកាត់ការធ្វើដំណើរជីវិតពីផែនដីទៅកាន់សិរីរុងរឿង

181 គ្រាន់តែប្រែចិត្ត និយាយ "ព្រះទូលបង្គំសូមទោស។ ទូលបង្គំ—ទូលបង្គំមិនចង់ធ្វើបែបនោះឡើយ។ ទ្រង់មិនឈរសម្រាប់ទូលបង្គំឡើយ បើទូលបង្គំមិនឈរសម្រាប់ទ្រង់។ ហើយទូលបង្គំចង់ឲ្យទ្រង់ឈរសម្រាប់ទូលបង្គំ ហើយទូលបង្គំក៏ឈរសម្រាប់ទ្រង់ពីថ្ងៃនេះទៅ។ទូលបង្គំនឹងរស់នៅតាមរបៀបគ្រីស្ទានគួរធ្វើ។ ទូលបង្គំនឹងប្ដូរផ្លូវរបស់ទូលបង្គំ ទូលបង្គំនឹងសុភាពនិងស្ងប់ស្ងៀម។ ទូលបង្គំនឹងឲ្យគេគ្រប់គ្នាធ្វើតាមការនិយាយផ្ទាល់របស់ពួកគេគ្រប់យ៉ាង។ ទូលបង្គំគ្រាន់តែរស់នៅស្លូតបូត និងស្ងាត់ស្ងៀមចំពោះព្រះភក្ដ្រទ្រង់"។ មិនថាអ្នកប្រកាសថាជាគ្រីស្ទាន យូប៉ុណ្ណាទេក្រុមជំនុំណា ដែលអ្នកចូលរួម នោះគ្មានអ្វីត្រូវធ្វើជាមួយវាឡើយ។ មកចុះ។ ព្រះប្រទានពរអ្នក។ ចុះធ្វើដំណើរទៅកូន។

182 ព្រះកំពុងមានបន្ទូលទៅកាន់អ្នកឥឡូវ។ បើអ្នកជឿខ្ញុំថាជាអ្នកបម្រើរបស់ទ្រង់ ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលមកកាន់ខ្ញុំនៅព្រឹកនេះ មានបន្ទូលថា "ធ្វើការហៅមានមនុស្សជាច្រើននៅទីនោះ"។ នេះគឺជាថ្ងៃ នេះជាពេលវេលា។ មានមនុស្សប្រហែលប្រាំទៅប្រាំមួយអ្នកនៅទីនោះគួរតែមកឥឡូវ។ ចងចាំ បងប្អូនប្រុសស្រី ខ្ញុំ

កំពុងសម្លឹងមើលអ្នក ខ្ញុំឃើញស្រមោលខ្មៅ នោះតោងពីលើអ្នក។ ឆាប់មកប្រសើរជាង។

183 ឲ្យដូចជាព្រះយេស៊ូវ! តើអ្នកមិនចង់ដូចទ្រង់ សុភាព ស្ងប់ស្ងៀម ស្លូតបូត បន្ទាបខ្លួន? ព្រះប្រទានពរអ្នក មនុស្សវ័យក្មេង។ ព្រះប្រទានពរអ្នក ឪពុកជាមួយទារក។ ព្រះប្រទានពរ បងប្អូនស្រី។ ព្រះប្រទានពរមិត្តដែលមានបាប។ នោះត្រូវហើយ។ ធ្វើសកម្មភាពឡើង បងប្អូនស្រី ចេញមក រកកន្លែងសម្រាប់ខ្លួនអ្នក។ ព្រះប្រទានពរ។

184 បងប្អូនស្រីជាទីស្រឡាញ់ អ្នកមានរឿងជាច្រើនដែលត្រូវអរព្រះគុណ។ ដេកនៅលើគ្រែ ជិតស្លាប់ ឥឡូវទីនេះអ្នកដើរបាន អាសនា។ ព្រះប្រទានពរអ្នកមានចិត្តទន់។

185 ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលម្តងទៀតឥឡូវ។ ចូរប្រែចិត្តចូរស្រែកយំទៅកាន់ព្រះ ចូរអធិស្ឋានដោយការអធិស្ឋានរបស់អ្នកផ្ទាល់។ អ្នកជាម្នាក់ដែលបានធ្វើបាបឥឡូវក៏ជាម្នាក់ធ្វើការអធិស្ឋានដែរ។ សូមប្រាប់ ដល់ព្រះអ្នកសោកស្តាយអ្វីអ្នកធ្វើខុស។ កុំខ្វល់ពីអ្នកនៅជុំវិញអ្នក។ សូមត្រឹមតែនិយាយ "ព្រះ អត់ទោសឲ្យទូលបង្គំ ទូលបង្គំមិនចង់បែបនោះឡើយ។ ទូលបង្គំចង់មានចិត្តសុភាព។ ទូលបង្គំ—ទូលបង្គំនឹងមិនឆ្លងវានិងនិងស្រែកបង្អកទៀតឡើយ"។

186 អូ ព្រះអង្គអើយ អូ ទូលបង្គំស្រឡាញ់ណាស់! ព្រះបិតាគង់ស្ថានសួគ៌ អ្នកជំងឺនីមួយៗនៅទីនេះក្បែរអាសនា លុតជង្គង់ពួកគេ អធិស្ឋាន! អូ ព្រះសូមឲ្យម្តាយឪពុក កូន ឪពុកនានា ម្តាយនានា អ្វីទៀតក៏ដោយ អ្នកជិតខាង សមាជិកក្រុមជំនុំចាស់ទុំក្រុមប្រឹក្សា អូ ព្រះអង្គអើយនៅវេលានៃទម្លាប់ចាស់នេះ អង្គុយក្នុងបន្ទប់ក្តៅព្រឹកនេះ ព្រះវិញ្ញាណបរិសុទ្ធយាងចុះមក និយាយដោយសេចក្តីសុខសាន្ត។ អូ ព្រះ ទូលបង្គំចង់ឈរនៅថ្ងៃនោះហើយឮទ្រង់មានបន្ទូលជាផ្អែមល្ហែម "មែនហើយអ្នកបានចេញមក ហើយឈរសម្រាប់ខ្ញុំ ឥឡូវខ្ញុំនឹងឈរសម្រាប់អ្នក"។ ទូលបង្គំចង់ឲ្យទ្រង់ដាក់សន្តិភាពសុខសាន្តក្នុងចិត្តម្នាក់ៗនៅទីនេះក្នុងថ្ងៃនេះព្រះអើយ។

ដោយស្ងប់ស្ងៀមនិងសុភាព ទូលបង្គំចង់ឲ្យទ្រង់ធ្វើបែបនេះ។ ទូលបង្គំចង់ឲ្យទ្រង់ធ្វើចលនាក្នុងនោះជាអារម្មណ៍ ដែលវានឹងមិនចេញពីគេទៀតឡើយ ពីថ្ងៃនេះតទៅ។ សូមឲ្យផ្ទះបានជាថ្មី។ សូមឲ្យមនុស្សបានក្លាយជាមនុស្សថ្មី។ សូមឲ្យគ្រប់យ៉ាងបានក្លាយជាថ្មីថ្ងៃនេះ ពួកមនុស្សទាំងនេះគេបានបន្ទាបខ្លួន។ ទ្រង់មាន

បន្ទូល "បើសិនជាមនុស្សដែលហៅតាមឈ្មោះយើងនិងបន្ទាបខ្លួន និងអធិស្ឋាន ដូច្នេះយើងនឹងស្តាប់គេពីស្ថានសួគ៌"។ ហើយទូលបង្គំដឹងថាទ្រង់នឹងធ្វើវា ព្រឹកនេះ ព្រះអង្គអើយ។

187 ហើយទូលបង្គំអធិស្ឋាន ការអត់ទោសសម្រាប់អ្នក ដែលនៅតែកន្លែងអង្គុយរបស់ពួកគេ ដែលគួរតែមក។ ព្រះ មានបន្ទូលទៅកាន់ពួកគេ និងសូមឲ្យពួកគេមិនមានសេចក្តីសុខសាន្ត មិនមាននៅលើផែនដីរហូតទាល់ តែគេធ្វើការសម្រេចចិត្តនោះ ព្រះអម្ចាស់ ដែលមកនិងបានជាសេចក្តីជាមួយទ្រង់វិញ្ញាណ។ សូមទទួលវា ព្រះអម្ចាស់។ សូមប្រទានពរដល់ម្នាក់ៗឥឡូវ។ សូមឲ្យសេចក្តីសប្បុរសរបស់ទ្រង់ និងក្តីមេត្តារបស់ទ្រង់ជាប់នៅជាមួយព្រលឹងម្នាក់ៗ ដែលអង្គុរនិងឱនក្នុងព្រះវិហារព្រឹកនេះ។

188 ព្រះបិតា ព្រះ ទូលបង្គំបានធ្វើក្នុងការជាប់នៅជាមួយទ្រង់។ ទូលបង្គំបានហៅមនុស្សទាំងនេះ ពួកគេបានក្រោកឈរ។ ទ្រង់មានបន្ទូល "អ្នកដែលធ្វើបន្ទាល់ពីខ្ញុំនៅមុខមនុស្ស ខ្ញុំនឹងធ្វើបន្ទាល់ពីអ្នកនោះនៅមុខព្រះបិតាដែរនិងពួកបរិសុទ្ធផង"។ មនុស្សជាច្រើននៅទីនេះបានក្លាយជាគ្រីស្ទានជាយូឆ្នាំ ហើយ ប៉ុន្តែពួកគេឈរនៅព្រឹកនេះដើម្បីធ្វើបន្ទាល់ពីបាប របស់ពួកគេដែលពួកគេបានធ្វើខុស។ ពួកគេក្លាយជាអ្នកមិនអាចស្រឡាញ់បាន។ ព្រះវិញ្ញាណបរិសុទ្ធ បានចេញពីគេទៅ។ ហើយមានពេលជាច្រើន ដែលពួកគេមិនអាចមានអារម្មណ៍សុភាពម្តងទៀត ផ្អែមល្ហែម អារម្មណ៍ស្លូតបូតដែលពួកគេគួរតែមាន។ មានពួកគេជាច្រើនក៏ជាមនុស្សបាបដែលមកជាលើកដំបូង។ ប៉ុន្តែព្រះបិតាពួកគេចង់មានអារម្មណ៍អស្ចារ្យ សេចក្តីសុខសាន្តដែលលើសអស់ទាំងការយល់ដឹង។ សូមប្រទានឲ្យពួកគេនៅថ្ងៃនេះ ព្រះជាព្រះអម្ចាស់ និងសូមឲ្យពួកគេទាំងអស់បានក្លាយជាទីគួរឲ្យស្រឡាញ់និងពេញដោយព្រះវិញ្ញាណទ្រង់កាលបើគេចេញពី ទីនេះនៅថ្ងៃនេះចេញទៅតាមផ្ទះខុសៗ គ្នាឲ្យរស់នៅជាជីវិតខុសប្លែកនិងជាមនុស្សខុសប្លែក។ ទូលបង្គំយើងខ្ញុំសូមដោយព្រះនាមនៃព្រះគ្រីស្ទ។

189 "បន្ទប់នៅប្រភពទឹក" ត្រូវហើយ អ្នកនៅទីអាសនា ងើបឡើង សម្លឹងមើលព្រះអម្ចាស់បង្វែរខ្លួននិងអង្រួនដៃជាមួយគ្រប់គ្នាជុំវិញអ្នក។ អូ យើងនឹងច្រៀងគ្រប់គ្នាឥឡូវ ពេលយើងឈរមួយភ្លែតមុខកម្មវិធីប្រោសឲ្យជា។

បន្ទប់ បន្ទប់ មែនហើយ មានបន្ទប់
មានបន្ទប់នៅប្រភពទឹកសម្រាប់អ្នក បន្ទប់
បន្ទប់ មែនហើយ មានបន្ទប់
មានបន្ទប់នៅប្រភពទឹកសម្រាប់អ្នក (គ្រប់គ្នា)

...បន្ទប់ បន្ទប់ មែនហើយ មានបន្ទប់
មានបន្ទប់នៅប្រភពទឹកសម្រាប់អ្នក
បន្ទប់ បន្ទប់ មែនហើយ មានបន្ទប់
មានបន្ទប់នៅប្រភពទឹកសម្រាប់អ្នក

បន្ទប់ បន្ទប់ មែនហើយ មានបន្ទប់!
[ចំណុចទទេលើខ្សែអាត់—Ed។]

190 ជំនឿ! អ្នកដឹងថ្ងៃផ្សេងទៀត បងប្អូនប្រុស ពេលរបស់អ្នក—ប្រពន្ធរបស់អ្នកហៅមក អធិស្ឋានសម្រាប់អ្នក? ចូលទៅបន្ទប់ និងព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលមកកាន់ខ្ញុំ "កុំខ្លាច" អាម៉ែន។ តើទ្រង់មិនពិតឬ? អស្ចារ្យ! ល្អ សរសើរព្រះអម្ចាស់! ខ្ញុំចង់ស្រែកពីជ័យជំនះ! ត្រូវហើយ។

ហើយព្រះលោហិតទ្រង់សំអាតឲ្យសជាង...(មានអ្វីត្រូវ
និយាយរឺ?)
ព្រះយេស៊ូវសង្គ្រោះ!...?...

191 ត្រូវហើយ បងប្អូនប្រុសនេវីល(Neville)ឥឡូវ។ និងបងប្អូនប្រុសស្លុតធី(Slaughter)មានពាក្យត្រូវនិយាយ។

[បងប្អូនប្រុសស្លុតធីនិយាយ។ ចំណុចទទេលើខ្សែអាត់—Ed។]

[បងប្អូនប្រុសនេវីលនិយាយ "ខ្ញុំ! អរគុណព្រះអម្ចាស់! អាមែន! សរសើរតម្កើងព្រះខ្ញុំជឿគ្រប់យ៉ាងដែលបានទទួលនៅព្រឹកនេះ"] សិរីរុងរឿង! ហាលេលូយ៉ា! ហាលេលូយ៉ា! បងប្អូនប្រុសនេវីល និយាយ រួចគាត់និយាយ "សូមចងចាំកម្មវិធីនៅយប់នេះ យើងមានការលាងជើងនិង ពិធីលៀងព្រះអម្ចាស់" គាត់សួរបងប្រុសប្រាណហាំ "អ្នកដឹងថាតើអ្នកនឹងនៅទីនេះទេ?"] ខ្ញុំប្រហែលជានៅទីនេះនៅយប់នេះ។ ហ្នឹងហើយ តាមតែខ្ញុំដឹង ខ្ញុំនឹងនៅទីនេះរហូតដល់ខ្ញុំមានការហៅទៅកន្លែងណាមួយ។

## ក្រុមជំនុំ និងស្ថានភាពរបស់ក្រុមជំនុំ KHM56-0805

(The Church And Its Condition)

**តំណាមេរៀនអំពីក្រុមជំនុំ**

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅព្រឹកថ្ងៃអាទិត្យ ថ្ងៃទី 05 សីហា 1956 នៅរោងឧបោសថ Branham, Jeffersonville, Indiana, U.S.A.។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវជាសារសម្លេងចេញពីខ្សែរអាត់ថតចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក។

KHMER

©2019 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG